ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- រដ្ឋាភិបាលអាមេរិកផ្តល់ទឹកប្រាក់ជាយថ្នូទានដែលមានតម្លៃ២០លានដុល្លារ
- ការធ្វើទស្សនកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌលសន្តិភាព

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២០៨ ខែមេសា ឆ្នាំ២០១៧

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២០៨ ខែមេសា ឆ្នាំ២០១៧

## មាតិកា

◆ រដ្ឋាភិបាលសហរដ្ឋអាមេរិកផ្តល់ទឹកប្រាក់ទាយជ្ជទាន ដែលមានតម្លៃ២០លាន ដុល្លារសហរដ្ឋអាមេរិកដល់លោក ឆាំង យុ ......................................១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់ គាំ ចាន់ ហៅ ចន លេខាតំបន់៤៣ ................៣

◆ យុវជន-យុវនារីបដិវត្តន៍ ត្រូវបំពាក់និស្ស័យគិតគូរ ពិចារណា ...........១២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ថ្ងៃដែលយើងមិនត្រូវបំភ្លេច ......................................................២៨

◆ វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានស្តីអំពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជា .......៣០

◆ ជីវិតរបស់ កៅ ផាន្នី នៅក្នុងរបបខ្មែរក្រហម................................៣៣

**ផ្នែកច្បាប់**

◆ សំណួររបស់មេធាវីចុងចោទ ទៅកាន់សាក្សី និងដើមបណ្តឹង ...............៣៥

**វេទិកាពិភាក្សាសាធារណៈ**

◆ ការធ្វើទស្សនកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌល ...............៤៥

◆ ការបង្កើតជារូបរាង និងការរចនាឡើងនូវវិទ្យាស្ថានស្លឹករឹត ................៥០

◆ ចំណាប់អារម្មណ៍របស់និស្សិតស្តាបត្យកម្មចំពោះស្នាដៃរចនារបស់ .........៥២

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ "សល់មួយគ្រាប់" .........................................................................៥៥

◆ "សាភណីយ" ..................................................................................៥៨



ប្រជាជនត្រូវបានជម្លៀសចេញពីផ្ទះសម្បែង បន្ទាប់ពីរបបខ្មែរក្រហមឡើងកាន់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**អ្នកសរសេរលេខនេះ** ៖ លី សុខឃាង, ម៉ែន ពិចិត្រ, លីអូនី គីដេស្តី, កាហ្វ៊ី ហេជីវីងតុន, ម៉ាកឃីស ហ្សីមមឺរ, យ៉េង សិរីរ័ត្ន, សូ វិទូ, សៀង សត្យា, ហែម សុវណ្ណារិទ្ធិ និង ផាន់ សុផល **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ ទាវ សារៈមុនិន្ទ និង ឆេង វើង **អ្នកបកប្រែ** ៖ ឈឹម អមរ័ត្ន និង ឯម សីលា **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ជំនួយការនិពន្ធនាយក** ៖ សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ** ៖ សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ** ៖ សន ល័ក្ខ **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org, www.truthcambodia.com**

# រដ្ឋាភិបាលសហរដ្ឋអាមេរិកផ្ដល់ទឹកប្រាក់ទាយជ្ជទានដែលមាន តម្លៃ២០លានដុល្លារ សហរដ្ឋអាមេរិកដល់លោក ឆាំង យុ

រដ្ឋាភិបាលសហរដ្ឋអាមេរិក ផ្ដល់សាច់ប្រាក់ចំនួនប្រមាណ ១០លានដុល្លារសហរដ្ឋអាមេរិក (៩លាន៨សែន) ដែលមានតម្លៃជាទាយជ្ជទានចំនួន២០លានដុល្លារសហរដ្ឋអាមេរិកគឺជាការឧបត្ថម្ភដ៏ធំបំផុតមួយសម្រាប់អង្គការក្រៅរដ្ឋាភិបាលក្នុងឆ្នាំ២០១៧នេះ ដល់លោកឆាំងយុ ។



លោក ឆាំង យុ គឺជានាយក និងស្ថាបនិកមួយរូបនៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងខែមករា ឆ្នាំ១៩៩៥ ដែលត្រូវបានគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និងបង្កើតឡើងដោយក្រុមការងាររបស់លោកមកពីសកលវិទ្យាល័យយ៉េល បន្ទាប់ពីសភាសហរដ្ឋអាមេរិកអនុម័តលើច្បាប់ស្តីពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដោយមានលោកប្រធានាធិបតី ប៊ីល ឃ្លីនតុន ចុះហត្ថលេខាចូលជាធរមាននៅក្នុងខែមេសាឆ្នាំ១៩៩៤ ។ លោក ឆាំង យុ មានប្រសាសន៍ថា លោកនឹងប្រើប្រាស់ថវិកាទាយជ្ជទាន ២០លានដុល្លារសហរដ្ឋអាមេរិកនេះ ដើម្បីលើកកម្ពស់ការស្រាវជ្រាវ និងការអប់រំស្តីអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាសម្រាប់រយៈពេល២០ឆ្នាំខាងមុខ ។ លោក ឆាំង យុ គឺជាកូនប្រុសពៅក្នុងគ្រួសារមួយ នៅរដ្ឋធានីភ្នំពេញ ។ លោកបានកើតក្នុងឆ្នាំ១៩៦១ នៅសង្កាត់ទួលគោក ។ ម្ដាយរបស់លោកគឺ ឧបាសិកា កែវ ណាន ដែលមានស្រុកកំណើតនៅភូមិខ្មែរលើ ស្រុកព្រៃកប្បាស ខេត្តតាកែវ ដែលមានជន្មាយុ៨៩វស្សា នៅក្នុងឆ្នាំនេះ ។ លោក និងម្ដាយរបស់លោក ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ដោយពួកខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទៅរស់នៅក្នុងភូមិត្រពាំងវែង ក្បែរជើងភ្នំព្រះនេត្រព្រះ ក្នុងខេត្តបន្ទាយមានជ័យ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

លោក ឆាំង យុ មានប្រសាសន៍ថា ការអប់រំស្តីអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាគឺមានសារសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសកម្ពុជា និងពិភពលោកទាំងមូល ។ នៅពេលដែលមនុស្សជំនាន់ក្រោយៗនៃប្រទេសរបស់យើង បានយល់អំពីប្រវត្តិសាស្ត្រដ៏ជូរចត់មួយនេះ យើងនឹងមានក្តីសង្ឃឹមថា មនុស្សគ្រប់ជំនាន់ និងយកចិត្តទុកដាក់លើបញ្ហាសង្គម និងដោះស្រាយបញ្ហាសង្គមនៅក្នុងវិធីជាវិជ្ជមានផ្សេងៗ ហើយនេះនឹងជួយឲ្យសង្គមជាតិ មិនពើបប្រទះនឹងកំហុស ដែលធ្លាប់កើតមានឡើងពីអតីតកាល ។

លោកបានលើកឡើងថា លោកពិតជាមានកិត្តិយស និងសេចក្តីដឹងគុណ ក្នុងការទទួលយកនូវជំនួយដ៏សប្បុរសនេះ តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីការអភិវឌ្ឍអន្តរជាតិ បង្កើតឡើងដោយលោកប្រធានាធិបតីសហរដ្ឋអាមេរិក ចន កេណ្ណឌី នៅក្នុងឆ្នាំ១៩៦១ ដែលឈរលើទស្សនវិស័យមួយថាៈ «យើងត្រូវអត់ឱនដល់សត្រូវរបស់យើង ប៉ុន្តែយើងមិនត្រូវភ្លេចឈ្មោះសត្រូវរបស់យើងទេ» ។ ក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះក្រោមកិច្ចគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជាជំនួយជាច្រើនរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិបានទ្រទ្រង់ការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ជំរុញឲ្យមានការលើកកម្ពស់ការស្វែងរកការពិតដើម្បីការចងចាំ យុត្តិធម៌ ការផ្សះផ្សា និងការជាសះស្បើយ នៅក្នុងប្រទេសកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានផ្ដល់ឯកសារភស្តុតាងជាងកន្លះលានឯកសារដល់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយនៅបន្តជួយដល់ដំណើរការនៃសាលាក្តីមួយនេះដល់ទីបញ្ចប់ និងពង្រីកការងារការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការនេះ ។ ការទ្រទ្រង់នាពេលបច្ចុប្បន្នរបស់រដ្ឋាភិបាល

សហរដ្ឋអាមេរិក ក៏ដូចជាការទ្រទ្រង់ដ៏សប្បុរសកន្លងមករបស់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីការអភិវឌ្ឍអន្តរជាតិ និងផ្តល់នូវមូលដ្ឋានហិរញ្ញវត្ថុអចិន្ត្រៃយ៍ដ៏រឹងមាំមួយសម្រាប់ការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងរយៈពេល២០ឆ្នាំខាងមុខ ។

ការងាររបស់លោក ឆាំង យុ និងផ្តោតទៅលើការកសាងសង្គមប្រកបដោយសន្តិភាពមួយ តាមរយៈការស្រាវជ្រាវ និងការអប់រំស្តីអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ លោក ឆាំង យុ បានមានប្រសាសន៍ថា មជ្ឈមណ្ឌលឯកសារកម្ពុជា និងបន្តការងារប្រមូល និងចងក្រងឯកសារប្រវត្តិសាស្ត្រស្តីពីការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ តាមរយៈការធ្វើឲ្យឯកសារមានទម្រង់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការអភិរក្ស និងការជួសជុលស្តារឡើងវិញ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បន្តការផ្តល់តម្លៃប្រវត្តិសាស្ត្រ ព្រមទាំងរក្សាការចងចាំរបស់ជនរងគ្រោះដោយរបបខ្មែរក្រហម និងជនរងគ្រោះនៃអំពើឃោរឃៅដទៃទៀត តាមការងារផ្សេងៗរួមមាន ការតាំងពិព័រណ៍ បោះពុម្ព លទ្ធផលនៃការស្រាវជ្រាវ និងការចុះទៅភូមិស្រុកដើម្បីជួបជាមួយប្រជាជនឲ្យបានទៀងទាត់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បន្តការរួមចំណែកកសាងនូវអនាគតដ៏ត្រចះត្រចង់មួយរបស់កម្ពុជាតាមរយៈការបង្រៀនមនុស្សជំនាន់ក្រោយៗ អំពីតម្លៃនៃការសិក្សាប្រវត្តិសាស្ត្រ ដែលមិនអាចកាត់ថ្លៃបាន ការអភិរក្ស និងរំលេចវប្បធម៌ និងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ លោកនឹងរក្សានូវសម្ពន្ធភាពការងារយ៉ាងប្រសិទ្ធភាពដែលមានកន្លងមក ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ១) ក្រសួងមហាផ្ទៃ ក្នុងការផ្សព្វផ្សាយដល់ប្រជាជនទូទាំងប្រទេស ក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ២) ឯកឧត្តមរដ្ឋមន្ត្រីបណ្ឌិត ហង់ ជួនណារ៉ុន និងលោកជំទាវអនុរដ្ឋលេខាធិការ ទន់ សាអ៊ឹម នៃក្រសួងអប់រំ យុវជន និងកីឡា លើការអប់រំ និងស្រាវជ្រាវអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ៣) ឯកឧត្តមរដ្ឋមន្ត្រីបណ្ឌិត ថោង ខុន នៃក្រសួងទេសចរណ៍ ឯកឧត្តមអភិបាលខេត្តឧត្តរមានជ័យ ស ថាវី និង លោក ហោ ជិនវីរៈយុទ្ធ អភិបាលស្រុកអន្លង់វែង លើការថែរក្សាសន្តិភាព និងគោរពសិទ្ធិមនុស្សតាមរយៈការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ៤) លោកជំទាវរដ្ឋមន្ត្រីបណ្ឌិត ភឿង សកុណា នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លើការអភិរក្សនិងស្តារវប្បធម៌ និង ៥) អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលធ្វើការលើកកម្ពស់យុត្តិធម៌អំពីអំពើប្រល័យពូជសាសន៍ ការចងចាំ និងការផ្សះផ្សានៅកម្ពុជា ។

លោកស្រី ប៉ូលី ជីនហ៊ុត នាយិកាទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ មានប្រសាសន៍ថាៈ «ទាយជ្ជទាននេះនឹងធ្វើឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា មានលំនឹងប្រាកដប្រជាមួយ ហើយសហរដ្ឋអាមេរិកមានសេចក្តីរីករាយ ក្នុងការគាំទ្រដល់ការខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចូលរួមចំណែកធ្វើឲ្យអនាគតកម្ពុជាកាន់តែប្រសើរឡើង តាមរយៈការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់យុវ័យជំនាន់ក្រោយ ការជួយថែរក្សាវប្បធម៌របស់គេ ព្រមទាំងលើកកម្ពស់ដល់ការគោរពសិទ្ធិមនុស្ស» ។

បន្ថែមនូវការងារដែលកំពុងប្រព្រឹត្តទៅរបស់លោក ឆាំង យុ ស្តីពីចលនាខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជាទាយជ្ជទាននាបច្ចុប្បន្ននេះ និងអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ផ្តើមធ្វើដំណើរទៅរកការពង្រីកការងាររបស់លោក ក្នុងការអប់រំផ្សព្វផ្សាយទៅបណ្តាប្រទេសនានា ក្នុងតំបន់អាស៊ីអាគ្នេយ៍ និងការសាងសង់មជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍ ដែលមានឈ្មោះថា «វិទ្យាស្ថានស្លឹករឹត» ។

លោកសូមថ្លែងអំណរគុណដល់ប្រជាជនកម្ពុជា ជាពិសេសជនរងគ្រោះនៃរបបខ្មែរក្រហមទាំងអស់ដែលតែងតែស្វាគមន៍ និងគាំទ្រដល់ការងាររបស់លោក ។ លោកសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលផ្តល់សេចក្តីទុកចិត្តមកលើលោក ចំពោះការងារជាប្រវត្តិសាស្ត្រនេះ ។ លោកក៏សូមថ្លែងអំណរគុណដល់ប្រជាជនអាមេរិកាំងទាំងអស់ ហើយលោកនឹងប្រតិបត្តិការការងារនេះ ដោយសេចក្តីដឹងគុណ ក៏ដូចជាការប្តេជ្ញាក្នុងការប្រយុទ្ធប្រឆាំងនឹងទណ្ឌភាព និងការការពារសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះជាង២លាននាក់ ដែលបានបាត់បង់ជីវិតនៅក្នុងសម័យខ្មែរក្រហម និងអ្នកដែលរស់រានមានជីវិតពីរបបនេះ ព្រមទាំងមនុស្សជំនាន់ក្រោយមកទៀត ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ចម្លើយសារភាពរបស់ គាំ ចាន់ ហៅ ចន លេខាតំបន់៤៣ ភាគកណ្តាល

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D៤១២៦៤*

គាំ ចាន់ ហៅ ចន អាយុ៤៤ឆ្នាំ ជាអតីតលេខាតំបន់៤៣ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចន បានក្លាយខ្លួនជាអ្នកទោសពីបទធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ហើយត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧ និងបញ្ជូនមកមន្ទីរសន្តិសុខស-២១ ដើម្បីសួរចម្លើយ ។ ចន មានស្រុកកំណើតកើតនៅភូមិបាក់ស្មោរ ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ នៅក្នុងចម្លើយសារភាពរបស់ ចន បែកចេញជាច្រើនផ្នែក ដែលផ្នែកទីមួយសរសេរពីសេចក្តីរាយការណ៍អំពីប្រវត្តិសកម្មភាពក្បត់ (មានចំនួន៧២ទំព័រ) សរសេរចប់នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៧ ផ្នែកទីពីរជាសេចក្តីកំណត់ហេតុអំពីសកម្មភាពក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ សរសេរដោយអ្នកសួរចម្លើយឈ្មោះ ទុយ (មានចំនួន៣៤ទំព័រ) ធ្វើចប់នៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៧៧ ផ្នែកទីបីសរសេរពីសកម្មភាពក្បត់ផ្ទាល់របស់ គាំ ចាន់ ហៅ ចន ពីខែមីនា ឆ្នាំ១៩៧៦ ដល់ខែកញ្ញា ឆ្នាំ១៩៧៧ (ជាសេចក្តីរាយការណ៍បន្ថែមនូវសកម្មភាពដែល ចន មិនបានរាយការណ៍នៅក្នុងចម្លើយសារភាព មានចំនួន២០ទំព័រ) និងផ្នែកចុងក្រោយសរសេរអំពីសេចក្តីសរុបពីផែនការកម្ទេចឃ្លាំងគ្រាប់បែក និងគ្រាប់មីននៅមន្ទីរភ័ស្តុភារកងពល១៧៤ រួមជាមួយនឹងសេចក្តីសង្ខេបចម្លើយសារភាពផ្សេងៗទៀត (មានចំនួន២៥ទំព័រ) ។ សរុបក្នុងចម្លើយសារភាពរបស់ ចន ទាំងអស់មានចំនួនទំព័រ១៥១ទំព័រ ។ យើងមិនដឹងថាសំណេរនៅក្នុងចម្លើយសារភាពរបស់ ចន ពិតឬយ៉ាងណានោះទេ ខាងក្រោមនេះ ជាការដកស្រង់ដោយសង្ខេបអំពីប្រវត្តិ និងសកម្មភាពក្បត់របស់ គាំ ចាន់ ហៅ ចនៈ

តាំងពីតូច ចន រស់នៅជាមួយឪពុកម្តាយ ដល់អាយុបាន១៤ឆ្នាំ ឪពុកម្តាយក៏បានបញ្ជូនឲ្យទៅរៀននៅវត្តកំពង់ថ្ម ក្នុងស្រុកសន្ទុក ។ លុះរៀនបានរយៈពេលបីឆ្នាំ ចន បានឈប់រៀន ហើយវិលមករកស៊ីធ្វើស្រែចម្ការជាមួយឪពុកម្តាយវិញ ។ ក្រោយមកទៀត នៅពេល ចន មានអាយុ២២ឆ្នាំ ឪពុកម្តាយក៏បានរៀបការប្រពន្ធឲ្យ ។

ឆ្នាំ១៩៦៦ ចន បានជាប់ចលនាបដិវត្តន៍ មានឈ្មោះ ពក ជាអ្នកដឹកនាំរហូតដល់ឆ្នាំ១៩៦៨ ចលនានេះត្រូវបែកការណ៍ ។ ពេលនោះ ចន ត្រូវបានខ្មាំងចាប់ខ្លួនយកទៅដាក់គុកនៅកំពង់ធំជាងមួយខែ រួចក៏បញ្ជូនបន្តទៅគុកព្រៃស ។ នៅព្រៃសរយៈពេលបួនខែ ចន មាននាទីជាអ្នកយកសំរាមទៅចោលខាងក្រៅគុកជាមួយឈ្មោះ គុល ។ តាមរយៈឈ្មោះ គុល នេះ ចន បានទាក់ទង និងរាប់អានជាមួយឈ្មោះ ម៉ែន យ៉ាងជិតស្និទ្ធជាប់រហូតមក តែដល់ពេលចេញពីគុកអ្នកទាំងពីរក៏បានបែកគ្នាទៅកន្លែងទីទៃរៀងៗខ្លួន ។

ឆ្នាំ១៩៧០ ចន, គុល និង យ៉ែន បានជាប់ក្នុងចលនាបដិវត្តន៍ជាមួយ ពក នៅវត្តសំរោង ក្នុងស្រុក១៣០ ។ នៅពេលនោះរដ្ឋអំណាចបានចាត់តាំង ចន ឲ្យមករៀបចំរដ្ឋអំណាចនៅភូមិឃុំក្នុងស្រុកបារាយណ៍ ហើយនឹងរៀបចំកងទ័ពចំនួន១០០នាក់ ចំណែក គុល និង យ៉ែន ត្រូវបានចាត់តាំងឲ្យទៅរៀបចំរដ្ឋអំណាចភូមិឃុំនៅក្នុងស្រុកសន្ទុក ។ ពេលនោះ ចន ត្រូវបានអង្គការចាត់ឲ្យមកបំពេញភារកិច្ចជាអ្នករៀបចំរដ្ឋអំណាចភូមិ ឃុំនៅក្នុងស្រុកបារាយណ៍ក្នុងតួនាទីជាប្រធាន ឈ្មោះ កែវ ជាអនុប្រធាន និងឈ្មោះ សយ ជាសមាជិក ។ បន្ទាប់មក ម៉ែន បានមកលេង និងបានសម្រាកជាមួយ ចន មួយយប់ ។ ពេលហូបបាយល្ងាចរួច ចន, ម៉ែន និង ម៉ុន បានអង្គុយនិយាយគ្នាលេង ។ ម៉ែន ក៏បានលើកពីសភាពការណ៍បដិវត្តន៍កម្ពុជា និងសភាពការណ៍បដិវត្តន៍យួន និងលើកពីសង្គ្រាមរវាងយួននិងចក្រពត្តិអាមេរិកថាមិនដឹងអ្នកណាឈ្នះ អ្នកណាចាញ់ ។ អាមេរិកជាប្រទេសមួយធំជាងប្រទេសយួន ហើយប្រទេសយួនបានប្រទេសសូវៀតជួយសព្វគ្រប់តាំងពីអាវុធ និងស្បៀង ។ ចំណែក

ប្រទេសកម្ពុជាយើងតូចណាស់ ធ្វើសង្គ្រាមវាយចក្រពត្តិមិនឈ្នះទេ ព្រោះយើងខ្វះសព្វ ខ្វះគ្រប់ កាំភ្លើងក៏ខ្វះ គ្រាប់ក៏ខ្វះ ជំនួយបរទេសក៏គ្មាន ។ ប្រទេសអាមេរិក គេមានអាវុធសម្បូរបែប មានកាំភ្លើងធំ យន្តហោះ រថក្រោះ ជាដើម ។ ចន បានស្តាប់ការលើកឡើងរបស់ ម៉ន ហើយក្នុងសតិអារម្មណ៍ និងគោលជំហររបស់របស់ ចន នៅពេលនោះពិនិត្យឃើញថា ជាការពិតដូច ម៉ន បាននិយាយមែន ។ និយាយគ្នារួចហើយ ក៏នាំគ្នាសម្រាក លុះព្រឹកឡើង ម៉ន និង ម៉ុន ក៏បានបែកពី ចន ទៅ ។ ក្រោយមក ចន ត្រូវបាន យួន ជាលេខាភូមិភាគហៅឲ្យទៅជួប ហើយបានណែនាំឲ្យបន្តការរៀបចំពង្រឹងរដ្ឋអំណាចឃុំតទៅទៀត ដើម្បីឲ្យអំណាចកាន់តែរឹងមាំ ងាយស្រួលក្នុងការបំពេញភារកិច្ច ។

ឆ្នាំ១៩៧១ យួន បានហៅ ចន ឲ្យទៅជួបជាមួយ ម៉ន និង ម៉ុន នៅកន្លែងគណៈសេនាធិការយោធាភូមិភាគ (នៅមន្ទីរព្រៃឃ្លៃ ជិតភូមិដងក្តារ ឃុំក្រយា ស្រុកសន្ទុក) ។ ពេលទៅដល់ ចន បានឃើញឈ្មោះ គុល នៅទីនោះដែរ ។ ក្រោយពីធ្វើសេចក្តីរាយការណ៍ប្រាប់គ្នារួចហើយ យួន បានណែនាំ ចន ឲ្យរៀបចំកន្លែងទុកដាក់ស្រូវ និងអំបិលធ្វើយ៉ាងណាទុកឲ្យឆ្ងាយពីផ្លូវជាតិលេខ៦ ហើយបានឲ្យវិទ្យុមក ចន និង គុល ម្នាក់មួយគ្រឿង ។ បន្ទាប់ពីបានទទួលការណែនាំពីយួន ហើយ ចន បានយកទៅអនុវត្តជាបន្តបន្ទាប់ ។ ខែមីនា ចន បានចូលរួមប្រជុំមួយជាមួយ យួន ដោយពេលនោះ យួន បានលើកពីសភាពការណ៍បដិវត្តន៍កម្ពុជា ដែលកំពុងវាយចក្រពត្តិអាមេរិក និងលន់ នល់ និងសភាពការណ៍បដិវត្តន៍សកលលោក ពិសេសបដិវត្តន៍ប្រទេសយួនដែលកំពុងវាយចក្រពត្តិអាមេរិក ។

យួន បាននិយាយថា បដិវត្តន៍កម្ពុជាសព្វថ្ងៃ ធ្វើសង្គ្រាមជាមួយចក្រពត្តិអាមេរិក និង លន់ នល់ ។ ចក្រពត្តិអាមេរិកជួយ លន់ នល់ តាំងពីអាវុធ គ្រាប់កាំភ្លើងធំ យន្តហោះ ឯយើងវិញ អង្គការមិនទទួលជំនួយបរទេសទេ ហើយឲ្យយើងវាយដណ្តើមអាវុធពីខ្មាំងយកទៅវាយខ្មាំងវិញ ។ បើតាមពិនិត្យ យើងវាយមិនឈ្នះទេ ។ នៅប្រទេសយួន ភាគខាងជើងធ្វើសង្គ្រាមវាយរំដោះភាគខាងត្បូងយូរឆ្នាំមកហើយ មិនទាន់ដឹងខាងណាឈ្នះចាញ់ទេ យួនទទួលជំនួយពីគ្រប់ប្រទេស ប៉ុណ្ណឹងហើយនៅតែវាយមិនឈ្នះចក្រពត្តិអាមេរិកទៀត ។ ឥឡូវនេះ ចន ឯងមានតែផ្លូវមួយទេ ដែលបានរួចខ្លួន គឺចូល សេ.អ៊ី.អា ។ បើយើងចូល សេ.អ៊ី.អា ទោះយើងវាយចាញ់ លន់ នល់ និងចក្រពត្តិអាមេរិក ក៏យើងបានរួចខ្លួន ព្រោះយើងជាសមាជិក សេ.អ៊ី.អា ស្រាប់ តែបើយើងវាយឈ្នះចក្រពត្តិអាមេរិក និងលន់ នល់ វិញ ក៏យើងបានរួចខ្លួនដែរ ព្រោះយើងនៅខាងបដិវត្តន៍ ។ ក្រោយពី យួន បានធ្វើការអប់រំហើយ ចន ក៏បានឯកភាពយល់ព្រមចូល សេ.អ៊ី.អា ។ ក្រោយពីបានចូលជាសមាជិក សេ.អ៊ី.អា ហើយ យួន បានណែនាំអំពីភារកិច្ចរបស់ សេ.អ៊ី.អា ដែលត្រូវបំពេញគឺ៖

១) យកចិត្តទុកដាក់ ឃោសនា អប់រំប្រជាជនដែលជាអ្នកមានសមាសភាពមិនល្អ មិនជ្រះស្រឡះជាមួយបដិវត្តន៍ និងពួកដែលជំពាក់ជំពិននិន្នាការនយោបាយខ្លាំងជាមួយបដិវត្តន៍ ឃោសនាបំផុសទំនាស់ ឲ្យស្មុគស្មាញ ឲ្យឃើញថាបដិវត្តន៍តឹងតែង រស់នៅលំបាក ។

២) យកចិត្តទុកដាក់ ខិតខំកសាងកម្លាំង ឲ្យបានច្រើនបង្កប់ស៊ីរូងផ្ទៃក្នុងឲ្យបានពាសពេញភូមិឃុំ និងជ្រើសរើសយកអ្នកដែលមានសមាសភាពមិនល្អ មកកសាងរួចហើយបញ្ចូលក្នុងរដ្ឋអំណាចឲ្យបានជាបន្តបន្ទាប់នៅកន្លែងដែលខ្លួនទទួលខុសត្រូវ ។

៣) យកចិត្តទុកដាក់រក្សាការសម្ងាត់ឲ្យខ្ពស់បំផុត ការទាក់ទងគ្នាត្រូវមានការប្រុងប្រយ័ត្ន ធ្វើយ៉ាងណាកុំឲ្យបែកការណ៍ ។

ឆ្នាំ១៩៧២ យួន បានហៅ ចន ឲ្យទៅជួប រួមជាមួយឈ្មោះ សុត និងឈ្មោះ សេង និងបានឲ្យភ្ជាប់ខ្សែជាមួយគ្នា នៅមន្ទីររបស់ភូមិភាគត-១៥ នៅក្នុងព្រៃចម្ការកៅស៊ូ ។ សុត ត្រូវបាន យួន ខទ្មុសនាមឲ្យធ្វើជាលេខាតំបន់១០៦ ចំណែក សេង អនុលេខាតំបន់១០៦ ។ ពេលនោះដែរ យួន បានបង្កើតជាគណៈវរសេនាតូច៣០៧ (ក្នុងឯកសារសរសេរថា បានចាត់តាំងជាគណៈវរសេនាតូច) ដោយចាត់ឲ្យឈ្មោះ ហឿង ធ្វើជាប្រធានវរសេនាតូច ឈ្មោះ ទួន ធ្វើជាអនុប្រធាន និង ចន ធ្វើជាសមាជិក ។ ពេលនោះ ចន អូសទាញកម្លាំងបានបីនាក់ ជាយោធានៅក្នុងកងវរៈក្រោមការគ្រប់គ្រងរបស់ខ្លួនផ្ទាល់ ដោយបានធ្វើការអប់រំឲ្យអ្នកទាំងបីឲ្យមើលឃើញពីបដិវត្តន៍មានការលំបាក ស្មុគស្មាញ មានវិន័យតឹងតែង យុទ្ធជនយុទ្ធនារីរស់នៅជិតគ្នាមិនបានប៉ះពាល់បន្តិចបន្តួចត្រូវអង្គការដាក់ពិន័យ គឺតឹងតែងជាងពីសង្គមចាស់ ។ នៅពេលដែលអ្នកទាំងបីយល់

ព្រមឯកភាពហើយ ចន ក៏បានបញ្ចូលអ្នកទាំងបីជាសមាជិក សេ.អ៊ី.អា នៅអង្គភាពតូចដែលមានឈ្មោះ ទុន ជាអ្នកខ្ទេសនាម ចន ជាអ្នកទទួលស្គាល់ ។ បន្ទាប់មក ចន ក៏បានដាក់ភារកិច្ច សេ.អ៊ី.អា ឲ្យអនុវត្តគឺៈ

១) ត្រូវអប់រំអ្នកដែលមានសមាសភាពកណ្តាល និងអ្នកដែលនៅជាប់កម្មសិទ្ធិ សតិអារម្មណ៍ស្មុគស្មាញជាមួយបដិវត្តន៍ អូសទាញគេបណ្តើរៗ នៅតាមកង និងអង្គភាពដែលខ្លួនទទួលខុសត្រូវ ។

២) ត្រូវកសាងកម្លាំងបង្កប់ក្នុងយោធាឲ្យបានច្រើនស្ទើរកស្ទះនៅតាមអង្គភាពរបស់ខ្លួន ។

៣) ត្រូវយកចិត្តទុកដាក់ទាក់ទងគ្នា ត្រូវមានការចាត់តាំងឲ្យបានហ្មត់ចត់ ចៀសវាងធ្វើឲ្យបែកការណ៍សម្ងាត់ ។ ពេលនោះដែរ ចន បានចាត់ឲ្យឈ្មោះ រិត យោធាកងធំ ឲ្យធ្វើសកម្មភាពបង្កទំនាស់ដោយចាប់ប្រធានឃុំចោទថាយកគោទៅលក់ឲ្យទាហាននៅបន្ទាយស្វាយធំ ជាសកម្មភាពមួយធ្វើឲ្យប្រជាជននៅសមរភូមិក្រោយមានការជ្រួលច្របល់ ខ្លាចយោធាចាប់ខ្លួនទៀត ។ ការណ៍ដែលធ្វើសកម្មភាពបែបនេះ គឺក្នុងគោលបំណងធ្វើឲ្យសមរភូមិក្រោយ និងសមរភូមិមុខមានការបាក់បែកសាមគ្គី លែងទុកចិត្តគ្នា ធ្វើឲ្យប្រជាជនមានសតិអារម្មណ៍មិនពេញចិត្តនឹងកងទ័ព ។

នៅចុងឆ្នាំ១៩៧២ អង្គការបានលើកទិសឲ្យវាយទាហាននៅសមរភូមិសៀមរាប ។ ពេលនោះ ឈ្មោះ ស្រេង សមាជិកភូមិភាគ បានបើកការប្រជុំមួយដែលអ្នកចូលរួមមានៈ ស្រេង សមាជិកភូមិភាគ, សុត លេខាតំបន់១០៦, សេង អនុលេខាតំបន់១០៦, ចន ប្រធានវរសេនាតូច៣០១, ហឿង ប្រធានវរសេនាតូច៣០៧, សៀន ប្រធានវរសេនាតូច៣០៦ និង ប៉េង ប្រធានវរសេនាតូច៣០៥ ។ ខ្លឹមសារប្រជុំ ឈ្មោះ ស្រេង បានលើកឡើងថា យើងប្រជុំគ្នានេះ គឺត្រូវវាយទាហាននៅប៉ុស្តិ៍ចិន តែប៉ុស្តិ៍នេះនៅជាប់វាលយន្តហោះ ហើយកន្លែងនេះមានភូមិសាស្ត្រឆ្ងាយទៀត ដូច្នេះយើងវាយតែមួយថ្ងៃមួយយប់ លុះព្រឹកឡើង យើងដកកងទ័ពមកអង្គរវិញ ។ ធ្វើយ៉ាងនេះ ឲ្យទាហាននៅប៉ុស្តិ៍ចិន និងទាហាននៅបន្ទាយវាលរំងៀលយន្តហោះ ឃើញកងទ័ពយើងដក គេវាយបុកយើង ធ្វើឲ្យកងទ័ពយើងរត់បាក់បែកគ្នា បាក់ស្មារតី ។ ក្រោយពេលប្រជុំ ចន បានយកការណែនាំរបស់ ស្រេង មកអនុវត្តតាមការកំណត់ ដោយបានចាត់ឲ្យកងទ័ពវាយប៉ុស្តិ៍ចិនមួយថ្ងៃមួយយប់ ហើយក៏ដកទ័ពនៅពេលព្រឹក ពេលនោះពួកទាហានឃើញយើងដកទ័ព ក៏បានវាយបុកកងទ័ពយើងពីក្រោយ បណ្តាលឲ្យកងទ័ពពលីអស់៦នាក់ និងរងរបួសចំនួន៨នាក់ ។

ឆ្នាំ១៩៧៣ ដោយអនុវត្តតាមការណែនាំមួយចំនួនរបស់ ឃួន លេខាភូមិភាគ ចន, ប៉េង, សៀន និង ហឿង បានធ្វើការវាយលុកនៅបន្ទាយសំរោង ដោយបានកៀរប្រជាជននិងដុតផ្ទះសម្បែងនេះអស់ជាច្រើនខ្នង ។ ពេលនោះ ចន បានទាក់ទងឈ្មោះ ហួត ជាទាហានស័ក្តិពីរនៅចុងកាល់តាមតេអូ ឲ្យនាំទាហានមកវាយបុកកងទ័ព ធ្វើឲ្យកងទ័ពបាត់ម្ចាស់ការ ពលីអស់៩នាក់ និងរបួស១២នាក់ ។ បន្ទាប់មក ចន បានទាក់ទងស័ក្តិមួយឈ្មោះ សាមិត្ត នៅបន្ទាយគោកត្រឡាចតាមការណែនាំរបស់ ឃួន ឲ្យបាញ់ផ្តត់កាំភ្លើងធំ ដើម្បីកម្ទេចវិមានយុទ្ធមិត្តពលីនៅស្រះស្រង់ដែលជាកន្លែងបញ្ចុះសាកសពកម្មាភិបាល និងយុទ្ធជនបណ្តាលឲ្យខូចខាតខ្ទេចខ្ទីអស់ ។ ចំណែក ឌឿន លេខាតំបន់៤៣បានទាក់ទងជាមួយទាហានស័ក្តិប្រាំឈ្មោះ ហ៊ិន ហ៊ៅ តាមរយៈតេអូលេខ៥ ឲ្យទាហានមកកៀរប្រជាជននៅក្នុងតំបន់៤៣ បានរាប់ម៉ឺននាក់យកទៅចូលក្រុងកំពង់ធំរួមជាមួយនឹងទ្រព្យសម្បត្តិជារបស់ប្រជាជនជាច្រើនទៀត ។ នៅខែកញ្ញា អង្គការបានហៅយោធាជាង១០០នាក់នៅក្នុងភូមិភាគ និងនៅមូលដ្ឋានឲ្យមកចូលរួមសន្និបាតដែលមាន ឃួន ជាប្រធាន និង ពក ជាអនុប្រធាន ។ ពេលនោះ ចន បានជួប គុល និង យ៉ន ហើយបានសួរសុខទុក្ខគ្នាទៅវិញទៅមក ។ ពេលសម្រាក ចន, គុល និង យ៉ន បានសម្រាក និងនិយាយលេងជាមួយគ្នាជាហូរហែ ។ ពេលនោះ គុល បាននិយាយថា យើងត្រូវខំធ្វើការងារឲ្យមែនទែន សំខាន់កសាងកម្លាំងបង្កប់ក្នុងយោធាយើងឲ្យបានច្រើន យើងត្រូវអប់រំពួកគេបណ្តើរៗ តែត្រូវប្រយ័ត្នបែកការណ៍ បើនរណាមិនទាន់ទុកចិត្ត កុំនិយាយឲ្យគេដឹងឲ្យសោះ ។ នៅពេលសន្និបាតចប់ ចន, គុល និង យ៉ន ក៏បានបែកគ្នា ។ ពេលនោះ ចន កសាងកម្លាំង សេ.អ៊ី.អា បានបីនាក់បន្ថែមទៀត ។

ឆ្នាំ១៩៧៤ ចន ត្រូវបាន ឃួន ផ្លាស់ពីសមរភូមិសៀមរាប អង្គរ ឲ្យមកទទួលជាលេខាស្រុកបារាយណ៍ ហើយបានចូលរួមប្រជុំ

នៅមន្ទីរភូមិភាគស្ថិតនៅក្នុងស្រុកសន្ទុក ដែលមានអ្នកចូលរួមចំនួន ៨នាក់ ដែលក្នុងនោះជាលេខាតំបន់៤១, ៤២, ៤៣ និងលេខាស្រុកស្ទោង លេខាស្រុកសន្ទុក និងលេខាស្រុកសណ្តាន់ ។ ខ្លឹមសារនៃការប្រជុំ យួន បានកំណត់ថា នៅក្នុងតំបន់ និងស្រុកនីមួយៗ ត្រូវរៀបចំធ្វើសកម្មភាពរុះរើផ្ទះធំៗរបស់ប្រជាជនមកធ្វើជាផ្ទះតូចៗ ហើយរៀបជាជួរៗ ត្រូវដាំចេកនៅតាមផ្លូវជាតិលេខ៦ ឲ្យបានជាទូទៅនៅក្នុងភូមិភាគ ដើម្បីងាយស្រួលធ្វើដំណើរ និងងាយដឹកជញ្ជូនសម្ភារស្បៀងយកទៅសមរភូមិមុខកុំឲ្យយន្តហោះមើលឃើញពីលើ ហើយនៅរដូវប្រាំងនេះត្រូវធ្វើអាងទឹកនៅតាមបណ្តោយផ្លូវជាតិរហូតដល់តាំងគោក ។ នៀតក្នុងឱកាសនោះ យួន ក៏បានប្រកាសជាផ្លូវការទទួលស្គាល់ ចន ជាលេខាស្រុកបារាយណ៍ចាប់ពីពេលនោះមក ។ ក្រោយពេលចេញពីប្រជុំ ចន បានណែនាំឈ្មោះ លឹម និងឈ្មោះ វន ឲ្យធ្វើសកម្មភាពបំផ្លើសមាគ៌ារបស់បក្ស រុះរើផ្ទះធំៗរបស់ប្រជាជន មកធ្វើផ្ទះតូចៗ រៀបជាជួរៗ និងកាប់ដើមដូង ដើមស្វាយ ដើមខ្នុរ និងដំណាំផ្សេងៗអស់ជាច្រើន ដែលសកម្មភាពទាំងអស់នេះធ្វើឲ្យប្រជាជនមានការថ្នាំងថ្នាក់ មានសតិអារម្មណ៍ស្មុគស្មាញ និងអស់ជំនឿជាមួយបដិវត្តន៍ ។ ក្នុងឆ្នាំនេះដែរ ចន កសាងសមាជិក សេ.អ៊ី.អា បានចំនួនប្រាំនាក់ ។

ក្រោយរំដោះ ១៧ មេសា ឆ្នាំ១៩៧៥ គុល លេខាតំបន់៤២ បានបង្កើតជាគណៈមួយ (គណៈកម្មការមួយ) ដើម្បីទទួល និងចាត់ចែងប្រជាជនថ្មី (ប្រជាជនជម្លៀស) ដោយបានចាត់ឲ្យ ចន ធ្វើជាប្រធាន ឈ្មោះ បួន លេខាស្រុកចម្ការលើ ធ្វើជាអនុប្រធាន និងឈ្មោះ ឡូន លេខាស្រុកតាំងគោក ជាសមាជិក ។ គុល បានលើកឡើងថា ប្រជាជនថ្មីទាំងអស់ ត្រូវប្រគល់ឲ្យ ចន ជាអ្នកចាត់ចែងយកទៅដាក់តាមស្រុកនៅក្នុងតំបន់ ។ គុល បានណែនាំទៀតថា នៅតាមមូលដ្ឋានទាំងអស់ ត្រូវចាត់តាំងឈ្លបឲ្យដើរឆែកឆេរ ដកយកសម្ភារពីប្រជាជនថ្មីដូចជានាឡិកាដៃ ខោអាវ ក្រណាត់ កង់ ម៉ូតូ ត្រូវប្រមូលដាក់ម្ដុំ ។ ប្រជាជនថ្មី ត្រូវយកទៅដាក់នៅឃុំចើងដើង ឃុំក្រវ៉ា ឃុំបាក់ស្នា ឃុំគគីរធំ ស្រុកបារាយណ៍ ឯស្រុកតាំងគោក ត្រូវដាក់នៅឃុំអណ្ដូងពោធិ៍ ស្រុកចម្ការលើត្រូវយកទៅដាក់នៅឃុំអូរនុង អន្ទង់ពេជ្រ ស្រុកស្ទឹងត្រង់ ដាក់នៅឃុំស្រែវាល ស្រុកព្រៃកប្រសព្វដាក់នៅព្រាំប្រទល់១៣០ ។ យើងយកប្រជាជនថ្មីដាក់នៅកន្លែងទាំងនោះ គឺក្នុងគោលបំណងធ្វើឲ្យប្រជាជនថ្មីឈឺស្លាប់ ព្រោះទីកន្លែងដែលយើងដាក់ប្រជាជនថ្មីសុទ្ធតែជាកន្លែងដែលងាយកើតជំងឺគ្រុនចាញ់ ។ ចប់ការប្រជុំ ចន បានហៅអនុលេខាស្រុកទាំងអស់មកប្រជុំ ហើយបានលើកឡើងតាមលំនាំដែលឈ្មោះ គុល បានលើកឡើង ។ ពេលប្រជុំចប់ ចន បានចាត់ឲ្យ លឹម អនុលេខាស្រុក រើសយកយុទ្ធជនយោធានៅស្រុកបារាយណ៍ចំនួនបីនាក់ឲ្យដើរឆែកឆេរដកយកសម្ភារពីប្រជាជនថ្មី មានដូចជានាឡិកាដៃបានចំនួន៥០ ខោអាវ-ក្រណាត់មួយចំនួន ម៉ូតូ៦០គ្រឿង កង់ចំនួន៨០ យកទៅចែកឲ្យប្រជាជនចាស់ទាំងអស់ ហើយបានយកប្រជាជនថ្មីទៅដាក់នៅតាមឃុំមួយចំនួនតាមផែនការខាងលើ ធ្វើឲ្យប្រជាជនថ្មីស្លាប់អស់ជាច្រើនរយនាក់ដោយសារជំងឺគ្រុនចាញ់ ។

បន្ទាប់មក ចន កសាងកម្លាំង សេ.អ៊ី.អា បានបីនាក់ ហើយបានណែនាំឲ្យបំពេញភារកិច្ចរបស់ សេ.អ៊ី.អា ដើម្បីធ្វើការប្រឆាំងនឹងបដិវត្តន៍ ។ មួយខែក្រោយមក ចន បានទៅចូលរួមប្រជុំនៅកំពង់ចាម ដែលដឹកនាំដោយឈ្មោះ ស្រេង ជាសមាជិកភូមិភាគ ។ ខ្លឹមសារនៃការប្រជុំគឺផ្ដោតសំខាន់ទៅលើការរៀបចំចាត់តាំងគណៈភូមិភាគឲ្យបានស្រួលបួលឡើងវិញ ព្រោះ យួន ដែលជាលេខាភូមិភាគ ត្រូវផ្លាស់ទៅបំពេញភារកិច្ចថ្មីនៅភ្នំពេញ ។ អ្នកដែលត្រូវចាត់ឲ្យទទួលនាទីមានដូចជា ៖

១) ឈ្មោះ ស្រេង ទទួលជាលេខាភូមិភាគ
២) ហង់ (លេខាតំបន់១០៣) ជាអនុលេខាភូមិភាគ
៣) គុល (លេខាតំបន់៤២) ជាសមាជិកភូមិភាគ
៤) សេង (លេខាតំបន់៤៣) ជាសមាជិកភូមិភាគ
៥) ងឹន (អនុលេខាតំបន់៤១) ជាសមាជិកភូមិភាគ
៦) លី (លេខាកងពល) ជាសមាជិកភូមិភាគ
៧) ចន (លេខាស្រុកបារាយណ៍) ជាសមាជិកភូមិភាគ និង
៨) តាំង (លេខាស្រុកព្រៃឈរ) ជាសមាជិកភូមិភាគ ។

បន្ទាប់ ពីបានប្រកាសចាត់តាំងហើយ ស្រេង បានណែនាំអង្គប្រជុំឲ្យចាប់អារម្មណ៍ឲ្យបានខ្ពស់បំផុតអំពីភារកិច្ចកសាងកម្លាំងឲ្យបានច្រើន ដើម្បីបង្កប់ស៊ីរូងផ្ទៃក្នុងក្នុងរដ្ឋអំណាចសហករណ៍ និងនៅគ្រប់ក្រសួងនានានៅក្នុងតំបន់នីមួយៗ នៅតាមមូលដ្ឋាននីមួយៗដែលខ្លួនទទួលខុសត្រូវ ។ ចប់ការប្រជុំសមាជិកទាំងអស់ក៏បានបំបែក

គ្នាទៅកន្លែងរៀងៗខ្លួន ។ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៥ នេះដែរ គុល បានចាត់តាំងជាគណៈកម្មការទទួលប្រជាជនជម្លៀសមកពីខាងបូព៌ា ដោយឲ្យ ចន ធ្វើជាប្រធាន និងឈ្មោះ ហៀង ជាអនុប្រធាន ហើយបានណែនាំឲ្យទទួលប្រជាជន បែកទៅតាមស្រុកនៅក្នុងតំបន់៤២ និងបែកទៅខាងស្រុកសន្ទុក តំបន់៤៣ ។ ទទួលបានការណែនាំរួចហើយ ចន បានចាត់អ្នកបើកបរឈ្មោះ គុណ ឲ្យឆែកឆេរប្រជាជន ដោយដកបាននាឡិកាដៃចំនួន១០ និងមាសកន្លះគីឡូ យកទៅប្រគល់ឲ្យ គុល ហើយបានកសាងកម្លាំងបានមួយចំនួន ដោយបានបញ្ចូលជាសមាជិក សេ.អ៊ី.អា នៅមន្ទីរឃុំបាល័ង្ក ដោយឈ្មោះ លីម អនុលេខាស្រុកជាអ្នកខ្ទេសនាម និង ចន ជាអ្នកទទួលស្គាល់ ហើយបានណែនាំឲ្យអ្នកទាំងនេះ ឲ្យយកចិត្តទុកដាក់ ឃោសនាអប់រំ បំពាក់បំប៉នប្រជាជនណាដែលនៅមានសតិអារម្មណ៍ជំពាក់ជំពិនមិនទាន់ជ្រះស្រឡះជាមួយបដិវត្តន៍ ដែលនៅជាប់កម្មសិទ្ធផ្ទាល់ខ្លួន អូសទាញបណ្តើរៗឲ្យមកខាងយើង ដើម្បីធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ជាបន្តទៅទៀត ។

ខែកុម្ភៈ ឆ្នាំ១៩៧៦ អង្គការបានចាត់តាំង ចន ឲ្យទៅទទួលជាលេខាតំបន់៤៣ ។ ពេលនោះ ស្រេង បានណែនាំ ចន ឲ្យធ្វើការទាក់ទងជាមួយឈ្មោះ ងឹន (លេខាតំបន់៤៣) ។ នៅពេលបានជួប ងឹន នៅក្រុងកំពង់ធំ ងឹន បានណែនាំ ចន ឲ្យស្គាល់លេខាស្រុក អនុលេខាស្រុក និងសមាជិកជាង១០នាក់ ដែលជាខ្សែរបស់ខ្លួន ។ ក្រោយមក ចន ក៏បានហៅលេខាស្រុកទាំងអស់ឲ្យមកប្រជុំនៅមន្ទីរតំបន់៤៣ ។ ការប្រជុំនេះ ចន បានណែនាំអំពីភារកិច្ចដែលត្រូវអនុវត្តគឺ ត្រូវយកចិត្តទុកដាក់ពង្រឹងកម្លាំងចាស់ដែលបានកសាងហើយអប់រំ រៀបចំចាត់តាំង ឲ្យមានជាខ្សែសង្វាក់ច្បាស់លាស់នៅតាមស្រុកនីមួយៗ និងត្រូវកសាងកម្លាំងថ្មីបន្ថែមទៀតឲ្យបានច្រើន បង្កប់ក្នុងរដ្ឋអំណាចបដិវត្តន៍ សំខាន់ក្នុងសហករណ៍ និងតាមក្រសួងរបស់ស្រុក ។ ក្រោយមក អង្គការភូមិភាគ បានដាក់ទិសឲ្យលើកប្រព័ន្ធភ្លឺស្រែនៅតំបន់៤៣ និងរៀបចំធ្វើស្ថានីយ៍បូមទឹកនៅក្តីសែន ពេលនោះ ចន បានណែនាំឈ្មោះ គេង លេខាស្រុកកំពង់ស្វាយឲ្យធ្វើសកម្មភាពបំផ្លើសមាគ៌ាអង្គការបានណែនាំ ដោយដកកម្លាំងយកទៅជីកព្រែកនៅស្ទឹងព្រៃប្រស់វិញ ដែលជាហេតុធ្វើឲ្យការកសាងប្រព័ន្ធភ្លឺស្រែ ស្ថានីយ៍បូមទឹក និងប្រឡាយ មិនបានសម្រេចតាមការកំណត់របស់បក្ស និងធ្វើឲ្យមានការប៉ះពាល់ដល់ការដោះស្រាយស្បៀងជូនដល់ប្រជាជនថែមទៀត ។

ក្រោយមក ស្រេង បានមកជួប ចន នៅកំពង់ធំដើម្បីរកកន្លែងពិភាក្សាគ្នា (ប្រជុំ) ។ ចន បានចាត់ វ៉ែន ប្រធានមន្ទីរតំបន់៤៣ ឲ្យទទួលខុសត្រូវក្នុងការរៀបចំកិច្ចការប្រជុំនេះ ។ អង្គប្រជុំក៏បានចាប់ផ្តើមដោយមានអ្នកចូលរួមដែលមានឋានៈ លេខា-អនុលេខាភូមិភាគ លេខាកងពល លេខា-អនុលេខាតំបន់ និងអ្នកមុខអ្នកការផ្សេងទៀតចូលរួមចំនួន២៦នាក់ ។ នៅក្នុងឱកាសនោះ ឈ្មោះ យ៉ា លើកយកខ្លឹមសារចំនួនបីគឺៈ

១) សភាពការណ៍រួមបច្ចុប្បន្ន

២) ផែនការវាយបក្សនៅថ្ងៃបុណ្យខួបនៅខែកញ្ញា ឆ្នាំ១៩៧៦

និងទី៣) បានសង្កត់ធ្ងន់អំពីភារកិច្ចកសាងកម្លាំងឲ្យបានពាសពេញថែមទៀត ។ យ៉ា បានបញ្ជាក់ថា ផែនការវាយបក្ស គឺខាងភ្នំពេញជាអ្នកទទួលខុសត្រូវធ្វើ ដោយមានឈ្មោះ ឌឿន, អឿន និងសួង ជាអ្នកណែនាំអនុវត្តដោយផ្ទាល់ ។ នៅតាមភូមិភាគ និងតំបន់កុំអាលផ្ទុះអាវុធមុនខាងភ្នំពេញ គ្រាន់តែរៀបចំត្រៀមលក្ខណៈសម្បត្តិសិនបានហើយ បើភ្នំពេញផ្ទុះអាវុធហើយ នៅតាមភូមិភាគនិងតំបន់ត្រូវចាប់ផ្តើមផ្ទុះជាបន្តបន្ទាប់ ហើយត្រូវរៀបចំទាក់ទងគ្នាឲ្យជាប់នៅតាមតំបន់នីមួយៗ ។ ចំណែកការកសាងកម្លាំង តាមពិនិត្យទៅឃើញមានចន្លោះប្រហោងច្រើន មិនទាន់ម្ចាស់ការបានទាំងស្រុងនៅឡើយទេ ។ នៅតាមមូលដ្ឋាននីមួយៗ មិនទាន់មានកម្លាំងបង្កប់ស៊ីរូងផ្ទៃក្នុងឲ្យបានពាសពេញនៅឡើយ ។ អង្គប្រជុំបានបញ្ចប់ សមាជិកទាំងអស់ក៏បានបំបែកគ្នា ។ ក្រោយមក អង្គការបានចាត់ ចន ឲ្យទៅធ្វើការនៅភ្នំពេញចំនួនបីថ្ងៃ ដើម្បីប្រជុំពិសោធពិនិត្យផែនការបីគោនមួយហិកតារបស់បក្សក្នុងឆ្នាំ១៩៧៦ ។ នៅពេលនោះ ចន បានធ្វើការទាក់ទងជិតស្និទ្ធជាមួយឈ្មោះ សឿង លេខាកងពលភូមិភាគបស្ចិម, សាន លេខាកងពលភូមិភាគពាយ័ព្យ, វ៉ាញ ប្រធានពាណិជ្ជកម្មភូមិភាគពាយ័ព្យ, ហ៊ីង លេខាតំបន់៥, និងឈ្មោះ យី លេខាតំបន់១០៥ ហើយការទាក់ទងគ្នានេះ មានលក្ខណៈជាបដិវត្តន៍ធម្មតា ។ ជាបន្តបន្ទាប់ ស្រេង តែងតែហៅសមាជិកមកប្រជុំជារឿយៗ ក្នុងការត្រៀមលក្ខណៈវាយបក្សក្នុងខែកញ្ញា ឆ្នាំ

១៩៧៦ ។

ឆ្នាំ១៩៧៧ ឈ្មោះ សាន លេខាកងពលភូមិភាគពាយ័ព្យ បានមកមើលទំនប់១មករា និងបានទៅជួប ចន នៅមន្ទីរភូមិខ្វែក ។ នៅពេលបានជួបគ្នាហើយ សាន បានសួរ ចន ពីសភាពការណ៍នៅភូមិភាគខត្តរតើយ៉ាងណាដែរ? ចន បានប្រាប់ សាន វិញថា អង្គការបានចាប់សមាជិកក្នុងខ្សែអស់មួយចំនួនហើយ ឈ្មោះ ស្រេង ឈ្មោះ គុល និងគណៈស្រុកមួយចំនួនក៏ត្រូវអង្គការចាប់ដែរ រីឯសភាពការណ៍នៅខាងពាយ័ព្យ សាន បានប្រាប់ ចន ថា បានសុខសប្បាយទេ ។ លុះដល់ល្ងាច អ្នកទាំងពីរ បានទៅសម្រាកនៅកំពង់ធំ និងបានពិភាក្សាគ្នាដើម្បីរៀបចំខ្សែទាក់ទង ងាយស្រួលដឹងសភាពការណ៍ពីគ្នាទៅវិញទៅមក ។

ក្នុងខែមេសា អង្គការបានណែនាំ ចន ថា នៅថ្ងៃខាងមុខ អង្គការនឹងចាត់តាំងឈ្មោះ ភោគ ប្រធានសន្តិសុខភូមិភាគ ឲ្យទៅយកមនុស្សដែលអង្គការបានឃាត់ខ្លួននៅសន្តិសុខតំបន់៤៣ មកកាន់កំពង់ចាម ។ បីថ្ងៃក្រោយមក ភោគ បានបើកឡានមួយគ្រឿង និងមានយុទ្ធជនបួននាក់ទៅជាមួយគ្នា ។ ចន បានជួប ភោគ នៅមន្ទីរសន្តិសុខតំបន់៤៣ ហើយក៏បានធ្វើការណែនាំឲ្យ ភោគ ធ្វើសកម្មភាពដោះលែងអ្នកទោសនៅកំពង់ចាមមានឈ្មោះ ឡុន លេខាស្រុកតាំងគោក, ឈ្មោះ ដេន អនុលេខាស្រុកតាំងគោក និងឈ្មោះ ពឹន សមាជិកស្រុកបារាយណ៍ ព្រោះអ្នកទាំងបីជាមនុស្សដែលធ្លាប់មានការជិតស្និទ្ធជាមួយគ្នា (ចន) តាំងពីជំនាន់តស៊ូនយោបាយឆ្នាំ១៩៦៨ មក បើដោះលែងបាន នឹងឲ្យអ្នកទាំងនោះធ្វើសកម្មភាពវាយបក្សជាបន្តបន្ទាប់ ។ ក្រោយពីបានទទួលការណែនាំពី ចន ហើយ ភោគ បានយកផែនការនេះទៅអនុវត្ត តែមិនបានសម្រេចទេ ព្រោះមនុស្សទាំងអស់នេះ ត្រូវអង្គការបញ្ជូនទៅភ្នំពេញអស់ហើយ ។

ក្រោយមក ឈ្មោះ ហង់ លេខាតំបន់១០៣ បានមកជួប ចន, សី និង យី ក្នុងគោលចំណងប្រជុំពិភាក្សាគ្នានៅមន្ទីរតំបន់៤៣ ដើម្បីរៀបចំចាត់តាំងគណៈភូមិភាគខត្តរថ្មីឡើងវិញ ព្រោះងាយស្រួលធ្វើការងារ ។ អង្គប្រជុំបានសម្រេចរើសយកឈ្មោះ សី ធ្វើជាអនុលេខាភូមិភាគ និងជ្រើសរើស ចន ធ្វើជាសមាជិកភូមិភាគ ។ អង្គប្រជុំបានរំសាយ បន្ទាប់ពីបានសម្រេចជ្រើសរើសអនុលេខា និងសមាជិកភូមិភាគរួចមក ។ ពីរថ្ងៃក្រោយ ហង់ បានដឹកនាំការប្រជុំម្តងទៀត មានសមាជិកចូលរួមចំនួន១៣នាក់ ។ ក្នុងពេលប្រជុំ ហង់ បានលើកឡើងថា កន្លងមក គណៈដឹកនាំនៅក្នុងភូមិភាគត្រូវបានអង្គការចាប់ខ្លួនអស់ហើយ ដូច្នេះយើងត្រូវរៀបចំគណៈដឹកនាំសាជាថ្មីឡើងវិញ ។ បន្ទាប់មក ហង់ បានប្រកាសការចាត់តាំងគណៈភូមិភាគមានឈ្មោះៈ

១) ហង់ (លេខាតំបន់១០៣) ជាលេខាភូមិភាគ

២) សី (ប្រធានកងពលភូមិភាគ) ជាអនុលេខាភូមិភាគ

៣) ចន (លេខាតំបន់៤៣) ជាសមាជិកលេខាភូមិភាគ

៤) ទៀង (អនុលេខាតំបន់៤២) ជាសមាជិកលេខាភូមិភាគ

៥) រាប (ប្រធានវរសេនាធំ៦០២) ជាសមាជិកលេខាភូមិភាគ ។

៦) ជ័យ (ប្រធានពាណិជ្ជកម្ម) ជាសមាជិកលេខាភូមិភាគ

៧) ស៊ាន (ប្រធានឧស្សាហកម្ម) ជាសមាជិកលេខាភូមិភាគ

៨) លី (ប្រធានភ័ស្តុភារយោធា) ជាសមាជិកលេខាភូមិភាគ

៩) សោ (ប្រធានគមនាគមន៍) ជាសមាជិកលេខាភូមិភាគ

១០) ញឿង (ប្រធានសង្គមកិច្ច) ជាសមាជិកលេខាភូមិភាគ

១១) ភោគ (ប្រធានសន្តិសុខ) ជាសមាជិកលេខាភូមិភាគ

១២) ឆន (ប្រធានយោធាតំបន់៤៣) ជាសមាជិកលេខាភូមិភាគ ។

១៣) ណែម (ប្រធានគមនាគមន៍តំបន់៤៣) ជាសមាជិកលេខាភូមិភាគ ។

បន្ទាប់ពីបានប្រកាសចាត់តាំងសមាសភាពគណៈភូមិភាគរួចរាល់ហើយ ហង់ បានណែនាំអំពីភារកិច្ចដែលត្រូវអនុវត្តជាបន្តទៅមុខទៀតគឺៈ

១) ត្រូវខិតខំឃោសនា អប់រំប្រជាជននៅតាមមូលដ្ឋាន និងអង្គភាពដែលខ្លួនទទួលខុសត្រូវ បំផុសបង្កជាទំនាស់ បំផុសពីរបបសមូហភាពមានការលំបាក ឯរបបឯកជនមានការងាយស្រួល និងអប់រំ អូសទាញអ្នកដែលមិនពេញចិត្តនឹងបដិវត្តន៍ ។

២) ត្រូវយកចិត្តទុកដាក់កសាងកម្លាំងបង្កប់ស៊ីរូងផ្ទៃក្នុងក្នុងរដ្ឋអំណាចសហករណ៍ យោធា និងក្រសួងនានានៅក្នុងភូមិភាគធ្វើយ៉ាងណា ចាត់តាំងបង្កប់ក្នុងរដ្ឋអំណាចនេះឲ្យបានណែនតទៅទៀត ។

៣) ពេលធ្វើការងារ ត្រូវយកចិត្តទុកដាក់រក្សាការសម្ងាត់ឲ្យបានខ្ពស់បំផុត ។

នៅខែកក្កដា ឆ្នាំ១៩៧៧ ហង់ បានដឹកនាំការប្រជុំមួយទៀត ដើម្បីរៀបចំផែនការវាយឃ្លាំងគ្រាប់នៅកំពង់ចាម ។ នៅក្នុងអង្គប្រជុំដែលមានសមាជិកចំនួន១៣នាក់ចូលរួម ហង់ បានលើកឡើងថា ឈ្មោះ រាប និង លី គឺជាអ្នកការពារនៅឃ្លាំងគ្រាប់ស្រាប់ ឯយុទ្ធជនការពារឃ្លាំងគ្រាប់ក៏សុទ្ធតែជាយុទ្ធជនរបស់ រាប និង លី ទៀត ហេតុនេះ មិនមានការលំបាកក្នុងការវាយកម្ទេចឃ្លាំងគ្រាប់ឡើយសម្រាប់យើង ។ ហង់ បានណែនាំបន្ថែមថា បញ្ហាវាយឃ្លាំងគ្រាប់នេះ យើងធ្វើក្នុងគោលបំណងបំផ្លាញបក្ស ធ្វើយ៉ាងណាកុំឲ្យបក្សមានគ្រាប់ប្រើប្រាស់គ្រប់គ្រាន់ក្នុងការការពារប្រទេស និងធ្វើឲ្យសភាពការណ៍នៅកន្លែងនេះមានភាពច្របូកច្របល់ ធ្វើឲ្យប្រជាជន និងកងទ័ពមានការភ្ញាក់ផ្អើល ប៉ះពាល់ដល់នយោបាយក្នុង និងក្រៅប្រទេស ។ យើងវាយនេះ ក៏ដើម្បីលើកទឹកចិត្តដល់ សេ.អ៊ី.អា ឲ្យឃើញពីជ័យជម្នះរបស់យើង កុំឲ្យយល់តែពីភាពបរាជ័យរបស់ សេ.អ៊ី.អា រាល់លើកពេក ។ បន្ទាប់មក ហង់ បានចាត់តាំងអ្នកដឹកនាំធ្វើសកម្មភាពវាយឃ្លាំងគ្រាប់ ដោយឈ្មោះ សី ទទួលជាប្រធានដឹកនាំរួម រាប ជាអនុប្រធាន និង លី ជាសមាជិក ។ អ្នកទាំងបីមាននាទីដឹកនាំអនុវត្តដោយផ្ទាល់ ដោយកំណត់យកថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ វេលាម៉ោងប្រាំល្ងាច ជាពេលធ្វើសកម្មភាពបំផ្ទុះតែម្តង ។ ចំណែកអ្នកដែលនៅខាងក្រៅ ពេលបានឮស្នូរគ្រាប់ផ្ទុះហើយ ត្រូវនាំគ្នាស្រែកថា យន្តហោះទម្លាក់គ្រាប់បែកចំឃ្លាំងគ្រាប់ហើយៗ ធ្វើយ៉ាងនេះដើម្បីបង្វែងដានកុំឲ្យគេសង្ស័យថាយើងជាអ្នកធ្វើឲ្យផ្ទុះ ។ បន្ទាប់ពីរៀបចំផែនការបំផ្លាញឃ្លាំងគ្រាប់រួចហើយ សមាជិកអង្គប្រជុំក៏បានរំសាយទៅកន្លែងរៀងៗខ្លួន ។

ប្រហែលថ្ងៃទី១៨ ខែសីហា លី និង រាប បានទៅកំពង់ធំរាយការណ៍ប្រាប់ ចន ថា ផែនការដែលគ្រោងនឹងធ្វើនោះ ឥឡូវនេះ មិនបានធ្វើទេ ពីព្រោះ សី ត្រូវបានអង្គការចាប់ខ្លួនហើយ ។ បានទទួលសេចក្តីរាយការណ៍ពីអ្នកទាំងពីរភ្លាម ចន បានទៅសាលានិស្ស័យ ដើម្បីទៅជួប ហង់ និងបានរាយការណ៍ឲ្យ ហង់ បានដឹងពីបញ្ហានេះ ។ ក្រោយពីបានស្តាប់សេចក្តីរាយការណ៍ហើយ ហង់ បានណែនាំទៅ ចន វិញថា ត្រូវណែនាំទៅ លី និង រាប វិញឲ្យរៀបចំអនុវត្តផែនការនេះឲ្យបានដាច់ខាត តែមិនកំណត់យកថ្ងៃណាមួយទេ ឲ្យតែមានឱកាសល្អ គឺអនុវត្តចុះ ។ បានទទួលការណែនាំពី ហង់ ហើយ ចន ក៏បានមកណែនាំដល់ លី និង រាប ដូចដែល ហង់ បានណែនាំខ្លួនយ៉ាងនោះដែរ តែ ចន បានកំណត់យកថ្ងៃដែលត្រូវវាយមានចំនួនបីលើកនៅក្នុងខែកញ្ញា គឺទីមួយវាយថ្ងៃទី៥ ខែកញ្ញា លើកទីពីរកំណត់យកថ្ងៃទី១៧ ខែកញ្ញា និងលើកទីបីកំណត់យកថ្ងៃទី២៥ ខែកញ្ញា ។ ទទួលបានការណែនាំពី ចន ហើយ លី និង រាប បានយកផែនការនេះទៅអនុវត្ត ។

បន្ទាប់ពីបានទទួលការណែនាំអំពីផែនការកម្ទេចឃ្លាំងគ្រាប់នៅកំពង់ចាមពី ចន រួចមក លី, រាប និងបក្ខពួក បានយកផែនការនេះមកអនុវត្ត ដោយយកម៉ើរ៉ា "បូផា" ថ្នាដាក់កីបមីនចុចនឹងថ្មពិលធ្វើឲ្យគ្រាប់ធុន១០៥,៨២ និង៦០ ផ្ទុះនៅក្នុងឃ្លាំង នៅវេលាម៉ោងប្រមាណប្រាំកន្លះនាល្ងាចថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៧ បណ្តាលឲ្យប្រជាជន និងកងទ័ពនៅកន្លែងនោះ មានការភ្ញាក់ផ្អើល និងច្រួលច្របល់យ៉ាងខ្លាំង ព្រោះក្នុងពេលដែលកំពុងផ្ទុះគ្រាប់នៅក្នុងឃ្លាំងនោះ អ្នកនៅខាងក្រៅ បាននាំគ្នាស្រែកថា យន្តហោះទម្លាក់គ្រាប់បែកលើឃ្លាំងគ្រាប់ហើយៗ ។ ការផ្ទុះឃ្លាំងគ្រាប់នេះ បានធ្វើឲ្យប៉ះពាល់ដល់សតិអារម្មណ៍កងទ័ព និងប៉ះពាល់ដល់នយោបាយក្រៅប្រទេសរបស់បក្សយ៉ាងខ្លាំង ព្រោះនៅជិតកន្លែងកើតហេតុនោះ មានកម្មករចិនមកធ្វើការនៅក្នុងរោងចក្រតម្បាញ ដែលអាចធ្វើឲ្យអ្នកទាំងនោះកើតមានការសង្ស័យថា រដ្ឋអំណាចបដិវត្តន៍កម្ពុជា នៅមានសភាពច្របូកច្របល់ ។ រំលងបានពីរថ្ងៃបន្ទាប់ពីថ្ងៃកើតហេតុ គឺនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧ អង្គការក៏បានឃាត់ខ្លួន ចន តែម្តង ។

ចន ត្រូវបានសួរចម្លើយដោយឈ្មោះ សួរ នៅពួក "ក" ។ ចម្លើយសារភាពរបស់ ចន បានសរសេរចប់សព្វគ្រប់នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៧ គឺក្រោយពេលអង្គការចាប់ខ្លួនប្រហែលជាជិតបីខែ ដោយមានចុះហត្ថលេខា និងស្នាមផ្តិតមេដៃរបស់ ចន ផង ។ នៅក្នុងឯកសារ៦ទំព័រចុងក្រោយនៃចម្លើយសារភាព គឺជាបញ្ជីរាយឈ្មោះបក្ខពួករបស់ ចន សរុបមានចំនួន១៣៦នាក់ ដែលក្នុងនោះមានសរសេរឈ្មោះ តួនាទីយ៉ាងច្បាស់លាស់ និងឈ្មោះខ្លះសរសេរថា "ស្លាប់" និងឈ្មោះខ្លះទៀតសរសេរថា "ចាប់" ។ **ឆេង ម៉េង**

# វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀន ប្រវត្ត
# នៅសាលាគរុកោសល្យភូមិភាគ ខេត្តកំព









# សាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ង់ចាម ពីថ្ងៃទី៣-៧ ខែមេសា ឆ្នាំ២០១៧









# យុវជន-យុវនារីបដិវត្តន៍ ត្រូវបំពាក់និស្ស័យគិតគូរ ពិចារណា ទទួលខុសត្រូវខ្ពស់ជានិច្ច ដើម្បីកសាងសង្គមនិយម និងការពារប្រទេសឱ្យបានខ្លាំងក្លាបំផុត

*ដកស្រង់ចេញឯកសារយុវជន និងយុវនារីបដិវត្តន៍លេខ១-២ ខែមករា-កុម្ភៈ ឆ្នាំ១៩៧៧ D២១៣៩៨*

## I.ចំណុចខ្លាំង និងចំណុចខ្សោយរបស់យុវវ័យ

ហៅថាយុវវ័យ គឺចាប់ពីអាយុ១៨ឆ្នាំ រហូតដល់អាយុ៣០ឆ្នាំ ។ ក្នុងចន្លោះពីអាយុ១៨ ទៅ៣០ឆ្នាំនេះ មនុស្សយើងមានធាតុយុវភាពក្លៀវក្លាណាស់ ។ មនុស្សដែលមានអាយុចាប់ពី១៨ឆ្នាំ ទៅទល់នឹង៣០ឆ្នាំ យើងហៅថា យុវជនឬយុវនារី ។ ដូច្នេះ យុវវ័យ គឺជាវ័យមួយដែលខ្លាំងក្លាបំផុត ទាំងរូបរាងកាយ ទាំងសតិបញ្ញា ។ គឺជាវ័យមួយដែលអង់អាចក្លៀវក្លាបំផុតនៃជីវិតមនុស្ស ។ ក្នុងរយៈពេលមុនចូលដល់យុវវ័យនេះ មនុស្សយើងស្ថិតនៅក្នុងវ័យកុមារភាព ។ ក្នុងវ័យកុមារភាពនេះ ទាំងរូបរាងកាយ ទាំងសតិបញ្ញា មនុស្សយើងមិនទាន់មានភាពពេញលេញ បរិបូរនៅឡើយទេ ។ ដូច្នេះ ទាំងកម្លាំងកាយ កម្លាំងចិត្ត ក៏មិនទាន់ខ្លាំងក្លាប៉ុន្មានដែរ ។ ហើយបើហួសពីយុវវ័យនេះទៅ គឺចាប់ពី៣០ឆ្នាំឡើងទៅលើ រូបរាងកាយ



កងចល័តកំពុងលើកប្រព័ន្ធប្រឡាយ នៅក្នុងរបបខ្មែរក្រហម

និងកម្លាំងពលំរបស់មនុស្សយើង ក៏នឹងចុះថមថយវិញជាលំដាប់ ហាក់បីដូចជាថ្ងៃរសៀល ដែលចេះតែជ្រេទន់ទាបទៅ រហូតដល់អស្តង្គតដូច្នេះដែរ ។

សរុបមក ក្នុងជីវិតមនុស្សយើង យើងទាំងអស់គ្នាបានជួបប្រទះនឹងយុវវ័យនេះ តែមួយដងគត់ តែហួសពីរយៈពេលនេះទៅ យើងពុំអាចវិលត្រឡប់មកកាន់យុវវ័យវិញបានឡើយ ។ ដូច្នេះ យុវវ័យនេះ ដែលមនុស្សនៅលើសកលលោកទាំងមូល គេតែងប្រៀបប្រដូចទៅនឹងផ្កាដែលកំពុងរីកស្គុះស្គាយនោះ វាមានតម្លៃជាទីបំផុត ចំពោះយុវជន យុវនារីយើង ។ យុវជន យុវនារីយើង ត្រូវឃើញតម្លៃនៃយុវវ័យនេះ ហើយចេះប្រើយុវវ័យរបស់ខ្លួននេះ ឲ្យមានប្រយោជន៍ដល់កិច្ចការកសាងប្រទេសជាតិ ការពារប្រទេសជាតិ និងបម្រើប្រជាជនឲ្យបានស័ក្តិសិទ្ធិបំផុត ។ ដើម្បីចេះប្រើយុវវ័យនេះ ឲ្យមានប្រសិទ្ធភាពបំផុត យុវជន យុវនារីយើង ត្រូវស្គាល់ចំណុចខ្សោយ និងចំណុចខ្លាំងរបស់ខ្លួនឲ្យបានច្បាស់លាស់ ដើម្បីម៉្យាងជំរុញ និងពង្រឹងពង្រីកអ្វីដែលជាចំណុចខ្លាំងរបស់យុវវ័យ ហើយម៉្យាងទៀត មានវិធានការប្រុងប្រយ័ត្ន ទប់ទល់ និងវាយកម្ចាត់អ្វីដែលជាចំណុចខ្សោយរបស់យុវវ័យ ព្រមទាំងមានវិធានការប្រុងប្រយ័ត្ន បង្ការជាមុនស្រេច កុំឲ្យយុវជន យុវនារីយើងធ្លាក់ខ្លួន ឬផុងខ្លួនទៅក្នុងចំណុចខ្សោយទាំងនេះបាន ។

### ១) ចំណុចខ្លាំងរបស់យុវវ័យ

ក្នុងវ័យនេះ យុវជន យុវនារីយើង មានកម្លាំងកាយខ្លាំងក្លា មាំមួនណាស់ ។ ឯកម្លាំងចិត្តវិញ ក៏អង់អាចក្លៀវក្លាណាស់ដែរ ។ ខាងសតិបញ្ញាក៏វាងវៃភ្លឺថ្លា ឆាប់ក្តាប់ ឆាប់ចាំគ្រប់បញ្ហាទាំងអស់ ។ ដូច្នេះ បើប្រៀបធៀបទៅនឹងវ័យផ្សេងៗទៀត យុវជន យុវនារីយើង អាចទ្រាំទ្រការលំបាកវេទនា ការអត់ឃ្លាន ទ្រាំទ្រនឹងជំងឺដង្កាត់បានខ្លាំងជាងគេ ។ បើទោះបីជាឈឺ ក៏យុវជន យុវនារីយើងឆាប់ជាសះស្បើយ ឆាប់មានកម្លាំងកម្លែងឡើងធ្វើការវិញបាន មិនដូចយូរដូចមនុស្សចាស់ទេ ។

ខាងទស្សនៈគោលជំហរ ក៏យុវជន យុវនារីយើង មិនសូវជាប់ជំពាក់ជំពិននឹងបញ្ហាកម្មសិទ្ធិសួនតួ ជាគ្រួសារ ប្តីប្រពន្ធ កូនចៅ ផ្ទះសម្បែង ស្រែភ្លឺ ភូមិករអ្វីដែរ ។ ដូច្នេះ ក្នុងចលនាតស៊ូបដិវត្តន៍ យុវជន យុវនារីងាយលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីផលប្រយោជន៍រួមរបស់ប្រទេសជាតិ និងផលប្រយោជន៍បដិវត្តន៍ជាងមនុស្សចាស់ ។ ដោយយុវជន យុវនារី មិនសូវមានបញ្ហាជាប់ជំពាក់ជំពិន និងកម្មសិទ្ធិសួនតួ និងដោយយុវជន យុវនារីយើងមានការលះបង់កម្រិតខ្ពស់ ក្នុងការប្រយុទ្ធជាមួយខ្មាំងសត្រូវគ្រប់ប្រភេទ ជាចក្រពត្តិអាណានិគមនិយម ជាវណ្ណៈសក្តិភូមិ វណ្ណៈនាយទុនក្តី យុវជនយុវនារីយើងមានវីរភាពអង់អាចក្លៀវក្លាគ្រប់ពេលវេលា ។ ដូច្នេះគេអាចពុះពារគ្រប់ឧបសគ្គ ប្រយុទ្ធឈ្នះខ្មាំងសត្រូវគ្រប់ប្រភេទបាន ។

ចំណុចខ្លាំងមួយទៀតរបស់យុវជន យុវនារី គឺឆាប់ទទួលនូវធាតុថ្មី ។ បើប្រៀបធៀបទៅនឹងមនុស្សវ័យចាស់វិញ យុវជនយុវនារី ឆាប់ទទួលធាតុបដិវត្តន៍ កាលពីសម័យបដិវត្តន៍ ប្រជាជាតិប្រជាធិបតេយ្យកន្លងមក ក៏ដូចសម័យបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម បច្ចុប្បន្ននេះដែរ ។

### ២) ចំណុចខ្សោយរបស់យុវវ័យ

ក្រៅពីចំណុចខ្លាំងសំខាន់ៗ ទាំងប៉ុន្មានខាងលើនេះ យុវជន យុវនារីយើង ក៏នៅមានចំណុចខ្លាំងជាបន្ទាប់បន្សំផ្សេងទៀតជាច្រើន ។ ប៉ុន្តែ ទន្ទឹមនិងមានចំណុចខ្លាំង ដែលជាលក្ខណៈពិសេសរបស់យុវវ័យទាំងប៉ុន្មានខាងលើនេះ យុវជន យុវនារីយើង ក៏មានចំណុចខ្សោយមួយចំនួន ដែលជាលក្ខណៈពិសេសរបស់យុវវ័យដែរ ។

ចំណុចខ្សោយទី១ របស់យុវវ័យ គឺខ្វះការយល់ដឹងអំពីជីវិតមនុស្សនៅក្នុងសង្គម ដែលមានការវិវត្តបត់បែន ស្មុគស្មាញជាបន្តបន្ទាប់ ខ្វះពិសោធអំពីទំនាស់វណ្ណៈ និងការតស៊ូវណ្ណៈនៅក្នុងសង្គមចាស់ ក៏ដូចជានៅក្នុងសង្គមកម្ពុជាថ្មី ដែលមានតែវណ្ណៈកម្មករ និងវណ្ណៈកសិករបច្ចុប្បន្ននេះ ខ្វះពិសោធក្នុងការតស៊ូជាមួយធម្មជាតិ ក៏ដូចជាក្នុងការងារបច្ចេកទេស វិទ្យាសាស្ត្រ និងការងារកំប៉ិកកំប៉ុកប្រចាំថ្ងៃដែរ ។

ចំណុចខ្សោយទី២ របស់យុវវ័យ គឺមិនសូវចេះ ហើយក៏មិនសូវមានទម្លាប់គិតគូរ ពិចារណារកហេតុផល បច្ច័យល្អអាក្រក់ឲ្យបានវែងឆ្ងាយទេ ។ ធ្វើអ្វីក៏ដោយ គេច្រើនតែសំអាងទៅលើកម្លាំងកាយ ចិត្តរបស់គេដែលខ្លាំងក្លា មាំមួន និងអង់អាចក្លៀវក្លា ជាធម្មជាតិស្រាប់មកហើយប៉ុណ្ណោះ ម្ល៉ោះហើយ គេខ្ជិលគិតគូរ ពិចារ

ណា មើលមុខមើលក្រោយ មើលឆ្វេងមើលស្តាំណាស់ ។ ធ្វើអ្វីក៏ដោយ គេច្រើនចង់ធ្វើឲ្យតែបានហើយឆាប់ៗភ្លាម ។ ម្ល៉ោះហើយរឿងខុសត្រូវ ខូចខាត បាត់បង់ ឬចំណេញខាតយ៉ាងណាៗ យុវជន យុវនារីយើង មិនសូវគិតគូរទេ ។

ចំណុចខ្សោយទី៣ របស់យុវវ័យ គឺការដែលយុវជន-យុវនារី ឆាប់ទទួលធាតុថ្មី ម៉្យាងវាជាគុណសម្បត្តិ វាជាចំណុចខ្លាំងបើទទួលការឃោសនាអប់រំអំពីបដិវត្តន៍ អំពីគំរូល្អ ។ តែផ្ទុយទៅវិញដោយយុវជន យុវនារីយើង មានចំណុចខ្សោយ មិនសូវចេះគិតគូរពិចារណាវែងឆ្ងាយ ហើយដោយមិនសូវមានពិសោធអំពីល្បិចកលក្នុងការតស៊ូវណ្ណៈ និងទំនាស់វណ្ណៈនៅក្នុងសង្គមជាតិផង បើទៅប៉ះធាតុថ្មីមិនល្អ ជាធាតុពាលាអាវ៉ាសែក្តី ជាធាតុប្រឆាំងបដិវត្តន៍ក្តីជាធាតុសេរីក្តី ជាគំរូមិនល្អក្តី ក៏យុវជន យុវនារីយើងឆាប់ឆក់ ហើយក៏ងាយទទួលឥទ្ធិពលមិនល្អទាំងនេះដែរ ។ នេះហើយ ជាគ្រោះថ្នាក់ចំពោះយុវជន យុវនារីយើងទូទៅ ។

នេះជាចំណុចខ្សោយសំខាន់ៗ របស់យុវវ័យដែលយុវជន យុវនារីគ្រប់រូបត្រូវក្តាប់ឲ្យបាន ស្គាល់ខ្លួនឯងឲ្យច្បាស់ កុំអត្តនោម័តិ ។ ហើយព្រមជាមួយនេះ ត្រូវប្រុងប្រយ័ត្នជាប់ជានិច្ច មានវិធានការជាមុនឲ្យស្រេច ក្នុងការរស់នៅក៏ដូចជាក្នុងការតស៊ូវណ្ណៈ និងការបំពេញភារកិច្ចបដិវត្តន៍ប្រចាំថ្ងៃ ធ្វើយ៉ាងណាកុំឲ្យងាករេ ទាំងទស្សនៈ ទាំងគោលជំហរ ទាំងអំពើប្រព្រឹត្តជាក់ស្តែង អំពីមាគ៌ា និងលាក់ការណ៍ផ្សេងៗរបស់បក្សឲ្យសោះ ។ បើយុវជន យុវនារីយើងធ្វើយ៉ាងនេះបានបង្ការ និងទប់ទល់កុំឲ្យធ្លាក់ទៅក្នុងចំណុចខ្សោយទាំងនេះបាន នោះយុវជន យុវនារីយើង ប្រាកដជានឹងខ្លាំង ខ្លាំងទាំងកម្លាំងកាយកម្លាំងចិត្ត ខ្លាំងទាំងទស្សនៈ គោលជំហរ សតិអារម្មណ៍ ។ ដូច្នេះ យុវជន យុវនារីយើង ប្រាកដជានឹងទៅជាអ្នកឈ្នះលើអ្វីៗទាំងអស់ ឈ្នះទាំងខ្មាំងសត្រូវប្រជាជាតិមកពីក្រៅ ឈ្នះទាំងខ្មាំងសត្រូវវណ្ណៈនៅក្នុងសង្គមជាតិ ឈ្នះទាំងទម្លាប់ចាស់និងធាតុមិនបដិវត្តន៍ដែលនៅមានសេសសល់នៅក្នុងខ្លួនយើងទៀត ។ ដូច្នេះយុវជន យុវនារីយើង ប្រាកដជានឹងទៅជាកម្លាំងស្រួច ក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាបច្ចុប្បន្ន និងទៅអនាគតទៀត រហូតដល់ដណ្តើមបានជ័យជម្នះទាំងស្រុង និងជាស្ថាពរ ។

## II.គុណសម្បត្តិ និងការខ្វះខាតរួមរបស់យុវជន យុវនារីយើងក្នុងចលនាបដិវត្តន៍ជាបន្តបន្ទាប់

ជាគុណសម្បត្តិក្នុងចលនាបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យកន្លងមក យុវជន យុវនារីយើង បានលះបង់គ្រួសារ ឪពុកម្តាយ បងប្អូន លះបង់សេចក្តីសុខស្រួលផ្ទាល់ខ្លួន មកចូលរួមក្នុងជួរបដិវត្តន៍ដើម្បីប្រយុទ្ធវាយកម្ទេចខ្មាំងសត្រូវគ្រប់ប្រភេទ ជាចក្រពត្តិអាមេរិកបរិវារ និងពួកអាក្បត់ជាតិ លន់ នល់ សិរិមតៈ ស៊ឺង ង៉ុកថាញ់ រួមរំដោះប្រទេសជាតិ រំដោះប្រជាជន និងរំដោះយុវជន យុវនារីយើងខ្លួនឯងផង ។ លុះចូលមកក្នុងជួរបដិវត្តន៍ហើយ យុវជន យុវនារីយើង បានប្រយុទ្ធទ្រាំទ្រការលំបាកវេទនាសព្វបែបយ៉ាង មានការអត់ឃ្លាន ការឈឺថ្កាត់ ខ្វះថ្នាំសង្កូវ ការខ្វះសម្លៀកបំពាក់ និងសម្ភារប្រើប្រាស់សព្វសារពើទាំងអស់ ។ តែយុវជន យុវនារីបដិវត្តន៍យើង បានប្រយុទ្ធពុះពារគ្រប់ឧបសគ្គ និងការលំបាកវេទនាសព្វបែបយ៉ាង ហើយប្រយុទ្ធវាយសម្រុកយ៉ាងសស្រោកសស្រាំទាំងថ្ងៃទាំងយប់ បម្រើភារកិច្ចបដិវត្តន៍ ទាំងនៅសមរភូមិមុខ ទាំងនៅសមរភូមិក្រោយ សម្រេចជោគជ័យជាបន្តបន្ទាប់ជាប់មិនដាច់ជូនបក្ស ប្រជាជន និងប្រទេសជាតិយើង រហូតដល់សម្រេចជ័យជម្នះទាំងស្រុង និងជាស្ថាពរនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កន្លងទៅនេះ ។ ក្រោយរំដោះទូទាំងប្រទេសហើយ យុវជន យុវនារីបដិវត្តន៍យើង នៅបានបន្តធ្វើពលិកម្មកម្រិតខ្ពស់ទៀត បន្តប្រយុទ្ធស្រួចស្រាវដាច់ខាត ចុះប្រឡូកក្នុងគ្រប់កិច្ចការទាំងអស់ រួមចំណែកស្តារសេដ្ឋកិច្ច កសាងប្រទេស និងការពារប្រទេសយ៉ាងខ្លាំងក្លាសស្រោកសស្រាំ ទាំងថ្ងៃ ទាំងយប់ ទាំងប្រាំង ទាំងវស្សា គ្មានពេលទំនេរ ឬឈប់សម្រាកនៅស្ងៀមឡើយ ។

ក្នុងកិច្ចការពារប្រទេស យុវជន យុវនារីនៃកងទ័ពបដិវត្តន៍យើង បានបន្តធ្វើពលិកម្មគ្រប់បែបយ៉ាង ប្រយុទ្ធនឹងធម្មជាតិអាកាសធាតុ រងារ ត្រជាក់ ក្តៅ និងគ្រុនចាញ់ ប្រយុទ្ធនឹងខ្មាំងសត្រូវគ្រប់ប្រភេទមកពីក្រៅ នៅតាមព្រៃភ្នំក្រំថ្ម ឆ្នេរសមុទ្រ កោះកណ្តាលលំហរសមុទ្រ យ៉ាងអង់អាចក្លៀវក្លាបំផុត ។

ក្នុងកិច្ចការស្តារសេដ្ឋកិច្ចកសាងប្រទេស យុវជន យុវនារីបដិវត្តន៍យើង បានចុះប្រឡូកជាប់ជិតស្និទ្ធជាមួយប្រជាជនកសិករសហករណ៍យើង វាយសម្រុកធ្វើស្រែប្រាំង ស្រែវស្សា ធ្វើចម្ការ

វាយសម្រុកលើកទំនប់ ធ្វើអាងទឹក លើកភ្លឺ ជីកប្រឡាយ ជីកព្រែក ពាសពេញស្រុកស្អុះ ទូទាំងជនបទកម្ពុជាយើង ដើម្បីធ្វើម្ចាស់លើបញ្ហាទឹក ឲ្យបានកាន់តែខ្ពស់ក្នុងការបង្កបង្កើនផល ។ ក្រៅពីនេះ យុវជន យុវនារីបដិវត្តន៍យើង នៅបានចុះប្រឡូកក្នុងមហាចលនាមហាជន ប្រជាជន វាយសម្រុកធ្វើជីធម្មជាតិបានរាប់សែន រាប់លានតោន ដាក់ស្រែ ចម្ការ កែប្រែគុណភាពដី ដោយជោគជ័យ ។ ដូច្នេះ បានជាផលស្រូវយើងឆ្នាំនេះ ល្អជាទូទៅ ។ នៅទូទាំងប្រទេសកម្ពុជាយើង ផលស្រូវក្នុងមួយហិកតា១ ឡើងដល់ពីពីរតោនកន្លះទៅបួន ប្រាំ ប្រាំមួយតោន ។ នេះជាផលស្រូវខ្ពស់បំផុត និងល្អបំផុតដែលពុំធ្លាប់មានទេនៅប្រទេសកម្ពុជាយើងតាំងពីដើមរៀងមក ។

ខាងផ្នែកឧស្សាហកម្ម យុវជនយុវនារីយើង បានចុះប្រឡូកស្តា និងជួសជុលរោងចក្រចាស់ ដែលខូចទាំងប៉ុន្មានឲ្យដំណើរការដោយឯករាជ្យម្ចាស់ការបានវិញទាំងអស់ ព្រមទាំងវាយសម្រុកកសាង និងសង់រោងចក្រថ្មីៗ ថែមបានមួយចំនួនទៀត ។ យុវជនយុវនារីយើង បាន និងកំពុងវាយសម្រុកជំរុញផលិតកម្មឧស្សាហកម្មគ្រប់បែបយ៉ាង ទាំងថ្ងៃទាំងយប់ បម្រើជីវភាពប្រជាជន និងបម្រើកសិកម្ម សម្រេចជោគជ័យធំៗថ្មីទៀតជាបន្តបន្ទាប់ ។

ខាងគមនាគមន៍ដឹកជញ្ជូន យុវជន យុវនារីបដិវត្តន៍យើង បានចុះប្រឡូកវាយសម្រុកជួសជុលផ្លូវថ្នល់ ធ្វើស្ពាន ធ្វើផ្លូវរទេះភ្លើង ជួសជុលកែកុនឡាន កាណូត កប៉ាល់ ក្បាលរទេះភ្លើង ទូរទេះភ្លើងចាស់ៗ ឲ្យដំណើរការវិញបានយ៉ាងឆាប់រហ័ស បម្រើការដឹកជញ្ជូននៅទូទាំងប្រទេស ដោយឯករាជ្យម្ចាស់ការ ។

ខាងផ្នែកសង្គមកិច្ច និងសុខាភិបាល ក៏យុវជន យុវនារីពេទ្យបដិវត្តន៍យើង បានប្រយុទ្ធពុះពារគ្រប់ឧបសគ្គ និងការខ្វះខាតសព្វគ្រប់ ស្រាវជ្រាវ ច្នៃប្រឌិតធ្វើថ្នាំបូរាណ ថ្នាំសម័យបានជាច្រើនមុខ ទុកសម្រាប់ព្យាបាល និងការពារសុខភាពប្រជាជនយើង ដោយជោគជ័យ បានប្រយុទ្ធថែទាំ និងព្យាបាលជំងឺប្រជាជនយើងបានល្អប្រសើរ និងស័ក្តិសិទ្ធិជាអតិបរមា ។ ខាងផ្នែកវប្បធម៌ ឃោសនាអប់រំ នីរសារ ពាណិជ្ជកម្ម ការងារបរទេស ។ល ។ ក៏យុវជន យុវនារីបដិវត្តន៍យើង បានវាយសម្រុកបំពេញភារកិច្ចបដិវត្តន៍របស់



ស្ពានឈើកាត់ប្រឡាយដែលបានសាងសង់ឡើងដោយខ្មែរក្រហម

ខ្លួនយ៉ាងខ្លាំងក្លា សស្រោកសស្រាំ គ្រប់ពេលវេលា មិនថាយប់ឬថ្ងៃឡើយ រួមចំណែកយ៉ាងសកម្ម និងស័ក្តិសិទ្ធិបំផុត ក្នុងកិច្ចការស្តារសេដ្ឋកិច្ច កសាងប្រទេស និងការពារប្រទេស ដោយសន្ទុះមហាលោតផ្លោះ មហាអស្ចារ្យ ។

សរុបមកឃើញថា យុវជន យុវនារីបដិវត្តន៍យើង បានធ្វើពលិកម្មគ្រប់បែបយ៉ាង ប្រយុទ្ធពុះពារ និងជម្នះបាននូវគ្រប់ឧបសគ្គ និងការខ្វះខាតសព្វគ្រប់ រួមប្រឡូកសម្រេចភារកិច្ចបដិវត្តន៍តូចធំធ្ងន់ ស្រាល លំបាក ស្រួល នៅលើគ្រប់សមរភូមិ និងក្នុងគ្រប់រយៈកាលបដិវត្តន៍ ។ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជា យុវជន យុវនារីយើងនេះហើយ ដែលជាកម្លាំងស្រួចឈានមុខ ទាំងខាងកម្លាំងកាយ ទាំងខាងកម្លាំងចិត្ត ទាំងខាងទស្សនៈគោលជំហរ ប្រយុទ្ធស៊ិតស្វាញ លះបង់សព្វបែបយ៉ាងដោយឥតលក្ខខណ្ឌ ទាំងខាងមនោសញ្ចេតនា រួមសម្រេចជ័យជម្នះជាប្រវត្តិសាស្ត្រ ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ កន្លងទៅនេះ ហើយឥឡូវកំពុងរួមចំណែក វាយសម្រុកធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសយ៉ាងខ្លាំងក្លាសស្រោកសស្រាំទាំងយប់ទាំងថ្ងៃ ទាំងប្រាំងទាំងវស្សា ជាបន្តទៀត ។

ទាំងអស់នេះ ជាគុណសម្បត្តិដ៏ច្រើនលើសលប់ និងជាសមត្ថភាពដ៏ខ្ពង់ខ្ពស់របស់យុវជន យុវនារីបដិវត្តន៍យើង ក្នុងចលនាបដិវត្តន៍ដ៏សន្ធោរសន្ធៅ គ្រប់កាលសម័យ ។

ប៉ុន្តែ ទន្ទឹមនឹងគុណសម្បត្តិទាំងប៉ុន្មានខាងលើនេះ យុវជន យុវនារីបដិវត្តន៍យើង ក៏នៅមានការខ្វះខាតមួយចំនួន ដែលជាចំណុចខ្សោយរួមរបស់យុវវ័យយើង ហើយដែលយុវជនយុវនារីបដិវត្តន៍ត្រូវស្គាល់ខ្លួនឯង ត្រូវចាប់អារម្មណ៍ឲ្យខ្ពស់ ហើយត្រូវមានវិធានការវាយកម្ចាត់កែប្រែ និងកែលម្អវាឲ្យបានស័ក្តិសិទ្ធិ និងទាន់ពេលវេលា ដើម្បីរួមវិភាគទានក្នុងមហាចលនាបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសបច្ចុប្បន្ន និងតទៅអនាគតទៀតឲ្យកាន់តែខ្លាំងក្លា និងកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត ។

និយាយរួម យុវជន យុវនារីយើង ដែលស្ថិតក្នុងយុវវ័យច្រើនខ្វះនិស្ស័យ និងទម្លាប់គិតគូរ ពិចារណា ។ និយាយមួយម៉ាត់ យុវជន យុវនារីយើងខ្ជិលគិតគូរណាស់ ធ្វើអ្វីៗក៏ដោយ មិត្តយើងច្រើនតែសម្អាងតែទៅលើកម្លាំងកាយ ។ ម្ល៉ោះហើយ មិត្តយើងច្រើនមានទស្សនៈ ធ្វើអីចង់ធ្វើឲ្យបានឆាប់ ចង់ធ្វើឲ្យបានច្រើន ទៅតាមកម្លាំងកាយ កម្លាំងចិត្ត ដែលមិត្តយើងអាចធ្វើបាន ។ ប៉ុន្តែចំពោះបញ្ហាខុសត្រូវ ខូចខាត បាត់បង់យ៉ាងណាៗ មិត្តយើងពុំសូវនឹកនាដល់ ហើយក៏ពុំបានជាគិតគូរ ឬចាប់អារម្មណ៍ផងទេ ។ ដូច្នេះហើយ បានជាក្នុងគ្រប់កិច្ចការនៅលើសមរភូមិ ជាគុណសម្បត្តិយុវជន យុវនារីបដិវត្តន៍យើង វាយសម្រុកខ្លាំងក្លាណាស់ ធ្វើការច្រើនណាស់ គ្មានដែលត្អូញត្អែរ រអ៊ូរទាំ ឬដាក់លក្ខខណ្ឌអ្វីឡើយ ។ ប៉ុន្តែ បើពិនិត្យជាលទ្ធផលវិញ ពុំធួនល្មមនឹងទុន និងកម្លាំងពលកម្មដែលយុវជន យុវនារីយើងចំណាយនៅឡើយ ។ ឯការខូចខាតបាត់បង់ក៏មានជាបន្តបន្ទាប់ នៅគ្រប់តែដំហានដែរ ។

ឧទាហរណ៍ៈ បក្សណែនាំបំផុសចលនាដាំដុះ ដោយលើកពាក្យស្លោកថា «ដាំដាំដាំ! កុំឲ្យសល់ដីមួយចង្អាម!» ។ មិត្តយុវជន យុវនារីបដិវត្តន៍យើង ក៏វាយសម្រុកដាំដុះទាំងយប់ទាំងថ្ងៃនៅគ្រប់ច្រកល្ហក យ៉ាងខ្លាំងក្លា សស្រោកសស្រាំដូចការណែនាំរបស់បក្សមែន ។ ប៉ុន្តែ ដោយខ្វះការត្រិះរិះពិចារណា តើត្រូវដាំត្រង់ណាទើបបានផល ដាំយ៉ាងម៉េចឲ្យបានល្អ ។ មិត្តយុវជន យុវនារីយើងចេះតែពីដាំ ។ នៅកន្លែងខ្លះ ដាំលើថ្ម លើគ្រួសក៏ដាំ ។ នៅកន្លែងខ្លះទៀត ដាំនៅលើដីជាំទឹកក៏ដាំ ហើយមិនគិតគូរ ថាតើដំណាំអ្វី ដែលអាចដាំលើដីជាំទឹកយ៉ាងនេះបាន ។ នៅកន្លែងខ្លះទៀត គិតតែពីដាំ



កងចល័តត្រឡប់មកពីធ្វើការនៅតាមការដ្ឋាន

ដាំដាំ ។ ដាំបានច្រើនណាស់ តែមិនយកចិត្តទុកដាក់ថែទាំឲ្យហ្មត់ចត់ ពោលគឺដាំចោលៗ ។ សរុបមកវិញ ជាលទ្ធផល កន្លែងខ្លះសូន្យ ។ កន្លែងខ្លះទៀត បានផលដែរ តែតិចតួចស្តួចស្តើងណាស់ មិនសមស្របនឹងទុន ដែលចំណាយទៅឡើយ ។ ដូច្នេះ ធ្វើការដោយមិនគិតគូរពិចារណាបៀបនេះ គឺជាការខ្ជះខ្ជាយធំណាស់ នាំឲ្យខូចខាតបាត់បង់ទាំងពេលវេលា ទាំងកម្លាំងកាយ ទាំងដើមទុន ចោលអសារឥតការ ។ ធ្វើការរបៀបនេះ ទោះបីជាខិតខំវាយសម្រុកខ្លាំងក្លាយ៉ាងណា ក៏មិនបានសម្រេចសំណូមពរវាយសម្រុក មហាលោតផ្លោះ មហាអស្ចារ្យរបស់បក្សដែរ ។ ធ្វើការរបៀបនេះ យើងពុំអាចកសាងសង្គមនិយមបានខ្លាំងក្លា និងឆាប់រហ័យឡើយ ។

ឧទាហរណ៍មួយទៀតៈ បក្សបំផុសមហាចលនាវាយសម្រុកមហាលោតផ្លោះ មហាអស្ចារ្យ ។ យុវជន យុវនារីបដិវត្តន៍យើងប្ដេជ្ញាអនុវត្តពាក្យស្លោកនេះឲ្យបានខ្លាំងក្លាបំផុត និងជាប់ជានិច្ច ។ ម្ល៉ោះហើយ មិត្តយើងខិតខំប្រយុទ្ធបំពេញភារកិច្ចបដិវត្តន៍បានខ្លាំងក្លា សស្រោកសស្រាំ ទាំងយប់ទាំងថ្ងៃ ហើយជំរុញផលិតកម្មសព្វបែបយ៉ាងបានច្រើន និងឆាប់រហ័សទាន់ពេលវេលាតាមសំណូមពររបស់បក្សមែន ។ តែដោយខ្វះការគិតគូរពីបញ្ហាអស់គង់ ចំណេញខាត នៅកន្លែងខ្លះ មិត្តយើងធ្វើបានច្រើនមែន លឿនមែន តែគុណភាពពុំសូវធានាទេ ។ កន្លែងខ្លះទៀត ធ្វើបានច្រើនមែន លឿនមែន ល្អមែន តែត្រូវចំណាយទុនច្រើនណាស់ មិនសមស្របនឹងទំហំការងារ និងទំហំផលិតផលដែលទទួលបានឡើយ ។

ដូច្នេះ របៀបធ្វើការងារ ដោយខ្វះការគិតគូរពិចារណាថ្លឹងថ្លែង អស់គង់ ចំណេញខាតនេះ ទោះធ្វើបានច្រើនយ៉ាងណាក៏ដោយ លឿនយ៉ាងណាក៏ដោយ ល្អយ៉ាងណាក៏ដោយ ក៏មិនមហាលោតផ្លោះ មហាអស្ចារ្យដែរ ។ ដូច្នេះ កសាងសង្គមនិយមមិនបានលឿន មិនបានខ្លាំងក្លាទេ ។

ឧទាហរណ៍ៈ បក្សបំផុសចលនា លើកទំនប់ ជីកប្រឡាយ លើកភ្លឺឲ្យបានច្រើនស្អេកស្កះ ដើម្បីដោះស្រាយបញ្ហាទឹកបង្កបង្កើនផល ។ យុវជន យុវនារីយើង ក៏ខិតខំវាយសម្រុកអនុវត្តការណែនាំរបស់បក្សនេះយ៉ាងខ្លាំងក្លា សស្រោកសស្រាំទាំងយប់ទាំងថ្ងៃ គ្មានគិតគូរដល់ការនឿយហត់ផ្ទាល់ខ្លួនឡើយ ។ មិត្តយើងខំវាយសម្រុកលើកទំនប់ ជីកប្រឡាយ លើកភ្លឺបានច្រើនស្អេកស្កះ ពាសពេញជនបទវាលរាបមែន ។ ប៉ុន្តែ ដោយខ្វះការគិតគូរពិចារណាធ្វើយ៉ាងណាឲ្យសំណង់ចាត់ចែងទឹកទាំងនេះ វាសម្រេចសំណូមពរដោះស្រាយបញ្ហាទឹកបាន ឲ្យតែឃើញថា វាលរាបហើយ មិត្តយើងចេះតែខិតខំលើកភ្លឺ ជីកប្រឡាយ លើកទំនប់ឲ្យតែបានច្រើន ។ ដូច្នេះ ជាលទ្ធផល នៅកន្លែងខ្លះ លើកទំនប់ លើកភ្លឺ ជីកប្រឡាយគ្មានទឹកព្រោះគ្មានប្រភពទឹកនៅជិតនោះ ។ កន្លែងខ្លះទៀត មានទឹកល្មមហើយ តែមិនប៉ះចំលើដីខ្សាច់ ដូច្នេះបង្កើនផលបានពីរដងក្នុងមួយឆ្នាំមែន តែផលតិចជាង បើប្រសិនជាយើងធ្វើនៅលើដីខ្សាច់វិញ ។ល ។

ដូច្នេះឃើញថា របៀបរបបធ្វើការងារ ដោយខ្វះការគិតគូរពិចារណា ទោះបីជាខិតខំវាយសម្រុកខ្លាំងក្លាយ៉ាងណាក៏ដោយ ទោះបីមានសេចក្តីប្ដេជ្ញាចិត្តខ្ពស់យ៉ាងណាក៏ដោយ ក៏ពុំអាចសម្រេចសំណូមពរ ឬសម្រេចទិសដៅបានមួយរយភាគរយដែរ ។ ផ្ទុយទៅវិញ វានាំឲ្យខូចខាតបាត់បង់កម្លាំងកាយ ពេលវេលា និងទុនដើមច្រើនណាស់ ។ ហើយជួនកាល វានឹងនាំឲ្យអន្តរាយដោយសម្រេចផលអីពុំបានទៀតផង ។ ដូច្នេះ ប៉ះពាល់ដល់ចលនាវាយសម្រុកកសាងសង្គមនិយម និងការពារប្រទេស ហើយក៏ប៉ះពាល់ដល់សតិអារម្មណ៍របស់ខ្លួនយើងផ្ទាល់ផង នេះបើក្នុងក្របខណ្ឌការងារ ។ តែបើក្នុងក្របខណ្ឌទស្សនៈគោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍វិញ ផលវិបាកដែលបណ្ដាលមកពីការខ្វះការគិតគូរពិចារណាវែងឆ្ងាយគ្រប់ជ្រុងជ្រោយនេះ និងបណ្ដាលឲ្យមានគ្រោះថ្នាក់កាន់តែធំដុំថែមទៀត ដល់ចលនាបដិវត្តន៍សង្គមនិយម ការកសាងសង្គមនិយម និងកិច្ចការពារប្រទេស ក៏ដូចជាអន្តរាយដល់អាត្មាខ្លួនផ្ទាល់ដែរ ។

កន្លងមក ដោយខ្វះការគិតគូរពិចារណា យុវជន យុវនារីបដិវត្តន៍យើងមួយចំនួន ចាញ់បញ្ឆោតខ្មាំង ចាញ់កលល្បិចខ្មាំង ហើយធ្លាក់ចូលទៅក្នុងអន្ទាក់ខ្មាំងដោយមិនដឹងខ្លួន ដោយអចេតនានាំឲ្យខ្មាំងចាត់តាំងកសាង ទៅជាកម្លាំងក្បត់របស់វាប្រឆាំងបក្សប្រឆាំងបដិវត្តន៍ ហើយធ្វើសកម្មភាពបំផ្លិចបំផ្លាញប្រទេសជាតិ និងប្រជាជនឯងទៅវិញ ។ នេះជាការគួរឲ្យសោកស្ដាយ និងឈឺចាប់ខ្លោចផ្សាបំផុត ។

ឧទាហរណ៍ៈ នៅកន្លែងខ្លះ ខ្មាំងបង្កប់ផ្ទៃក្នុង ឬពួកសមាសភាព

មិនល្អ វាញុះញង់ជំរុញយុវជន យុវនារីយើងឲ្យខុសឆ្គងសីលធម៌ វាបំផុសឲ្យសប្បាយភ្លើតភ្លើន និងស្រីស្រាប្រុសល្បោល ។ ដោយមិនបានគិតគូរពិចារណាវែងឆ្ងាយ អំពីសីលធម៌ស្អាតស្អំល្អបរិសុទ្ធរបស់បដិវត្តន៍ របស់សង្គមកម្ពុជាថ្មីយើងបច្ចុប្បន្ននេះ មិនបានគិតគូរដល់ផលប្រយោជន៍របស់ប្រទេសជាតិ និងប្រជាជនខ្លួន យុវជន យុវនារីយើងក៏លង់ខ្លួន ហើយយល់ភាន់ច្រឡំ ថាការសប្បាយតាមបែបពាលាអាវ៉ាសែ ពុករលួយ នៃរបបជិះជាន់ក្នុងសង្គមចាស់ទាំងនេះ ថាជាការសប្បាយពិតប្រាកដរបស់ខ្លួនមែន ។ ដូច្នេះ ពេលខ្មាំងវាយប្រហារបដិវត្តន៍ វាយប្រហាររបបសង្គមនិយម ថាគ្មានសិទ្ធិសេរីភាព គ្មានការសប្បាយ ។ល ។ មិត្តយើងក៏ជឿតាមវា យល់ស្របដូចវា ហើយក៏វាយប្រហារបដិវត្តន៍ឯង របបសង្គមថ្មីឯង ពោលគឺវាយប្រហារប្រទេសជាតិឯង បដិវត្តន៍ឯង និងប្រជាជនឯង រួមសកម្មភាពប្រឆាំងនឹងបក្ស បដិវត្តន៍ខ្លួន ប្រឆាំងនឹងរដ្ឋអំណាចប្រជាជនខ្លួន ប្រឆាំងនឹងប្រទេសជាតិខ្លួនទៅវិញ ។ ដូច្នេះគឺរួមសកម្មភាពក្បត់ជាមួយខ្មាំងពេញទី ។

ដូច្នេះ គ្រោះថ្នាក់ដល់ចលនាបដិវត្តន៍សង្គមនិយម ការកសាងសង្គមនិយម និងកិច្ចការពារប្រទេស ហើយនិងគ្រោះថ្នាក់ដល់បុគ្គលខ្លួនផ្ទាល់ដែរ ។

ឧទាហរណ៍២ មានយុវជន យុវនារីយើងខ្លះមានការខុសឆ្គងខាងសីលធម៌ ឬខុសឆ្គងបញ្ហាផ្សេងៗ ដែលធម្មតាក្នុងបដិវត្តន៍យើងអាចដោះស្រាយដោយការរៀនសូត្រ ទិតៀន-ស្វ័យទិតៀន ឬឆ្លងជីវទស្សន៍បដិវត្តន៍ ហើយទទួលយកទៅកែប្រែទៅ ក៏បានដែរ ។ តែដោយខ្វះការគិតគូរពិចារណា ឲ្យបានជ្រៅជ្រះ ខ្មាំងឬសមាសភាពមិនល្អដែលបង្កប់នៅក្នុងជួរ វាបំភ័យថាប្រយ័ត្នអង្គការកម្ទេចចោល ហើយវាជំរុញឲ្យរត់ចោលភារកិច្ចបដិវត្តន៍ យុវជន យុវនារីយើងខ្លះក៏ជឿតាមវា ហើយបោះបង់ចោលភារកិច្ចបដិវត្តន៍ទៅតាមការណែនាំរបស់ខ្មាំង ។

ឧទាហរណ៍ទី៣ កន្លងមក ពួកបង្កប់ស៊ីរូងផ្ទៃក្នុង វាធ្វើសកម្មភាពញុះញង់ ចាក់ចុច បំបែកបំបាក់ផ្ទៃក្នុងបដិវត្តន៍យើង ផ្ទៃក្នុងជួរយុវជន យុវនារីបដិវត្តន៍យើង ឲ្យប្រេះឆាបែកបាក់សាមគ្គី ឬឲ្យមានការស្មុគស្មាញក្នុងសតិអារម្មណ៍ជាប់ជានិច្ច ដើម្បីទប់ទល់ រាំងរាកុំឲ្យយុវជនយុវនារីបដិវត្តន៍យើង វាយសម្រុកអនុវត្តភារកិច្ចបដិវត្តន៍របស់ខ្លួនបានខ្លាំងក្លា ។ ដោយខ្វះការពិសោធ និងខ្វះការគិតគូរពិចារណា រកហេតុផលឲ្យបានគ្រប់ជ្រុងជ្រោយ មិត្តយើងខ្លះក៏ចេះតែស្តាប់ ចេះតែជឿពាក្យញុះញង់ អុជអាល ចាក់ដោតរបស់ខ្មាំង ហើយចេះតែស្មុគស្មាញ មន្ទិលសង្ស័យយ៉ាងនេះយ៉ាងនោះទៅលើបក្ស ទៅលើចលនាបដិវត្តន៍ខ្លួន ទៅលើសមូហភាព និងទៅលើសមមិត្តដទៃជាប់មិនដាច់ ។ បើមិត្តយើងស្មោះត្រង់ លើកពាក់ព័ន្ធជំរះសតិអារម្មណ៍ស្មុគស្មាញទាំងនេះ នៅក្នុងសមូហភាពនោះមិនអីទេ គង់អាចរកការពិតឃើញ ។ តែបើស្មុគហើយ មិត្តយើងបៀមទុកមិនបញ្ចេញជូនសមូហភាពដឹងថែមទៀត នោះវានឹងវិវត្តទៅកាន់ភាពស្មុគស្មាញឡើងៗ ។ អ្នកខ្លះធ្លាក់ទៅក្នុងទុទិដ្ឋិនិយមអស់សង្ឃឹម រហូតដល់ធ្វើអត្តឃាតសម្លាប់ខ្លួនឯង ។ អ្នកខ្លះទៀត ឈានទៅថ្នាំងថ្នាក់នឹងបក្ស និងចលនាបដិវត្តន៍ ថ្នាំងថ្នាក់នឹងសមូហភាព ហើយឈានទៅរួមសកម្មភាពជាមួយខ្មាំង វាយប្រហារ និងបំផ្លិចបំផ្លាញបក្ស បដិវត្តន៍ ប្រជាជន និងប្រទេសជាតិឯងវិញ ។ល ។

ដូច្នេះឃើញថា ខាងនិស្ស័យ ទស្សនៈ គោលជំហរ នយោបាយ សតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍ បើគ្មានការគិតគូរត្រិះរិះពិចារណាឲ្យបានវែងឆ្ងាយទេនោះ នឹងនាំឲ្យអន្តរាយធំចំពោះចលនាបដិវត្តន៍ ក៏ដូចជាចំពោះខ្លួនផ្ទាល់ ។

## III.យុវជន យុវនារីបដិវត្តន៍ ត្រូវយកចិត្តទុកដាក់កសាងនិស្ស័យ និងទម្លាប់គិតគូរពិចារណា ទទួលខុសត្រូវខ្ពស់ ក្នុងគ្រប់កិច្ចការងារប្រចាំថ្ងៃ ក៏ដូចខាងនិស្ស័យនយោបាយ សតិអារម្មណ៍ ចាត់តាំង ដើម្បីកសាងសង្គមនិយម និងការពារប្រទេសឲ្យបានរឹងប៉ឹងនិងខ្លាំងក្លាបំផុត

ឃើញបច្ច័យអាក្រក់ និងគ្រោះមហន្តរាយដែលបណ្តាលមកពីការខ្វិលគិតគូរ ថ្លឹងថ្លែង រកហេតុផលខុសត្រូវ ចំណោញខាតយ៉ាងដូច្នេះ ហើយនឹងឈរលើពិសោធខុសឆ្គង នៃចលនាយុវជន យុវនារីយើងកន្លងមក យុវជន យុវនារីបដិវត្តន៍យើងទាំងអស់ចាំបាច់ត្រូវកសាង បំពាក់និស្ស័យគិតគូរពិចារណា ទទួលខុសត្រូវឲ្យខ្ពស់ចំពោះបក្ស បដិវត្តន៍ ប្រជាជន និងប្រទេសជាតិខ្លួន ក្នុងគ្រប់កិច្ចការដែលខ្លួនធ្វើ និងគ្រប់អំពើប្រព្រឹត្តជាក់ស្តែងប្រចាំថ្ងៃ ។ បច្ចុប្បន្ននេះ បក្សដឹកនាំយុវជន យុវនារីបដិវត្តន៍យើង ព្រមទាំងប្រជាជនកម្ពុជាយើងទាំងមូល បន្តធ្វើបដិវត្តន៍សង្គមនិយម កសាង

សង្គមនិយម និងការពារប្រទេស យ៉ាងខ្លាំងក្លាជ្រាលជ្រៅណាស់ ។ ក្នុងរយៈកាលបដិវត្តន៍ថ្មីបច្ចុប្បន្ននេះ ក៏ដូចតទៅអនាគតទៀត ការតស៊ូវណ្ណៈ រវាងប្រជាជាតិ ប្រជាជនកម្ពុជា និងចក្រពត្តិបរទេសគ្រប់ប្រភេទ រវាងប្រជាជនកម្មករ-កសិករកម្ពុជា និងវណ្ណៈនាយទុនសក្តិភូមិ ព្រមទាំងវណ្ណៈជិះជាន់ផ្សេងទៀត ដែលត្រូវរលំរលាយទៅហើយ រវាងបដិវត្តន៍សង្គមនិយម និងរបបនាយទុន រវាងរបបកម្មសិទ្ធិសមូហភាព និងរបបកម្មសិទ្ធិឯកជន ។ល។ មានសភាពតឹងតែងស្មុគស្មាញ និងស្លាប់រស់ជាទីបំផុត ។ ខ្មាំងសត្រូវគ្រប់ទិសទីរបស់យើង វារិះរកគ្រប់វិធី ប្រើគ្រប់កលល្បិច វាយផ្តួលរំលំបដិវត្តន៍សង្គមនិយម ការកសាងសង្គមនិយមរបស់យើង ដើម្បីដណ្តើមយករដ្ឋអំណាច ពីប្រជាជនកម្មករ-កសិករយើងទៅវិញ ។ ដូច្នេះយើងត្រូវតែលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជានិច្ចកុំឲ្យមានប្រហោង កុំភ្លេចភ្លាំង ភ្លើតភ្លើន ធ្លាក់ទៅក្នុងសន្តិភាពនិយមកុំអត្តនោម័តិមើលស្រាលខ្មាំង ថាខ្មាំងមិនអាចធ្វើអីយើងបានឬមើលមិនឃើញខ្មាំង ថាអស់ខ្មាំងហើយឲ្យសោះ ។ និយាយរួមជាយុទ្ធសាស្ត្រ ខ្មាំងត្រូវវិនាសខ្ទាត់ខ្ទាយអស់ជាមូលដ្ឋានហើយ ។ បើប្រៀបធៀបទៅពេលមុន ខ្មាំងខ្សោយជាងមុខឆ្ងាយណាស់ ។ ប៉ុន្តែ បើយើងធ្វេសប្រហែស យើងប្រហោង ខ្មាំងអាចអុកឡុកយើងបាន អាចបំផ្លាញយើងបាន ។ ហើយចំពោះយុវជន យុវនារីយើង ដែលពិសោធក្នុងការតស៊ូវណ្ណៈ ក៏នៅខ្ចីនៅឡើយ បើមិនទម្លាប់គិតគូរពិចារណា ដកពិសោធ និងរកហេតុរកផលឲ្យវែងឆ្ងាយគ្រប់ជ្រុងជ្រោយទេ នោះអាចចាញ់បញ្ឆោតខ្មាំង មើលកលល្បិចខ្មាំងមិនឃើញ ហើយអាចធ្លាក់ទៅក្នុងអន្ទាក់ខ្មាំង នាំឲ្យខ្មាំងចាត់តាំងកសាងទៅជាកម្លាំងក្បត់របស់វាបាន ។ នេះជាគ្រោះមហន្តរាយធំណាស់ ក្នុងកិច្ចការពារប្រទេស ក៏ដូចការកសាងប្រទេសដែរ ។

ក្នុងការកសាងសង្គមនិយមវិញ យុវជន យុវនារីបដិវត្តន៍យើង ក៏ចាំបាច់គិតគូរ ពិចារណា ទទួលខុសត្រូវខ្ពស់ជានិច្ច ចំពោះកិច្ចការដែលខ្លួនធ្វើ ក៏ដូចចំពោះភារកិច្ចបដិវត្តន៍សព្វបែបយ៉ាងដែលខ្លួនទទួលខុសត្រូវដែរ ។ ត្រូវគិតគូរ ថ្លឹងថ្លែង រកហេតុផលខុសត្រូវ ចំណេញខាត អស់គង់ឲ្យបានគ្រប់ជ្រុងជ្រោយ ព្រមទាំងខស្សរាហ៍គិតគូរ ប្រជុំដកពិសោធខុសត្រូវ លើការងារដែលធ្វើកន្លងមក ឲ្យបានជាប់ជានិច្ចដែរ កុំចេះតែធ្វើៗទៅ កុំចេះតែជឿពាក្យចចេកចចូចក្រៅការចាត់តាំងឲ្យសោះ ។ ឥឡូវយើងឈានចូលដល់រយៈកាលធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសជាខ្សែសង្វាក់ហើយ ដើម្បីសម្រេចជ័យជម្នះទាំងស្រុងបាន វាទាមទារឲ្យយុវជន-យុវនារីយើង ត្រិះរិះ គិតគូរពិចារណាទទួលខុសត្រូវខ្ពស់ និងជាប់ជានិច្ច ។ យើងមិនអាចចេះតែធ្វើៗម៉ាស៊ីន ឬដូចកាលសម័យបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យទៀតឡើយ ។

យុវជន យុវនារីយើង មានកម្លាំងកាយ កម្លាំងចិត្ត មានទស្សនៈ គោលជំហរលះបង់ជ្រះស្រឡះ ជំហរវាយសម្រុកប្រយុទ្ធស្រួចស្រាវកម្រិតខ្ពស់ហើយ មានសេចក្តីប្តេជ្ញាចិត្ត ថានឹងបន្តវាយសម្រុកធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសខ្លាំងក្លាបំផុត រហូតដល់សម្រេចបានជ័យជម្នះទាំងស្រុង ។ ដូច្នេះ បើយុវជន យុវនារីយើង បំពាក់និស្ស័យ និងទម្លាប់គិតគូរពិចារណា ទទួលខុសត្រូវឲ្យបានខ្ពស់ថែមទៀត នោះយុវជន យុវនារីបដិវត្តន៍កម្ពុជាយើង ប្រាកដជានឹងក្លាយទៅជាកម្លាំងប្រយុទ្ធឈានមុខ ខ្លាំងក្លាស្រួចស្រាវបំផុត ក្នុងការអនុវត្តភារកិច្ចបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេស ក្នុងឆ្នាំ ១៩៧៧នេះ ឲ្យបានជោគជ័យទាំងស្រុងដាច់ខាត ។ សម្រាប់តទៅអនាគត យុវជន យុវនារីបដិវត្តន៍យើង ក៏នឹងក្លាយទៅជាអ្នកបន្តវេនបដិវត្តន៍ យ៉ាងរឹងប៉ឹងខ្លាំងក្លា ដឹកនាំចលនាបដិវត្តន៍សង្គមនិយម ចលនាកសាងសង្គមនិយម ការពារប្រទេសរហូតដល់សម្រេចជ័យជម្នះបានទាំងស្រុង និងជាស្ថាពរ ។

ដូច្នេះ យុវជន យុវនារីបដិវត្តន៍យើង នឹងក្លាយទៅជាកំពែងថែប ការពារប្រទេស ការពារផលបដិវត្តន៍ ការពារបក្ស ការពារប្រជាជន បានរឹងប៉ឹងខ្លាំងក្លាជារៀងរហូត ទោះបីខ្មាំងសត្រូវណាធំប៉ុណ្ណា មានកលល្បិចពិសពុលខ្មៅងងឹងយ៉ាងណា ក៏ពុំអាចជ្រៀតជើងចូលបាន ក៏ពុំអាចធ្វើអីយើងបានជារៀងរហូត ។

បច្ចុប្បន្ន ក៏ដូចជាតទៅអនាគត បើយុវជន យុវនារីជំនាន់នេះរឹងប៉ឹងខ្លាំងក្លា ទាំងខាងកម្លាំងកាយ កម្លាំងចិត្ត ហើយណែនទាំងខាងទស្សនៈ គោលជំហរនយោបាយ សតិអារម្មណ៍ ចាត់តាំងបដិវត្តន៍ទៀត នោះការកសាងសង្គមនិយមនៅប្រទេសកម្ពុជានិងកិច្ចការពារប្រទេសយើង ប្រាដកជាខ្លាំងក្លាមហាអស្ចារ្យ ហើយលឿនមហាលោតផ្លោះទៀតពុំខានឡើយ ។ **ឆេង ម៉េង**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អ៊ុន សុដាវី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthsodavy.u@dccam.org ។





















# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ ៖ ០០ ព្រឹក*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ ម៉ែន ពិចិត្រ ទូរសព្ទលេខ ៖ ០២៣ ២១៨ ០០៩ អ៊ីម៉ែល ៖ truthmpechet@dccam.org*

# គេហទំព័រទស្សនាវដ្ដីស្វែងរកការពិតជាភាសាខ្មែរ

# www.truthcambodia.com

*ទស្សនាវដ្ដីស្វែងរកការពិត បង្កើតគេហទំព័រ www.truthcambodia.com ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និង សង្គ្រាមជាច្រើនទសវត្សរ៍ ។*

*គេហទំព័រ www.truthcambodia.com ក៏នឹងដើរតួនាទីដ៏សំខាន់ផងដែរក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្ដីក្នុងការរំលែកព័ត៌មានទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះត្រូវបានយកទៅប្រើប្រាស់ជាភស្តុតាងដើម្បីដាក់បន្ទុកមេដឹកនាំខ្មែរក្រហម ។*

*គេហទំព័រ www.truthcambodia.com បែងចែកជា៥ផ្នែកសំខាន់ គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងគេទំព័រ www.truthcambodia.com ក៏មានផ្ទុកនូវឯកសារជាវីដេអូ, សំឡេង, រូបថត និងឯកសារដើមរបស់ខ្មែរក្រហមដែរ ។*

*អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើងដោយស្ទេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអាន គឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថា តើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រឹតឡើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលធ្វើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណា ដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្ដល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិត ជាដើម ។ល ។ ផ្នែកទី៥) គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬ បាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្ដិ សាច់សារលោហិតដែលបានស្លាប់ដោយសាររបបខ្មែរក្រហម ។ ជាទំព័រឈឺចាប់ អាណោចអាធ័ម ប៉ុន្តែក៏ជាទំព័ររម្ងាប់ការមន្ទិលសង្ស័យ ដើម្បីសេចក្ដីសុខក្នុងខ្លួនជាអមតៈដែរ ។*

*សរុបសេចក្ដីទៅផ្នែកទាំង៥ ខាងលើនៃគេហទំព័រ www.truthcambodia.com នឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ។ គេហទំព័រ www.truthcambodia.com នឹងបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រ www.truthcambodia.com សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរសព្ទសម្រាប់ធ្វើសេចក្ដីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទ មុនការចេញផ្សាយ ។*

*គេហទំព័រ www.truthcambodia.com សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែ គេទំព័រ www.truthcambodia.com នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។*

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបានប្រកាសសាលក្រមលើកទីមួយកាលពីខែសីហា ឆ្នាំ២០១៤ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូ សវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការ និងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់ សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញ និងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី "សហកម្មខុក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "*Join Criminal Enterprise*" ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម "ផែនការឧក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "*Common Criminal Plan*" ។ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេ ដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។ **វ៉ាន់ថាន់ ពៅដារ៉ា**

# ថ្ងៃដែលយើងមិនត្រូវបំភ្លេច

ដើម្បីដោះស្រាយពីស្ថានភាពក្រោយជម្លោះនៅប្រទេសកម្ពុជា បុគ្គល រដ្ឋ សង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀតបានពិនិត្យពិចារណាទៅលើកត្តាវប្បធម៌ សាសនា នយោបាយ និងបរិបទផ្សេងៗ ។ កិច្ចខិតខំប្រឹងប្រែងរបស់អ្នកទាំងអស់នេះបានចូលរួមបម្រើគោលបំណងនៃការថែរក្សាការចងចាំ ការពិត និងយុត្តិធម៌ ។

ប៉ុន្តែថ្ងៃព្រហស្បត្តិ៍ ទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលជាចំណុចរបត់ប្រកបដោយសោកនាដកម្មក្នុងប្រវត្តិសាស្ត្រកម្ពុជាពុំសូវទទួលបានការចាប់អារម្មណ៍ខ្លាំងទេ ។

នៅថ្ងៃនោះ មានក្រុមមនុស្សដែលប្រកាន់យកលទ្ធិម៉ៅបែបជ្រុលនិយម ដែលត្រូវបានស្គាល់ថាជា “ក្រុមខ្មែរក្រហម” បានវាយចូលក្នុងទីក្រុងភ្នំពេញ ហើយរបបលន់ នល់បានចុះចាញ់ ។

ពីដំបូង ប្រជាជនរស់នៅទីក្រុងជាច្រើនបានបង្ហាញពីភាពសប្បាយរីករាយ ដោយសារអ្នកទាំងនោះបានគិតថា សង្គ្រាមត្រូវបានបញ្ចប់ ហើយជំនួសវិញដោយសន្តិភាព សុវត្ថិភាព និងការកសាងជាតិឡើងវិញនៅទូទាំងប្រទេសកម្ពុជា ។ តែទោះយ៉ាងណា ភាពសប្បាយរីករាយនេះត្រូវជំនួសវិញភ្លាមៗ ដោយភាពភ័យខ្លាច ភាពជ្រួលច្របល់ និងភាពរន្ធត់ចិត្ត ។

ក្នុងថ្ងៃដដែលនោះដែរ ខ្មែរក្រហមបានចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានាទៅកាន់តំបន់ជនបទ ។ ការជម្លៀសដោយបង្ខំនេះគួបផ្សំជាមួយនឹងគោលនយោបាយដទៃទៀតរបស់ខ្មែរក្រហម បានបង្កឲ្យប្រជាជនកម្ពុជាជិតពីរលាននាក់ស្លាប់បាត់បង់ជីវិត ។


យោធាខ្មែរក្រហមបានដើរចូលទីក្រុងភ្នំពេញ បន្ទាប់ពីទទួលជ័យជម្នះលើរបប លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

រយៈពេលបីទសវត្សរ៍ក្រោយមក ការស្វែងរកការផ្សះផ្សាក្នុងប្រទេសកម្ពុជានៅតែជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងប្រជាជន ។

អ្នករស់រានមានជីវិតភាគច្រើនចាត់ទុកថ្ងៃទី៧ ខែមករា ថាជាថ្ងៃដែលខ្លួនត្រូវបានរំដោះពីរបបខ្មែរក្រហម ហើយទទួលបានសិទ្ធិមូលដ្ឋាន និងសេរីភាពរបស់ខ្លួនមកវិញ ។ ស្របគ្នានេះ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០ រដ្ឋាភិបាលកម្ពុជាតែងតែប្រារព្ធពិធីអបអរសាទរជ័យជម្នះថ្ងៃ ៧មករា ។ ទោះជាយ៉ាងនេះក្តី ក្រុមអ្នករិះគន់បានអះអាងថា តាមការពិត ថ្ងៃ៧ មករា គឺជាថ្ងៃដ៏អាម៉ាស់ ហើយថ្ងៃនោះ គឺជាថ្ងៃដែលកងទ័ពវៀតណាមបានឈ្លានពានប្រទេសកម្ពុជា និងបានកាន់កាប់ប្រទេសនេះអស់រយៈពេលមួយទសវត្សរ៍ទៅវិញទេ ។

ទោះបីជាមានការយល់ឃើញខុសគ្នាក៏ដោយ កិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយបញ្ហានៃសម័យកម្ពុជាប្រជាធិបតេយ្យផ្អែកទៅលើទិដ្ឋភាពច្បាប់វិញ ត្រូវបានធ្វើឡើងចាប់តាំងពីក្រោយការដួលរលំនៃរបបខ្មែរក្រហមមកម្ល៉េះ ។ នៅខែសីហា ឆ្នាំ១៩៧៩ ការបង្កើតឡើងនូវតុលាការប្រជាជនបដិវត្តន៍បានក្លាយជាកិច្ចខិតខំប្រឹងប្រែងផ្នែកច្បាប់ដំបូងបំផុត ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមចំនួនពីររូប ។ បើទោះបីជានីតិវិធីនៃដំណើរការតុលាការនេះហាក់មានភាពមន្ទិលសង្ស័យក៏ដោយ ដំណើរការរបស់តុលាការនេះពិតបានជួយពង្រឹងស្មារតីរបស់ប្រជាជនកម្ពុជា ។

លើសពីនេះទៅទៀត តុលាការប្រជាជនបដិវត្តន៍បានរួមចំណែកយ៉ាងធំធេងចំពោះប្រព័ន្ធយុត្តិធម៌តាមរយៈ "ញត្តិ" ចំនួនមួយលានប្រាំមួយសែន ដែលប្រជាជនបានធ្វើនៅចន្លោះឆ្នាំ១៩៨៣ និងឆ្នាំ១៩៨៤ ។

ឯកសារដែលត្រូវបានស្គាល់ថាជា ញត្តិរណសិរ្ស គឺជាកិច្ចខិតខំប្រឹងប្រែងរបស់ជនរងគ្រោះដើម្បីសម្តែងចេញ និងដោះស្រាយការឈឺចាប់របស់ខ្លួន និងដើម្បីបង្ហាញពីសារសំខាន់ក្នុងការកសាងសំណុំរឿងក្តីខាងផ្លូវច្បាប់ទៅលើមេដឹកនាំខ្មែរក្រហមសំខាន់ ។

មានទម្រង់នៃការចងចាំជាច្រើនទៀតត្រូវបានផ្តួចផ្តើមឡើងលើសពីវេទិកាផ្លូវច្បាប់នេះទៅទៀត ។ ឧទាហរណ៍ ដើម្បីជាការគោរពដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់បាត់បង់ជីវិត រដ្ឋាភិបាលបានគាស់ និងថែរក្សាអដ្ឋិធាតុ ដែលបានមកពីរណ្តៅសាកសពរួមប្រមាណជិតពីរម៉ឺនរណ្តៅនៅចន្លោះឆ្នាំ១៩៨២ដល់ឆ្នាំ២០០៧ ខណៈដែលបូជនីយដ្ឋានជាង៨០កន្លែងត្រូវបានកសាងឡើងចាប់តាំងពីឆ្នាំ១៩៨៦ ដោយបង្កលទ្ធភាពជូនសាធារណជនប្រារព្ធពិធីសាសនានានា និងដើម្បីឧទ្ទិសកុសលជូនអ្នកដែលបានបាត់បង់ជីវិតឲ្យបានទៅកាន់សុគតិភព ។

បន្ថែមពីនេះទៀត សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដែលត្រូវបានបង្កើតឡើងនាដើមទសវត្សរ៍ឆ្នាំ១៩៨០ បានក្លាយទៅជាផ្នែកដ៏សំខាន់មួយនៃកេរដំណែលដែលជួយស្តារឡើងវិញនូវការចងចាំរបស់អ្នកនៅរស់រានមានជីវិតពីសម័យកម្ពុជាប្រជាធិបតេយ្យ ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះគឺជាសកម្មភាពដ៏សំខាន់នៃការរំឭកឡើងវិញពីព្រឹត្តិការណ៍ក្នុងរបបខ្មែរក្រហម ដែលមិនជាប់ទាក់ទិននឹងដំណើរការផ្នែកច្បាប់ ។

ទិវានៃការរំឭក និងការចងចាំត្រូវបានបន្តប្រារព្ធក្នុងបរិបទនេះដដែល ។ "ទិវាចងកំហឹង" ដែលប្រារព្ធឡើងនៅស្តូបរំឭកវិញ្ញាណក្ខន្ធក្នុងថ្ងៃទី២០ ខែឧសភា បានជួយឲ្យអ្នកនៅរស់រានមានជីវិត រស់នៅដោយស្ងប់ចិត្តជាមួយអតីតកាលរបស់ខ្លួន និងទទួលបានការផ្សះផ្សា ។ នៅក្នុងឆ្នាំ២០០៩ ទិវាចងកំហឹងត្រូវបានប្តូរឈ្មោះទៅជា "ទិវានៃការចងចាំ" វិញ ។

នៅចន្លោះឆ្នាំ១៩៧៩ ដល់ចុងទសវត្សរ៍ឆ្នាំ១៩៨០ រដ្ឋាភិបាលបានធ្វើការផ្តោតសំខាន់ទៅលើការបញ្ចប់សង្គ្រាមស៊ីវិល និងនាំយកចលនាតស៊ូខ្មែរក្រហម និងភាគីដែលប្រឆាំងនឹងរដ្ឋាភិបាលនានាៗ មករួបរួមនៅក្នុងសង្គមជាតិវិញ ។ កម្មវិធីវិទ្យុដែលមានឈ្មោះថា "សំឡេងអំពាវនាវ" ត្រូវបានរៀបចំឡើងក្រោមកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីសម្រេចគោលដៅនេះ ។ កិច្ចខិតខំប្រឹងប្រែងនេះត្រូវបានបន្ត ហើយនៅចន្លោះឆ្នាំ១៩៨៤ ដល់ឆ្នាំ១៩៩៨ រដ្ឋាភិបាលបានព្យាយាមរំលាយរចនាសម្ព័ន្ធចាត់តាំងរបស់ខ្មែរក្រហមតាមរយៈការចរចា ។ ក្រុមអ្នកផ្តាច់ខ្លួនជាមួយរាជរដ្ឋាភិបាលដ៏ច្រើន បានធ្វើឲ្យកម្លាំងខ្មែរក្រហមត្រូវបានចុះខ្សោយ ។

ទោះជាយ៉ាងនេះក្តី កិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលគ្រប់ភាគីជម្លោះទាំងអស់បានឯកភាពកាលពីខែតុលា ឆ្នាំ១៩៩១ គឺជា

ដំណើរវិវឌ្ឍជាវិជ្ជមានបំផុតនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីកងកម្លាំងវៀតណាមបានដកចេញពីកម្ពុជា ។ កេរដំណែលនៃកិច្ចព្រមព្រៀងនេះមានភាពជាក់ស្តែងយ៉ាងខ្លាំង ហើយលទ្ធិប្រជាធិបតេយ្យក្រោមទម្រង់នៃការបោះឆ្នោតត្រូវបានអនុវត្តជាបន្តបន្ទាប់ចាប់តាំងពីពេលនោះមក ។

ឆ្នាំ១៩៩៧គឺជាឆ្នាំដែលប្រទេសកម្ពុជាបានងាកទៅរកបែបបទដំបូងក្នុងការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ នៅពេលដែលរាជរដ្ឋាភិបាលបានស្នើឲ្យអង្គការសហប្រជាជាតិកាត់ទោសជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិមនុស្សធ្ងន់បំផុត ដែលបានប្រព្រឹត្តចន្លោះ ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ។ ជាលទ្ធផល អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៣ ។ ដំណើរការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមដែលនៅរស់រានមានជីវិតត្រូវបានប្រព្រឹត្តឡើង ដោយបានកាត់ទោសមេដឹកនាំខ្មែរក្រហមចំនួនបីរូបឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ សាលក្រមរបស់ កាំង ហ្គិកអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានមន្ទីរសន្តិសុខស-២១ ក្នុងសំណុំរឿង០០១ ត្រូវបានប្រកាសក្នុងឆ្នាំ២០១០ ចំណែកសាលក្រមរបស់ នួន ជា ដែលជាអតីតប្រធានសភាតំណាងប្រជាជន និង ខៀវ សំផន ដែលជាអតីតប្រមុខរដ្ឋ ក្នុងសំណុំរឿង០០២ ត្រូវបានប្រកាសក្នុងឆ្នាំ២០១៤ ។

ជាការពិតណាស់ អង្គការសង្គមស៊ីវិលក៏បានដើរតួយ៉ាងសំខាន់នៅក្នុងដំណើរការនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាអង្គការមិនរកប្រាក់ចំណេញ បានដើរតួយ៉ាងសំខាន់ក្នុងការបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការផ្សះផ្សា ។ គម្រោងនាំមុខចំនួនប្រាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានដូចតទៅៈ

សៀវភៅរំឭកវិញ្ញាណក្ខន្ធរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាសៀវភៅមួយដែលបានចងក្រងឈ្មោះរបស់អ្នកដែលបានស្លាប់បាត់បង់ជីវិតក្នុងសម័យខ្មែរក្រហម ឬអ្នកដែលបានបាត់ខ្លួន


ប្រជាជនត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះសម្បែង ដោយយោធាខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៩ ។

ក្នុងជិតាន់នោះ ។ សៀវភៅនេះនឹងត្រូវចែកចាយទៅកាន់តំបន់នានានៅក្នុងប្រទេសកម្ពុជា ហើយឈ្មោះរបស់ជនរងគ្រោះនឹងត្រូវដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដែលប្រជាជននៅទូទាំងសកលលោកអាចចូលមើលទិន្នន័យនេះបាន ។

គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ជាសញ្ញាណនៃកិច្ចខិតខំប្រឹងប្រែងក្នុងជំរុញឲ្យមានការផ្សះផ្សាដែរ ។ ចាប់តាំងពីឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសុះស្វែងផ្សព្វផ្សាយប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ទៅកាន់សិស្សានុសិស្សកម្ពុជាតាមមធ្យោបាយជាច្រើន ។ យន្តការដ៏មានសារសំខាន់មួយក្នុងការចែករំលែកប្រវត្តិសាស្ត្រនេះគឺ តាមរយៈសៀវភៅស្តីពីរបបខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" ។

ក្នុងពេលថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យអស់ចំនួន៥សែនក្បាល និងបានបណ្តុះបណ្តាលគ្រូប្រវត្តិសាស្ត្រចំនួន៣ពាន់នាក់ដើម្បីបង្រៀនអំពីប្រវត្តិសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព និងស្របទៅតាមគោលដៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

គម្រោងដ៏សំខាន់មួយទៀតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺក្រុមការងារស្តីពីការចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ គម្រោងនេះផ្តោតលើការជឿជាក់ថា ការអប់រំពីអំពើប្រល័យពូជសាសន៍អាចប្រើប្រាស់ជាមូលដ្ឋានគ្រឹះសម្រាប់ការបង្កើតគណៈកម្មាការដើម្បីស្វែងរកការពិត និងការផ្សះផ្សាដែលកាន់តែមានភាពជាផ្លូវការ និងគ្រប់ជ្រុងជ្រោយ ហើយសមស្របទៅនឹងបរិបទដ៏ទូលំទូលាយក្នុងការផ្សះផ្សានៅប្រទេសកម្ពុជា ។

ការថែរក្សាតំបន់ប្រវត្តិសាស្ត្រអន្លង់វែងបានក្លាយជាដំណើរការវិវឌ្ឍដ៏សំខាន់ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ កាលពីខែមីនា ឆ្នាំ២០១០ រាជរដ្ឋាភិបាលបានចេញអនុក្រឹតស្តីពីការអភិរក្សតំបន់ប្រវត្តិសាស្ត្រនៅអន្លង់វែង ហើយបានប្រគល់ភារកិច្ចជូនដល់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការសិក្សាស្រាវជ្រាវពីតំបន់នេះ ។ នៅក្នុងឆ្នាំ២០១៥ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងត្រូវបានបង្កើតឡើង ដែលក្នុងនោះរួមមានបណ្ណាល័យសាធារណៈមួយ ហើយមជ្ឈមណ្ឌលនេះបានក្លាយជាទីតាំងសិក្សាស្រាវជ្រាវ និងអប់រំសម្រាប់សិស្សនិស្សិត និងអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ ។ ការងារនេះនឹងធ្វើឲ្យតំបន់អន្លង់វែងក្លាយជាប្រភពធនធាន លេចធ្លោមួយសម្រាប់រំឭកការចងចាំពីអតីតកាល ក៏ដូចជាទាក់ទាញចំណាប់អារម្មណ៍ទៅលើទិដ្ឋភាពដ៏ស្រស់ត្រកាលរបស់តំបន់នេះទៀតផង ។

គម្រោងនាំមុខចុងក្រោយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែអនុវត្តនោះគឺ វិទ្យាស្ថានស្លឹករឹត ។ ចាប់តាំងពីឆ្នាំ២០១១ មជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រែខ្លួនទៅជាវិទ្យាស្ថានស្លឹករឹតដែលមានគោលបំណងក្នុងការដើរតួជាចំណុចកណ្តាលនៃការសិក្សាពីអំពើប្រល័យពូជសាសន៍នៅក្នុងតំបន់អាស៊ី ។

កិច្ចខិតខំប្រឹងប្រែងទាំងឡាយដែលបានលើកឡើងខាងលើនេះ បានបង្កើតជាដំណើរដ៏ចម្បងក្នុងការជួយព្យាបាលរបួសផ្លូវចិត្តរបស់ប្រជាជនកម្ពុជាចាប់តាំងពីខែមករា ឆ្នាំ១៩៧៩ មកម្ល៉េះ ។ ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែងទាំងនេះ និងភាពមិនងាយទ្រុឌទ្រោមរបស់ប្រជាជនកម្ពុជាទេ ជំងឺសង្គមនេះនឹងនៅតែបន្តញាំញីប្រជាជនកម្ពុជាជារៀងរាល់ថ្ងៃជាក់ជាពុំខានឡើយ ។

កិច្ចខិតខំប្រឹងប្រែងទាំងនេះមានសារប្រយោជន៍ខ្លាំងណាស់ ហើយមានគោលដៅសំខាន់មួយ ដោយសារតែកិច្ចការទាំងនេះបានជំរុញយើងទាំងអស់គ្នាឲ្យគិតពីចំណុចចាប់ផ្តើម ព្រមទាំងកត្តានៃការបាត់បង់ និងឈឺចាប់យ៉ាងធំធេងទាំងនេះ ពោលគឺថ្ងៃទី១៧ ខែមេសា ។ **លី សុខឃាង**

## អានទស្សនាវដ្តីតាមគេហទំព័រ

*ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។*

# ការដាក់តាំងពិព័រណ៍ស្តីពី «ការជម្លៀសប្រជាជន ឆ្នាំ១៩៧៥-១៩៧៩» នៅសាលាគរុកោសល្យភូមិភាគ









# ះដោយបង្ខំ ពីឆ្នាំ១៩៧៥-១៩៧៩» និង «ភ្នំពេញ ខេត្តកំពង់ចាម កាលពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៧











# វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានស្តីអំពីការបង្រៀន ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

កាលពីដើមខែមេសា ឆ្នាំ២០១៧ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំវគ្គបណ្តុះបណ្តាលស្តីអំពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យលើកទី១៧ ចំនួន៩ថ្ងៃ ជាមួយគ្រូមូលដ្ឋានដែលបង្រៀននៅតាមអនុវិទ្យាល័យ និងវិទ្យាល័យនានាចំនួន១០៧នាក់ ដែលក្នុងនោះសិក្ខាកាមចំនួន៤០នាក់ជាស្ត្រី ។ សិក្ខាកាមទាំងនោះបានធ្វើដំណើរមកពីខេត្តចំនួន៦ រួមមាន ខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី ។ កម្មវិធីបណ្តុះបណ្តាលនេះរៀបចំឡើងនៅក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម និងជាផ្នែកមួយនៃគម្រោងសំណងជំងឺចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណី និង ជនរងគ្រោះសម័យខ្មែរក្រហមរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលទទួលបានការឧបត្ថម្ភពីសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា (EU) និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ។

កម្មវិធីបណ្តុះបណ្តាលនេះ រៀបចំឡើងក្នុងគោលបំណងផ្តល់ធនធាន និងចំណេះដឹងបន្ថែម ដល់លោកគ្រូអ្នកគ្រូស្តីអំពីការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យ ដើម្បីជំរុញឲ្យការបង្រៀនរបស់គាត់កាន់តែមានប្រសិទ្ធភាពតាមរយៈការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការធ្វើបទបង្ហាញអំពីវិធីសាស្ត្របង្រៀនផ្សេងៗ ព្រមទាំងការចូលរួមផ្តល់បាឋកថាទៅលើប្រធានបទផ្សេងៗពីសំណាក់វាគ្មិនជាតិ និងអន្តរជាតិ អំពីទំនាក់ទំនងការបរទេសរបស់ខ្មែរក្រហម និងចំណេះ



វគ្គបណ្តុះបណ្តាលស្តីអំពីការបង្រៀន "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩)" លើកទី១៧ ចំនួន៩ថ្ងៃ ពីថ្ងៃទី៣-៧ ខែមេសា ឆ្នាំ២០១៧ ដល់គ្រូមូលដ្ឋានដែលបង្រៀននៅតាមអនុវិទ្យាល័យ និងវិទ្យាល័យនានា ចំនួន១០៧នាក់ មកពីខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី នៅក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ។

ដឹងដែលទាក់ទងនឹងការប៉ះទង្គិចផ្លូវចិត្តបន្ទាប់ពីរបបខ្មែរក្រហម ។ ទន្ទឹមនឹងនោះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីដែលបានប្តឹងទៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមចូលរួមចែករំលែកបទពិសោធន៍របស់គាត់ដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមទៅដល់សិក្ខាកាមទាំងអស់ ។

បើយោងតាមបទសម្ភាសន៍ជាមួយ លោក សេង ស៊ឹម នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ដែលមានទីតាំងនៅក្នុងទីរួមខេត្តកំពង់ចាម មានប្រសាសន៍ថា មជ្ឈមណ្ឌលនេះគឺជាអតីតសាកលវិទ្យាល័យភូមិន្ទកំពង់ចាម ដែលបង្កើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ ប៉ុន្តែ សាកលវិទ្យាល័យនេះត្រូវបានបិទទ្វារនៅក្នុងរបបខ្មែរក្រហម ។ បន្ទាប់មក នៅឆ្នាំ១៩៨៩ សាកលវិទ្យាល័យនេះត្រូវបានប្រើប្រាស់ឡើងវិញជាមជ្ឈមណ្ឌលគរុកោសល្យមកទល់នឹងសព្វថ្ងៃ ។

នៅក្នុងវគ្គបណ្តុះបណ្តាលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានដាក់តាំងពិព័រណ៍ស្តីអំពី «ទីក្រុងភ្នំពេញ ៖ ឆ្នាំ១៩៧៥-១៩៧៩» ចំនួន១៤ផ្ទាំង នៅក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ដែលរំឭកដល់ទីក្រុងភ្នំពេញ និងកិច្ចខិតខំប្រឹងប្រែងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងការកសាង និងស្តាប្រទេសកម្ពុជាឡើងវិញ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា សង្ឃឹមថាពិព័រណ៍នេះនឹងរម្លឹកដល់គរុសិស្សដែលសិក្សានៅទីនោះ ព្រមទាំងសាធារណជនអំពីរបបខ្មែរក្រហម ។

បន្ទាប់ពីការបណ្តុះបណ្តាលអស់រយៈពេលប្រាំថ្ងៃ សិក្ខាកាមដែលចូលរួមវគ្គបណ្តុះបណ្តាលនេះហាក់ដូចជាទទួលបានចំណេះច្រើនជាងមុនទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម និងវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល ។ ខាងក្រោមនេះ គឺជាមតិយោបល់របស់សិក្ខាកាមមួយចំនួន ដែលបានចូលរួមវគ្គបណ្តុះបណ្តាល ៖

អ្នកគ្រូ ហ៊ោ រីយ៉ា អាយុ៣៥ឆ្នាំ មកពីខេត្តកំពង់ចាម ៖ ខ្ញុំចាប់ផ្តើមបង្រៀនតាំងពីឆ្នាំ២០០២ មកម៉្លេះ ។ ខ្ញុំបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យាដល់សិស្សថ្នាក់ទី១២ នៅវិទ្យាល័យ ហ៊ុន សែន ចម្ការលើ ។ ម្តាយរបស់ខ្ញុំធ្លាប់និយាយប្រាប់ខ្ញុំថា ក្រុមគ្រួសាររបស់គាត់មួយចំនួនត្រូវបានខ្មែរក្រហមសម្លាប់ ដោយសារតែខ្មែរក្រហមរកឃើញថា ឪពុករបស់ម្តាយខ្ញុំធ្លាប់ធ្វើការនៅក្រសួងការបរទេសមុនសម័យខ្មែរក្រហម ។ ផ្ទះរបស់គាត់នៅក្បែរវត្តភ្នំ ។ ពេលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ គ្រួសារម្តាយរបស់ខ្ញុំត្រូវបានជម្លៀសចេញពីទីក្រុងទៅកាន់ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ ម្តាយរបស់ខ្ញុំគឺជាមនុស្សតែម្នាក់គត់ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ។ ចំពោះវគ្គបណ្តុះបណ្តាលនេះ ខ្ញុំគិតថា វគ្គនេះមានសារសំខាន់ ដោយសារតែខ្ញុំមានឱកាសទទួលបានចំណេះដឹងបន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ មិនតែប៉ុណ្ណោះ ខ្ញុំមានឱកាសសួរទៅកាន់គ្រូបណ្តុះបណ្តាលនិងវាគ្មិនអំពីចម្ងល់ដែលទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម ។ ជាងនេះទៅទៀត ខ្ញុំបានទទួលការបណ្តុះបណ្តាលបន្ថែមអំពីវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល ។ ខ្ញុំយល់ឃើញថា វិធីសាស្ត្របង្រៀនដែលគ្រូបណ្តុះបណ្តាលបានបង្ហាញ អាចជួយឲ្យខ្ញុំមានភាពបត់បែននៅក្នុងថ្នាក់រៀន ។ សម្រាប់ខ្លួនខ្ញុំផ្ទាល់ ខ្ញុំនឹងសាកល្បងប្រើប្រាស់វិធីសាស្ត្រទាំងនោះជាមួយសិស្សរបស់ខ្ញុំដើម្បីធ្វើការស្ទាបស្ទង់ថា វិធីសាស្ត្រណាមួយមានប្រសិទ្ធភាពជាងគេសម្រាប់សិស្សរបស់ខ្ញុំ ។ ខ្ញុំរីករាយដែលបានចូលរួមវគ្គបណ្តុះបណ្តាលនេះ ដោយសារតែមិត្តរួមការងាររបស់ខ្ញុំដែលធ្លាប់ចូលរួមវគ្គបណ្តុះបណ្តាលនេះកន្លងមក មានការជឿជាក់ជាងមុនក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់រៀន ។ ខ្ញុំសង្ឃឹមថា គ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យាទាំងអស់នឹងទទួលបានការបណ្តុះបណ្តាលនេះនៅថ្ងៃខាងមុខ ។


ហ៊ោ រីយ៉ា


ប៊ុន សុដារី

អ្នកគ្រូ ប៊ុន សុដារី អាយុ៣៣ឆ្នាំ មកពីខេត្តស្ទឹងត្រែង៖ ខ្ញុំក្លាយជាគ្រូបង្រៀនតាំងពីឆ្នាំ២០០៨ ។ សព្វថ្ងៃខ្ញុំ

បង្រៀនមុខវិជ្ជាសីលធម៌ពលរដ្ឋដល់សិស្សថ្នាក់ទី១០ ទី១១ និងទី១២ នៅវិទ្យាល័យព្រះរាជបូជនីយកិច្ច ។ បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលនេះ ខ្ញុំសង្កេតឃើញថា ខ្ញុំហាក់ដូចជាយល់ដឹងបានច្រើនជាងមុនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ នៅក្នុងរបបខ្មែរក្រហម ឪពុកម្តាយរបស់ខ្ញុំបានបាត់បង់សាច់ញាតិអស់ស្ទើរគ្មានសល់ ។ កាលពីមុនខ្ញុំដឹងឮអំពីរបបខ្មែរក្រហម តាមរយៈការដំណាលរបស់ឪពុកម្តាយខ្ញុំ ។

លោកគ្រូ យី សុខូយ អាយុ២៩ឆ្នាំ មកពីខេត្តស្ទឹងត្រែង៖ ខ្ញុំបានបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា ដល់សិស្សថ្នាក់ទី១១ និងទី១២ នៅវិទ្យាល័យព្រះរាជបូជនីយកិច្ចអស់រយៈពេលជាងបីឆ្នាំកន្លងមកហើយ ។ ខ្ញុំគិតថា ខ្ញុំទទួលបានចំណេះដឹងផ្នែកប្រវត្តិសាស្ត្រខ្មែរក្រហមច្រើនជាងមុន ។ វិធីសាស្ត្របង្រៀនដែលខ្ញុំចាប់អារម្មណ៍ជាងគេ គឺតារាង *K-W-L= (K= អ្វីដែលយើងបានដឹងមុនពេលរៀន W= អ្វីដែលយើងចង់ដឹងនៅពេលរៀនL= អ្វីដែលយើងបានរៀន)* ។ មិនតែប៉ុណ្ណោះ នៅក្នុងវគ្គបណ្តុះបណ្តាលនេះ ខ្ញុំមានឱកាសសួរសំណួរជាច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម ។ មុនពេលដែលខ្ញុំចូលរួមវគ្គបណ្តុះបណ្តាលនេះ ខ្ញុំធ្លាប់បង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់រៀនដែរ ប៉ុន្តែសិស្សរបស់ខ្ញុំហាក់ដូចជាមិនសូវយកចិត្តទុកដាក់ថារបបខ្មែរក្រហមពិតជាបានកើតឡើងនោះទេ ។ ដូច្នេះ ខ្ញុំបានជំរុញលើកទឹកចិត្តឲ្យសិស្សរបស់ខ្ញុំសួរនាំឪពុកម្តាយ ឬសាច់ញាតិរបស់ខ្លួនអំពីបទពិសោធរបស់គាត់នៅក្នុងរបបខ្មែរក្រហម ។ បន្ទាប់មកសិស្សរបស់ខ្ញុំមួយចំនួនបានសួរនាំឪពុកម្តាយរបស់ខ្លួនអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម និងបានជឿជាក់ថារបបខ្មែរក្រហមពិតជាបានកើតឡើងមែន ។ ចំពោះរូបខ្ញុំផ្ទាល់វិញ ជីដូនរបស់ខ្ញុំបានបាត់បង់ប្អូនម្នាក់នៅក្នុងរបបខ្មែរក្រហម ។


យី សុខូយ

អ្នកគ្រូ សេង សុវណ្ណម៉ាណា អាយុ២៨ឆ្នាំ មកពីខេត្តក្រចេះ៖ ចាប់តាំងពីឆ្នាំ២០១៥មក ខ្ញុំបានក្លាយជាគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យាថ្នាក់ទី៧ ទី៨ និងទី៩ នៅវិទ្យាល័យ ហ៊ុន សែន កន្ទួត ។

ក្នុងចំណោមសិស្សថ្នាក់ទី៧ ទី៨ និងទី៩ មានតែសិស្សថ្នាក់ទី៩ប៉ុណ្ណោះដែលរៀនពីរបបខ្មែរក្រហម នៅក្នុងកម្មវិធីសិក្សា ។ បើតាមការសង្កេតរបស់ខ្ញុំ នៅពេលដែលខ្ញុំបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមកន្លងមក សិស្សរបស់ខ្ញុំហាក់បានបង្ហាញអារម្មណ៍អាណិតអាសូរដល់ជនរងគ្រោះរបបខ្មែរក្រហម ។ មុនពេលដែលខ្ញុំចូលរួមវគ្គបណ្តុះបណ្តាលនេះ ខ្ញុំមានចំណេះដឹងតិចតួចណាស់អំពីរបបខ្មែរក្រហម ដោយសារតែខ្ញុំកើតមិនទាន់របបខ្មែរក្រហម ។ នៅក្នុងចំណោមវិធីសាស្ត្របង្រៀន ខ្ញុំចាប់អារម្មណ៍ តារាង *K-W-L* ដោយសារតែវិធីសាស្ត្រនេះថ្មី និងងាយស្រួលប្រើនៅក្នុងថ្នាក់រៀន ។ អ្វីដែលគួរឲ្យសោកស្តាយគឺសាច់ញាតិរបស់ខ្ញុំមិនសូវចង់ឲ្យខ្ញុំរម្លឹកអំពីរបបខ្មែរក្រហមនៅចំពោះមុខគាត់ឡើយ ។


ញឹម សិទ្ធិ

លោកគ្រូ ញឹម សិទ្ធិ អាយុ៤២ឆ្នាំ មកពីខេត្តរតនគិរី៖ ខ្ញុំធ្វើជាគ្រូបង្រៀនតាំងពីឆ្នាំ២០០០ ។ សព្វថ្ងៃខ្ញុំបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ដល់សិស្សថ្នាក់ទី១០ ទី១១ និងទី១២ នៅវិទ្យាល័យ ហ៊ុន សែន ភូមិថ្មី ។ ខ្ញុំយល់ថា វគ្គបណ្តុះបណ្តាលនេះមានសារសំខាន់ បើទោះបីជាវគ្គបណ្តុះបណ្តាលនេះមានរយៈពេលខ្លីក៏ដោយ ដោយសារតែខ្ញុំទទួលបានចំណេះដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមច្រើនជាងមុន ដែលកាលពីមុនខ្ញុំធ្លាប់តែបានដឹងឮអំពីរបបខ្មែរក្រហមតាមរយៈសាច់ញាតិរបស់ខ្ញុំ និងឯកសារមួយចំនួន ។

ខ្ញុំគិតថា ខ្ញុំមានទំនុកចិត្តច្រើនជាងមុនក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់រៀន ។ ចំពោះវិធីសាស្ត្របង្រៀន ខ្ញុំគិតថា តារាង *K-W-L* ងាយស្រួលក្នុងការអនុវត្ត និងសំណូមពរឲ្យមានការរៀបចំវគ្គបណ្តុះបណ្តាលនេះជាបន្តបន្ទាប់ ដើម្បីអនុញ្ញាតឲ្យគ្រូបង្រៀនដទៃទៀតបានចូលរួម ។

**ម៉ែន ពិចិត្រ**

# ជីវិតរបស់ កៅ ផាន្នី នៅក្នុងរបបខ្មែរក្រហម

កៅ ផាន្នី មានអាយុ៤៨ឆ្នាំ មានស្រុកកំណើតនៅភូមិក្រចាប់ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ និងប្ដីឈ្មោះ អេន មានអាយុ៥០ឆ្នាំ ។ អ្នកទាំងពីររស់នៅឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ អ្នកទាំងពីរមានកូនចំនួន៤នាក់នៅក្នុងបន្ទុកគ្រួសារ (ប្រុសម្នាក់ និងស្រី៣នាក់) ដែលកូនទីមួយឈ្មោះ កៅ ផាន់ណា កូនទីពីរឈ្មោះ កៅ ស្រីនាក់ កូនទីបីឈ្មោះ កៅ មករា និងកូនទីបួនឈ្មោះ កៅ ស្រីពៅ ។

ផាន្នី បានរៀបរាប់ពីដំណើរជីវិតរបស់គាត់ដែលធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមថា ៖ គាត់បានរស់នៅជាមួយបងស្រីដែលគ្រួសារមានជីវភាពមធ្យមនៅភូមិក្រចាប់ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ។

នៅពេលដែល ផាន្នី មានអាយុប្រមាណ១៣ឆ្នាំ ជាពេលដែលខ្មែរក្រហមបានទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរដែលដឹកនាំដោយសេនាប្រមុខ លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ពេលនោះ ប្រជាជនខ្មែរទូទាំងប្រទេសត្រូវបានខ្មែរក្រហមធ្វើការជម្លៀសចេញពីទីក្រុងភ្នំពេញ ឲ្យទៅកាន់តំបន់ស្រុកស្រែចម្ការ ដើម្បីបង្កបង្កើនផលស្រូវ ព្រោះពួកខ្មែរក្រហមជឿតាមពាក្យស្លោកថា “មានស្រូវ គឺមានអ្វីៗទាំងអស់” ។ ម៉្យាងទៀតក្នុងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងនេះ ព្រោះខ្មែរក្រហមសំអាងលើហេតុផលថា ខ្លាចអាមេរិកទម្លាក់គ្រាប់បែកខ្ទះមធ្យោបាយដឹកស្បៀងយកមកផ្គត់ផ្គង់ប្រជាជនដែលរស់នៅក្នុងក្រុងភ្នំពេញ និងអង្គការត្រូវការបោសសម្អាតខ្មាំងក្នុងទីក្រុងដែលនៅសេសសល់ ។

ការជម្លៀសនេះ ប្រសិនបើជនណារឹងទទឹង ហ៊ានប្រឆាំងនឹងបញ្ជា នឹងត្រូវចាប់ចង ឬបាញ់ចោលភ្លាមៗនៅនឹងកន្លែង ។ មិនយូរប៉ុន្មានទីក្រុងភ្នំពេញក្លាយទៅជាទីក្រុងដែលគ្មានប្រជាជនរស់នៅ ។ នៅចុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានធ្វើការជម្លៀសប្រជាជនពីទីប្រជុំជនធំៗ ឲ្យទៅរស់នៅតាមជនបទដាច់ស្រយាល បន្ទាប់មកនៅដើមឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ខ្មែរក្រហមបានធ្វើការជម្លៀសប្រជាជនពីទីកន្លែងមួយទៅទីកន្លែងមួយផ្សេងទៀត ។ ស្របពេលជាមួយគ្នានេះដែរ គាត់ក៏ដូចជាប្រជាជនដែលរស់នៅក្នុងភូមិក្រចាប់ទាំងមូល ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅក្នុងភូមិខ្ទោ ។ ពេញមួយរបបនេះ គាត់ត្រូវបានខ្មែរក្រហមជម្លៀសចំនួនបីលើក ។

ផាន្នី បានបន្តទៀតថា ផ្ទះរបស់គាត់ត្រូវបានខ្មែរក្រហមបាញ់ឆេះ ។ នៅមុនរបបខ្មែរក្រហម សមាជិកក្នុងគ្រួសាររបស់គាត់មានចំនួនប្រាំពីនាក់ ហើយគាត់ជាកូនទីបួន ។ ម្ដាយរបស់គាត់ត្រូវបានស្លាប់ដោយសារតែជំងឺប្រចាំកាយ រួមផ្សំនឹងការបង្ខំឲ្យធ្វើការងារធ្ងន់ហួសកម្លាំង ។ ចំណែកឪពុករបស់គាត់ក៏ត្រូវបានខ្មែរក្រហមសម្លាប់ដែរ ដោយចោទប្រកាន់ថា “ជាខ្មាំងប្រឆាំងនឹងអង្គការ” ។ ក្រោយពេលឪពុកម្ដាយរបស់គាត់ស្លាប់ទៅ គាត់ត្រូវរស់នៅក្នុងនាមជាក្មេងកំព្រា តាំងពីគាត់អាយុបានប្រមាណជា១៣ឆ្នាំ ។

ផាន្នី បានឲ្យដឹងទៀតថា នៅក្នុងរបបខ្មែរក្រហម ប្រជាជនត្រូវបានបំបិទសិទ្ធិសេរីភាព មិនឲ្យមានទ្រព្យសម្បត្តិជាលក្ខណកម្មសិទ្ធិឯកជនឡើយ ហើយទ្រព្យសម្បត្តិ និងសម្ភារប្រើប្រាស់ទាំងប៉ុន្មានរបស់គាត់ ត្រូវបានខ្មែរក្រហមរឹបអូសយកទៅដាក់ជាទ្រព្យសម្បត្តិរួមទាំងអស់ ។ គាត់បានធ្វើការតស៊ូឆ្លងកាត់ការលំបាកគ្រប់បែបយ៉ាងនៅក្នុងរបបនេះ ដោយសុខចិត្តធ្វើតាមបញ្ជារបស់ខ្មែរក្រហមគ្រប់បែបយ៉ាងដើម្បីរក្សាជីវិតឲ្យបានរស់ ។

ការរស់នៅក្នុងរបបខ្មែរក្រហម គឺពិតជាលំបាកខ្លាំងណាស់សម្រាប់គាត់ ខ្មែរក្រហមបានធ្វើបាបគ្រប់បែបយ៉ាង ចំណែកការហូបចុកវិញ គឺឲ្យគាត់ហូបតែបបររាវៗលាយជាមួយដើមចេក ហើយគាត់ក៏មិនដែលបានហូបបានឆ្អែតដែរ ។ គាត់បានរៀបរាប់

បន្តថា ពេលព្រឹកគាត់ត្រូវចេញទៅធ្វើការរហូតដល់ម៉ោង១២ ទើបបានឈប់សម្រាក និងហូបបាយពេលថ្ងៃត្រង់ បន្ទាប់មកគាត់ត្រូវចុះទៅធ្វើការបន្តទៀតរហូតដល់ល្ងាច ។ ចំណែកការរៀនសូត្រនៅសម័យនោះ គឺគ្មានថ្នាក់រៀន គ្មានតុសមរម្យសម្រាប់ក្មេងៗឡើយ ក្មេងៗត្រូវរៀននៅក្រោមដើមឈើ ដោយអង្គុយផ្ទាល់នឹងដី ហើយការបង្ហាត់បង្រៀនរបស់ខ្មែរក្រហមចំពោះក្មេងៗទាំងនោះ គឺអប់រំក្មេងៗដឹងគុណអង្គការជាងដឹងគុណឪពុកម្តាយប៉ុណ្ណោះ ។ ក្មេងៗមួយចំនួន នៅពេលដែលបានទទួលការអប់រំបំពាក់បំប៉នគោលមាគ៌ានយោបាយដ៏ក្រហមឆ្អិនឆ្អៅពីអង្គការខ្មែរក្រហមរួចមក ក្មេងខ្លះត្រូវបានអង្គការបញ្ជាឲ្យសម្លាប់ម្តាយឪពុករបស់ខ្លួនក៏មានដែរ ។ អង្គការបានបញ្ចុះបញ្ចូលក្មេងៗឲ្យខិតខំប្រឹងប្រែងធ្វើការងារបម្រើអង្គការ បើមាននរណាប្រឆាំង នឹងត្រូវយកទៅធ្វើទារុណកម្ម ។

ផាន្នី បានមានប្រសាសន៍ថា នៅក្នុងគ្រួសារ បើមានសមាជិកណាម្នាក់ធ្វើខុស គឺសមាជិកគ្រួសារទាំងមូល ត្រូវមានទោសដូចគ្នា ។ ដោយមិនអាចទប់ស្កាត់នឹងសេចក្តីស្រេកឃ្លានបាន បងរបស់គាត់បានសម្រេចចិត្តលួចដំឡូងរបស់អង្គការហូប ពេលនោះអង្គការតាមទាន់ និងចាប់បងរបស់គាត់បាន រួចយកគាត់ទៅឃុំឃាំងចំនួនបីថ្ងៃ បន្ទាប់មកខ្មែរក្រហមបានដោះលែងបងរបស់គាត់ឲ្យត្រឡប់មកវិញ ។ នៅពេលយប់ ខ្មែរក្រហមតែងប្រើកងឈ្លបក្មេងៗឲ្យមកយកការណ៍នៅតាមផ្ទះ ឬដើរឈ្លបពេលយប់ ដើម្បីស៊ើបរកខ្មាំងប្រឆាំងអង្គការ ។

ចំណែកការរៀបចំគូស្រករវិញ ផាន្នី បានប្រាប់ឲ្យដឹងថា នៅសម័យខ្មែរក្រហម យុវជន និង យុវនារី គ្មានសិទ្ធិក្នុងការជ្រើសរើសគូស្រករដោយខ្លួនឯងនោះទេ អង្គការគឺជាអាណាព្យាបាលជាអ្នកមានសិទ្ធិក្នុងការផ្សំផ្គុំ និងរៀបចំគ្រួសារឲ្យយុវជន និងយុវនារីទាំងអស់ បើនរណាប្រឆាំងនឹងយកទៅកសាង ឬយកទៅអប់រំ ។ នៅក្នុងការរៀបការនេះទៀត យុវជន និងយុវនារីត្រូវឡើងចាប់ដៃគ្នាតាមការរៀបចំរបស់អង្គការ ហើយនៅចំពោះមុខអង្គការ អ្នកទាំងពីរត្រូវធ្វើការប្តេជ្ញាចិត្ត ថានឹងស្រលាញ់គ្នា រួមសាមគ្គីគ្នា រួមរស់ជាមួយគ្នា កសាងគ្រួសារមួយ ដើម្បីបម្រើការងារជូនបក្សឲ្យបានខ្លាំងក្លា ពិសេសការងារបង្កបង្កើនផលស្រូវឲ្យបានទិន្នផលបីតោនក្នុងមួយហិកតាជូនដល់បក្ស និងអង្គការ ។

នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយរំលំរបបខ្មែរក្រហមចេញពីអំណាចទទួលបានជ័យជម្នះទាំងស្រុង ។ កងទ័ពខ្មែរក្រហមរួមជាមួយមេដឹកនាំ បានរត់ទៅនៅព្រៃ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំថ្មីៗ ផាន្នី បានវិលត្រឡប់ទៅរស់នៅស្រុកកំណើតរបស់ខ្លួនវិញ ។ ក្រោយមកនៅឆ្នាំ១៩៩៣ ផាន្នី និងក្រុមគ្រួសារបានមករស់នៅស្រុកអន្លង់វែង ដែលជាស្រុកកំណើតខាងប្តីរបស់គាត់ ។ គាត់រស់នៅទីនោះមិនបានប៉ុន្មានផងក៏កើតមានការវាយប្រហារគ្នា រវាងកងទ័ពខាងរដ្ឋាភិបាលជាមួយនឹងកងទ័ពខ្មែរក្រហម ។ ដោយមានការភ័យខ្លាចចំពោះការវាយប្រហារគ្នានេះ ផាន្នី ក៏បានសម្រេចចិត្តទៅរស់នៅស្រែណូយមួយរយៈ រង់ចាំមើលសភាពការស្ងប់ស្ងាត់ដើម្បីវិលត្រឡប់ទៅអន្លង់វែងវិញ ។ ស្រប់ជាមួយគ្នានោះដែរ កងទ័ពរបស់រដ្ឋាភិបាលនៃរដ្ឋកម្ពុជា បានធ្វើការវាយលុកចូលមកកាន់កាប់ស្រុកអន្លង់វែង ធ្វើឲ្យមេដឹកនាំខ្មែរក្រហមមួយចំនួនបានរត់ភៀសខ្លួនទៅកាន់ទឹកដីថៃអស់ ។

រហូតមកដល់នៅឆ្នាំ១៩៩៨ កងទ័ពខ្មែរក្រហមទាំងអស់នៅតំបន់អន្លង់វែង បានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ នៅទូទាំងប្រទេសកម្ពុជាទាំងមូលលែងមានតំបន់ប្រឆាំងនឹងរាជរដ្ឋាភិបាលទៀតហើយ គឺប្រទេសកម្ពុជាទាំងមូលទទួលបានសុខសន្តិភាពពិតប្រាកដ ។

ផាន្នី សង្ឃឹមថា នៅទូទាំងស្រុកអន្លង់វែង ទាំងមូលក៏ដូចជានៅក្នុងប្រទេសកម្ពុជាទាំងមូល នឹងមិនមានរបបខ្មែរក្រហមកើតមានឡើងជាថ្មីម្តងទៀតទេ ព្រោះរបបនេះបានសម្លាប់ប្រជាជន ។ ផាន្នី ចង់ឃើញតំបន់អន្លង់វែងនេះក្លាយទៅជាតំបន់ប្រវត្តិសាស្ត្រនៅប្រទេសកម្ពុជាដែលអាចទាក់ទាញភ្ញៀវទេសចរមកទស្សនា ។ នៅពេលដែលស្រុកអន្លង់មានភ្ញៀវទេសចរមកលេងច្រើន នោះប្រជាពលរដ្ឋនឹងមានការងារធ្វើ មានមុខរបររកស៊ី ហើយអាចរកប្រាក់កម្រៃយកមកផ្គត់ផ្គង់ក្នុងជីវភាពគ្រួសារបាន ។

**ឡុច សំរុង**

# សំណួររបស់មេធាវីចុងចោទ ទៅកាន់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី

*ថ្ងៃនេះសាក្សី 2-TCW-913 និងដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-235 បានផ្តល់សក្ខីកម្មទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ ។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានរក្សាការសម្ងាត់ ពីព្រោះការស៊ើបអង្កេតនៅបន្តនៅឡើយ ហើយពួកគាត់ត្រូវបានហៅដោយឈ្មោះសម្ងាត់ ។ សាក្សី 2-TCW-913 បានរៀបរាប់ពីហេតុការណ៍ដែលគាត់ត្រូវបានបង្ខំឲ្យសឹកនៅក្នុងឆ្នាំ១៩៧៥ និងក្រោយមកទៀតគាត់ត្រូវបានបញ្ជូនឲ្យទៅធ្វើជាអ្នកភ្លក់ម្ហូបអាហារ ដើម្បីការពារភៀវពីការត្រូវថ្នាំពុល ។ សាក្សីក៏បានប្រាប់ពីការដែលគាត់រួចផុតពីសេចក្តីស្លាប់នៅពេលដែលកងរបស់គាត់ទាំងអស់ត្រូវបានគេយកទៅសម្លាប់ផងដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-235 ក៏នឹងផ្តល់ព័ត៌មានអំពីកម្មាភិបាលជាន់ខ្ពស់មួយចំនួនដូចជា នួន ជា តាម៉ុក និង ស៊ូ ម៉េត ជាដើម ។*

***ការលាចាកសិក្ខាបទ***

*បន្ទាប់ពីពន្យារពេលអស់១៥នាទី អង្គជំនុំជម្រះបានដំណើរការបន្ត ។ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន មានបញ្ហាសុខភាព ដូច្នេះគាត់មិនអាចចូលមកផ្តល់សក្ខីកម្មបានទេ ។ អង្គជំនុំជម្រះមានសាក្សីបម្រុង 2-TCW-913 ផងដែរ ។ លោកចៅក្រម ធូ មរណី បានចូលជំនួសលោកចៅក្រម យូ ឧត្តរា ដែលអវត្តមានក្នុងថ្ងៃនេះ ។ មេធាវីការពារក្តី ខៀវ សំផន លោកស្រី អានតា ហ្គីស្សេ ក៏អវត្តមានដូចគ្នាដែរ ប៉ុន្តែលោកស្រីពុំមានបញ្ជាក់ពីមូលហេតុអវត្តមានរបស់លោកស្រីទេ ។ សាក្សីមិនត្រូវបានហៅឈ្មោះពិតរបស់ពួកគាត់ទេ ដោយសារតែការស៊ើបអង្កេតកំពុងតែបន្ត ។*

*មេធាវីការពារក្តី ខៀវ សំផន បានមានប្រសាសន៍ថា កាលពីថ្ងៃទី៨ ខែវិច្ឆិកា សហការីរបស់លោកស្រី ហ្គីស្សេ បានជម្រាប*



*ដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្មនៅមុខអង្គជំនុំជម្រះ*

ដល់អង្គជំនុំជម្រះអំពីអវត្តមានរបស់លោកស្រីក្នុងថ្ងៃនេះរួចហើយ ។

អង្គជំនុំជម្រះត្រូវបានផ្តល់ជូនសហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាអន្តរជាតិ លោក នីកូឡា គាំចាន់ បានសួរទៅកាន់សាក្សីថា តើគ្រួសាររបស់សាក្សីមកពីតំបន់ណា? សាក្សីបានឆ្លើយថា ពួកគាត់មកពីបូព៌ា ។ សាក្សីបានបួសជាព្រះសង្ឃនៅវត្តតាសួស ខេត្តស្វាយរៀង ដែលនៅទីនោះមានព្រះសង្ឃ១៩អង្គ ។ សាក្សីបួសរៀនបាន៣ឆ្នាំ ហើយបានសឹកក្នុងឆ្នាំ១៩៧៥ ។ នៅថ្ងៃ ១៧ មេសា សាក្សីនៅជាព្រះសង្ឃនៅឡើយទេ ។ សាក្សីបានបន្តទៀតថា «ខ្ញុំត្រូវបានគេបង្ខំឲ្យសឹក ហើយព្រះសង្ឃទាំងអស់ក៏ត្រូវបានគេបង្ខំឲ្យសឹកដូចគ្នាដែរ ។ ពួកគេចង់លុបបំបាត់សាសនា ។ ពួកគេបង្ខំឲ្យខ្ញុំសឹកឲ្យលឿនតាមដែលអាចធ្វើទៅបាន ពីព្រោះពួកគេមិនត្រូវការព្រះសង្ឃទេ» ។ ដូច្នេះដើម្បីកុំឲ្យមានការធ្វើទារុណកម្ម ពួកយើងត្រូវតែសឹក ការចាប់បង្ខំនេះកើតឡើងក្នុងខែមេសា ឆ្នាំ១៩៧៥ ។

## បុរីកីឡា

សាក្សីត្រូវបានបញ្ជូនទៅសហករណ៍មួយកន្លែងនៅក្នុងស្រុកកំណើតរបស់គាត់ ដែលនៅទីនោះគាត់ត្រូវស្ទូងស្រូវ ។ ក្រោយពីនៅទីនោះបាន ២-៣ខែ សាក្សីត្រូវបានគេបញ្ជូនមកធ្វើការនៅរោងចក្រក្នុងទីក្រុងភ្នំពេញវិញ ។ ពេលមកដល់ទីក្រុង សាក្សីត្រូវបានចាត់តាំងឲ្យចិញ្ចឹមជ្រូក ទា និងចម្អិនម្ហូបអាហារសម្រាប់ភ្ញៀវនៅបុរីកីឡា ឬ បាក់ទូក ។

សហព្រះរាជអាជ្ញាអន្តរជាតិ គាំចាន់ បានបន្តសួរថា មុនពេលដែលសាក្សីទៅបុរីកីឡា តើសាក្សីធ្លាប់បានឆ្លងកាត់វគ្គរៀនសូត្រដែរឬទេ? ហើយសាក្សីបានឆ្លើយបដិសេធ ។ អគារបុរីកីឡាត្រូវបានប្រើប្រាស់សម្រាប់វគ្គរៀនសូត្រ ហើយរចនាសម្ព័ន្ធរៀបចំគឺបើកចំហ ដោយមានតុ និង កៅអី ។ សាក្សីមិនធ្លាប់ទទួលបានការរៀនសូត្រទេ ចំណែកប្រធានរបស់គាត់គឺ តាចំរើន ។ សាក្សីធ្វើការនៅទីនោះបានពីរ-បីខែប៉ុណ្ណោះ មុនពេលដែលត្រូវបញ្ជូនទៅសហករណ៍ស្ទឹង ។

សហព្រះរាជអាជ្ញា គាំចាន់ ចង់ដឹងថា តើនរណាជាអ្នកទទួលខុសត្រូវ គ៥ នៅពេលដែលសាក្សីនៅទីនោះ? សាក្សីបានឆ្លើយថា គាត់មិនដឹងនោះទេ ។ សាក្សីធ្លាប់ឮឈ្មោះ ផាន ប៉ុន្តែគាត់មិនធ្លាប់បានជួប ឬឃើញមុខ ផាន ទេ ។ «ខ្ញុំមិនដឹងថា ផាន មានរូបរាងយ៉ាងម៉េចនោះទេ» ។ សហព្រះរាជអាជ្ញា គាំចាន់ បានសួរបន្តថា តើសាក្សីធ្លាប់ឮឈ្មោះ ដួម ដែរឬទេ? សាក្សីបានឆ្លើយថា គាត់ធ្លាប់ឮឈ្មោះនេះ ។ នៅបុរីកីឡា សាក្សីក៏ធ្វើការដាំអំពៅផងដែរ ។ សាក្សីពុំដឹងពីចំនួនមនុស្សដែលធ្វើការនៅបុរីកីឡានេះទេ ហើយគាត់ក៏មិនធ្លាប់លឺឈ្មោះផ្សេងក្រៅពីឈ្មោះ គ៥ នេះដែរ ។

សហព្រះរាជអាជ្ញា គាំចាន់ សួរបន្តថា តើសាក្សីធ្លាប់ឮកងកម្លាំងស្វាដែរឬយ៉ាងណា? សាក្សីបានឆ្លើយថា មានគេប្រាប់ពួកយើងថា យើងត្រូវបានហៅថា «កងកម្លាំងស្វា» ។ យើងជាអ្នកចំណូលថ្មី និងមិនស្គាល់ទីតាំងភូមិសាស្ត្រ ។ ពួកយើងត្រូវបានប្រៀបប្រដូចទៅនឹងសត្វស្វា ។

សាក្សីបម្រើភ្ញៀវមកពីគ្រប់ទិសទីទាំងអស់ គឺពីរដងក្នុងមួយខែ ។ វគ្គរៀនសូត្រមានរយៈពេលពីបីថ្ងៃ ទៅមួយសប្តាហ៍ ។ សាក្សីពុំបានដឹងថា អ្នកណាជាអ្នកបង្កើតវគ្គរៀនសូត្រនេះឡើងទេ ហើយគាត់ក៏ពុំបានដឹងថា «អ្នកណាធ្វើអ្វីខ្លះនោះដែរ» ។ សាក្សីគ្រាន់តែដឹងថា តាចំរើន នៅទីនោះប៉ុណ្ណោះ ។ សាក្សីមិនធ្លាប់បានឃើញមេដឹកនាំណាម្នាក់នោះទេ ប៉ុន្តែគាត់ធ្លាប់បានឮថា មានមេដឹកនាំមកបុរីកីឡានេះ គ្រប់ម៉ោងរៀនទាំងអស់ ។ «ខ្ញុំជាចុងភៅធម្មតាប៉ុណ្ណោះ» ។ សាក្សីមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងបរិវេណរៀនសូត្រនោះទេ ហើយនៅទីនោះមានមនុស្សច្រើនក្រុម ។ ក្រុមខ្លះត្រូវបានចាត់តាំងឲ្យដឹកជញ្ជូនម្ហូបអាហារ និងបម្រើភ្ញៀវផងដែរ ។ សហព្រះរាជអាជ្ញា គាំចាន់ បានបន្តសួរអំពីវត្តមានរបស់កម្មាភិបាលជាន់ខ្ពស់ ដែលត្រូវបានសាក្សីឆ្លើយបដិសេធថា គាត់មិនធ្លាប់ឃើញ ប៉ុល ពត, ខៀវ សំផន ឬមេដឹកនាំណាម្នាក់នោះទេ ប៉ុន្តែគាត់ធ្លាប់បានឮពីអ្នកទាំងនោះ ។ «ខ្ញុំប្រាប់ការពិតទៅអ្នក ។ ខ្ញុំមិនក្បត់ពាក្យសន្យារបស់ខ្លួនឯងនោះទេ ដែលនេះជាសម្បថរបស់ខ្ញុំ» ។ សាក្សីក៏មិនធ្លាប់បានឃើញ នួន ជា នៅបុរីកីឡាដែរ ។ សាក្សីបានបន្តថា «សាលាបណ្តុះបណ្តាលនៅឆ្ងាយណាស់ដូច្នេះខ្ញុំមិនធ្លាប់បានឃើញកម្មាភិបាលជាន់ខ្ពស់ណាមួយនោះទេ» ។

តាចំរើន ជាអ្នកប្រាប់ឲ្យសាក្សីភ្លក់ម្ហូបអាហារ មុនពេលដែលប្រគល់ឲ្យអ្នកលើកម្ហូប ។ «ប្រសិនបើម្ហូបអាហារទាំងនោះ

មានថ្នាំពុល ខ្ញុំជាអ្នកដែលត្រូវស្លាប់ មិនមែនភ្ញៀវទាំងនោះទេ» ។ សាក្សីភ្លក់ បាយ ម្ហូប និង ទឹក ហើយគាត់មិនដឹងថា នរណានឹងមកធ្វើការងារនេះជំនួសគាត់ នៅពេលដែលគាត់លាឈប់នោះទេ ។ «ខ្ញុំមិនធ្លាប់ត្រូវថ្នាំពុល ឬឈឺទេ ។ ការភ្លក់ម្ហូបនេះគ្រាន់តែជាការប្រុងប្រយ័ត្នទុកមុនប៉ុណ្ណោះ» ។ សាក្សីបន្តថា គាត់ត្រូវភ្លក់គ្រប់មុខទាំងអស់ ពីព្រោះប្រសិនបើភ្ញៀវណាម្នាក់ស្លាប់ គាត់នឹងត្រូវគេស្តីបន្ទោសមិនខាន ។ សាក្សីពុំបានដឹងពីមុខងាររបស់ភ្ញៀវទាំងនោះទេ ហើយគាត់ក៏ពុំបានដឹងពីខ្លឹមសារនៃការរៀនសូត្រនេះដែរ ។ សាក្សីធ្លាប់ឮថា ខៀវ សំផន ជាអ្នកបង្រៀននៅទីនោះ ហើយគាត់ធ្លាប់ឮអ្នកនៅទីនោះនិយាយតែពី ខៀវ សំផន ម្នាក់គត់ ។ សាក្សីបានលាឈប់បន្ទាប់ពីធ្វើការនៅទីនោះបានបីខែ ។

សាក្សីប៉ាន់ស្មានថា មានមនុស្សរាប់រយនាក់ដែលបានចូលរួមក្នុងវគ្គរៀនសូត្រនោះ ប៉ុន្តែគាត់មិនប្រាកដនោះទេ ។ សាក្សីអាចមើលឃើញបន្ទប់រៀនសូត្រ ពីចម្ងាយប្រហែល៣០០ម៉ែត្រប៉ុណ្ណោះ ។ សាក្សីក៏ពុំដឹងពីឋានានុក្រមរបស់កម្មាភិបាលទាំងនោះដែរ ។ សាក្សីនិយាយថា «ខ្ញុំគឺជាមនុស្សតូចទាបប៉ុណ្ណោះ» ។

សហព្រះរាជអាជ្ញាអន្តរជាតិ គាំចាន់ បានបង្ហាញឯកសារមួយទៅកាន់សាក្សី ។ សាក្សីបានបន្តថា ឯកសារនេះគឺជាប្រវត្តិរូបរបស់គាត់ ដែលគាត់ត្រូវបានគេបង្ខំឲ្យសរសេរនៅពេលដែលមកដល់ទីក្រុងភ្នំពេញ ។ មកដល់ត្រង់ចំណុចនេះ លោកប្រធានបានផ្អាកសវនាការដោយសម្រាករយៈពេលខ្លី ។

## វគ្គរៀនសូត្រ

សហព្រះរាជអាជ្ញាអន្តរជាតិ គាំចាន់ បានសួរបន្តថា តើសាក្សីត្រូវបានគេបង្គាប់ឲ្យសរសេរប្រវត្តិរូបប៉ុន្មានដងនៅបុរីកីឡា? សាក្សីបានឆ្លើយថា តែម្តងគត់ ។ សហព្រះរាជអាជ្ញា គាំចាន់ បានបន្តថា នៅផ្នែកខាងលើស្តាំ បានបង្ហាញថា សាក្សីនៅកង ស-៧១ ។ តើស-៧១ នេះគឺជាអ្វី? សាក្សីបានឆ្លើយថា គាត់ត្រូវបានគេឲ្យសរសេរលេខកូដនេះចូលប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញា គាំចាន់ បានបន្តទៀតថា តើសាក្សីបំពេញប្រវត្តិរូបនេះនៅក្នុងឆ្នាំ១៩៧៦ ឬយ៉ាងណា? សាក្សីបានឆ្លើយថា គាត់បានមកដល់ទីក្រុងភ្នំពេញបន្ទាប់ពីបានសឹកនៅដើមឆ្នាំ១៩៧៦ ។ សាក្សីត្រូវបានសួរអំពីសាលា ស-២០០ ហើយគាត់បានឆ្លើយថា គាត់ធ្លាប់បានឮឈ្មោះសាលានេះ ប៉ុន្តែគាត់មិនចាំនោះទេ ។ សហព្រះរាជអាជ្ញា គាំចាន់ បានសួរបន្តថា តើសាក្សីនៅចាំ ដាន់ សុជា មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចុះទៅភូមិរបស់គាត់ និងនិយាយជាមួយគាត់ដែរឬទេ? សាក្សីបានឆ្លើយថា គាត់ចាំមិនបាននោះទេ ។ សាក្សីក៏មិនធ្លាប់បានអានបទសម្ភាសន៍នោះ នៅពេលដែលគាត់និយាយជាមួយក្រុមសើបអង្កេតដែរ ។ ដើម្បីធ្វើឲ្យសាក្សីមានការចងចាំឡើងវិញ សហព្រះរាជអាជ្ញាអន្តរជាតិ គាំចាន់ បានអានសម្រង់បទសម្ភាសន៍របស់សាក្សី ដែលសាក្សីបានលើកឡើងថា ខ្លួនធ្លាប់បានរៀននៅសាលាស-២០០ ប្រហែលពីរខែដែរ ។ សាក្សីបានឆ្លើយថា គាត់ត្រូវបានគេបញ្ជូនទៅធ្វើការនៅក្នុងសហករណ៍មួយកន្លែង មុនពេលដែលគាត់ត្រូវបានផ្សឹក ។ បន្ទាប់មកទៀតគាត់ត្រូវបានគេបញ្ជូនទៅរោងចក្រ និងវត្តអំពិលថែមទៀតផង ។ សាក្សីត្រូវបានគេឲ្យសម្រាកនៅទីនោះពីរយប់ ប៉ុន្តែនេះមិនមែនជាវគ្គរៀនសូត្រអ្វីនោះទេ ។ ក្រោយមកទៀតពួកគាត់បានមកដល់ស្វាយរៀង ។ សាក្សីបានបន្តថា មានអគ្គប្រជុំមួយនៅវត្តព្រះទន្លេ ប៉ុន្តែនេះក៏មិនមែនជាវគ្គរៀនសូត្រធំដុំអីដែរ ។ «ខ្ញុំមិនបានចូលរួមក្នុងវគ្គរៀនសូត្រសំខាន់ណាមួយទេ» ។ ពួកគេផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយ ។

សហព្រះរាជអាជ្ញាអន្តរជាតិ គាំចាន់ ចង់ដឹងថា មនុស្សនៅទីនោះធ្វើអ្វី? ពួកគេមិនត្រូវបានអនុញ្ញាតឲ្យទៅណាមកណាដោយសេរីនោះទេ ។ «ពួកយើងទទួលបានការរៀនសូត្រ ប៉ុន្តែពួកយើងមិនទទួលបានសម្ភារអ្វីនោះទេ ។ សាក្សីបន្តថា គ្មាន «វគ្គរៀនសូត្រសំខាន់» នោះទេ ។ ពួកគេបានស្នាក់នៅក្នុងវត្តមួយ ដែលលែងមានព្រះសង្ឃគង់នៅទៀតហើយ ។ សាក្សីជាអតីតព្រះសង្ឃតែម្នាក់គត់ «ខ្ញុំពិតជាអ្នកថ្មីមែន» ។

សាក្សីស្នាក់នៅបុរីកីឡាបាន ពីរ-បីខែ មុនពេលដែលត្រូវគេបញ្ជូនទៅសហករណ៍ផ្សេងទៀត ដើម្បីធ្វើស្រែ ។ សាក្សីត្រូវបានគេព្រមានមិនឲ្យធ្វើខូចខាតរបស់របរនៅទីនោះទេ ។

សហព្រះរាជអាជ្ញា គាំចាន់ បានសួរថា តើសាក្សីត្រូវបានគេបញ្ជូនទៅត្រពាំងក្រឡឹង ក្នុងខេត្តកំពង់ស្ពឺ ដែរឬយ៉ាងណា? សាក្សីបានឆ្លើយបញ្ជាក់ថា ពិតមែន ។ សាក្សីបានបន្តថា អ្នកដែលមកពីបូព៌ាត្រូវបានគេចាត់ទុកជាសត្រូវ ហើយអ្នកដែលមកពី

ស្វាយរៀង និងកន្លែងផ្សេងទៀតត្រូវបានហៅថា "សម្រួល" ។ អ្នកទាំងនោះបានប្រាប់ពួកយើងថា ពួកយើងក្បាលយួន ខ្លួនខ្មែរ ។ នៅក្នុងសហករណ៍ស្ទឹង សាក្សីត្រូវបានគេចាត់ឲ្យមើលថែក្របីខ្សោយៗ រួមជាមួយការផាររភ្ជួរស្រែ ។ ខ្ញុំត្រូវធ្វើការដោយប្រុងប្រយ័ត្នបំផុត ។ ខ្ញុំត្រូវបានគេបញ្ជូនទៅកន្លែងផ្សេងមួយទៀត ដោយសារតែការប្រុងប្រយ័ត្នរបស់ខ្ញុំ ។

នៅពេលដែលសហព្រះរាជអាជ្ញា គាំចាន់ សាកសួរអំពីសហករណ៍ស្ទឹង មេធាវីការពារក្តី នួន ជា លោកមេធាវី វីកទ័រ កូប៉េ បានបដិសេធ ។ លោកមេធាវី កូប៉េ មានប្រសាសន៍ថា សំណួរនេះហួសដែនវិសាលភាពនៃអង្គហេតុ ។ លោកមេធាវី កូប៉េ សំដៅទៅលើសេចក្តីសម្រេចរបស់តុលាការ ហើយបន្តថា សាក្សីរូបនេះមិនឋិតក្នុងក្រុមគោលដៅនោះទេ ។ ម្យ៉ាងទៀត សំណួរនេះក៏មិនឋិតនៅក្នុងវិសាលភាពនៃមន្ទីរសន្តិសុខដែរ ។ សហព្រះរាជអាជ្ញា គាំចាន់ បន្តថា សំណួរនេះឋិតនៅក្នុងដែនវិសាលភាពនៃអង្គហេតុ ពីព្រោះវាពាក់ព័ន្ធនឹងទាហានតំបន់បូព៌ា ។ លោកមេធាវី កូប៉េ បន្តថា បើសិនជាសំណួរនេះត្រូវបានអនុញ្ញាតឲ្យសួរ គឺបំពានទៅនឹងលំដាប់លំដោយនៃសំណួររបស់សហព្រះរាជអាជ្ញាខ្លួនឯង ។ លោកប្រធានបានប្រកាសថា សំណួរត្រូវឋិតនៅក្នុងវិសាលភាពនៃអង្គហេតុ ហើយពេលវេលាក្នុងការសាកសួររបស់សហព្រះរាជអាជ្ញាក៏បានអស់ហើយដែរ ។

សហព្រះរាជអាជ្ញាអន្តរជាតិ គាំចាន់ បានសួរអំពីមនុស្សដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាល ។ សាក្សីបានឆ្លើយថា អ្នកទាំងនោះមកពីភូមិស្រុកជាច្រើន ខុសៗគ្នា ហើយពួកគេមិនស្គាល់គ្នានោះទេ ។

## ការសម្លាប់មនុស្សដែលមកពីតំបន់បូព៌ា

សហព្រះរាជអាជ្ញាអន្តរជាតិ គាំចាន់ បានសួរបន្តថា តើសាក្សីធ្លាប់ត្រូវបានគេបញ្ជូនទៅតំបន់កំពង់សោមដែរឬទេ? លោកប្រធានបានបដិសេធ ដោយមានប្រសាសន៍ថា សំណួរត្រូវឋិតនៅក្នុងលំដាប់លំដោយនៃដំណើរការសវនាការ ។ សាក្សីបានឆ្លើយថា គាត់ត្រូវបានគេបញ្ជូនទៅស្ទឹងហាវ ដែលជាតំបន់មួយនៃកំពង់សោម ។ កម្មករនៅទីនោះសុទ្ធតែមកពីភូមិភាគបូព៌ា ដើម្បីចូលរួមក្នុងការធ្វើពលកម្មធ្ងន់ធ្ងរ ។ សហព្រះរាជអាជ្ញាអន្តរជាតិ គាំចាន់ ចង់ដឹងថា តើមានរឿងអ្វីកើតឡើងចំពោះសាក្សីនាពេលនោះ? សាក្សីបានឆ្លើយថា ពួកគាត់មិនត្រូវបានគេផ្តល់អាហារឲ្យហូបចុកគ្រប់គ្រាន់ទេ ។ អ្នកខ្លះបានដើរស្វែងរកអាហារនៅក្នុងព្រៃ ដោយសារតែភាពស្រេកឃ្លាន ហើយពួកគេត្រូវបានចោទពីបទមិនធ្វើការ ។ ប៉ុន្តែពួកគេបានចាប់ខ្លួន ហឿន អ្នកត្រួតពិនិត្យនៅតំបន់នោះ និងបានបញ្ជូន ហឿន ទៅបន្ទាយទាហាន ដោយប្រាប់ទាហាននៅទីនោះថា ពួកគេមិនត្រូវបានផ្តល់របបអាហារឲ្យហូបចុកគ្រប់គ្រាន់ ។ ហឿន ត្រូវបានបញ្ជូនទៅបន្ទាយទាហានមួយផ្សេងទៀត ។ ថ្ងៃបន្ទាប់ កម្មករ ៥០ នាក់ត្រូវបានហៅឲ្យចូលរួមប្រជុំ ដើម្បី "ដោះស្រាយបញ្ហា" ដោយសារតែពួកគេចាប់មេរបស់ខ្លួនឯង ។ កម្មករទាំងនោះទៅចូលរួមប្រជុំនៅពេលថ្ងៃ ដោយមានពាក់ក្រមាពណ៌ខៀវទៅជាមួយផង ។ "ដោយសារហេតុផលខ្លះស្ថានការណ៍នៅពេលនោះប្រែជា ចលាចល ដូច្នេះ ពួកយើងមិនគួររត់គេចខ្លួនទេ ។ ពួកយើងត្រូវបានប្រាប់ថា ទង្វើរបស់ ហឿន គឺត្រឹមត្រូវ" ។ សាក្សីបានបន្តថា "ពួកគេបានចាប់ចងពួកយើងទាំងអស់គ្នា" ។ លោកមេធាវី កូប៉េ បានបដិសេធ និងបន្តថា សំណួរនេះហួសដែនវិសាលភាពនៃអង្គហេតុហើយ ។ លើសពីនេះទៅទៀត សំណួរនេះមិនមានការពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទនោះទេ ។ "ខ្ញុំគ្មានយោបល់នោះទេថា ហេតុអ្វីបានជាសាក្សីនេះត្រូវផ្តល់សក្ខីកម្មទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ" ។ សហព្រះរាជអាជ្ញា គាំចាន់ បានតបថា ភស្តុតាងទាំងអស់ត្រូវបានបង្ហាញ ទោះបីជាវាគ្មានការពាក់ព័ន្ធនឹងផ្នែកនៃការផ្តល់សក្ខីកម្មនេះក៏ដោយ ។ លោកប្រធានបានសួរថា តើសំណួរនេះទាក់ទងនឹងផ្នែកណាមួយឲ្យប្រាកដទៅ? តើលោកមេធាវី កូប៉េ និយាយសំដៅទៅលើសេចក្តីសម្រេចមួយណាដែរ? សហព្រះរាជអាជ្ញា គាំចាន់ បានបន្តថា សំណួរនេះទាក់ទងនឹងការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ា ។ លោកមេធាវី កូប៉េ បានតបថា សេចក្តីសម្រេចដែលលោកបានលើកឡើងខាងលើគឺផ្តើមចេញពីការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ា នៅកន្លែងប្រហារជីវិតស្ទឹងតូច និងការជម្លៀសប្រជាជនដំណាក់កាលទី៣ ។ សហព្រះរាជអាជ្ញាបានឆ្លើយថា តម្រូវការនៃសហឧក្រិដ្ឋកម្មរួមគឺដើម្បីស្វែងរកចេតនាដូចគ្នា ។ ទោះបីជាកន្លែងប្រហារជីវិតនេះ មិនទាក់ទងកន្លែងប្រហារជីវិតដែលបានបញ្ចូល

នៅក្នុងរឿងក្តីក៏ដោយ ក៏វាចូលទៅក្នុងសហឧក្រិដ្ឋកម្មរួមដែរ ។ វាមានការជាប់ពាក់ព័ន្ធនឹងគោលនយោបាយគោលដៅរបស់មនុស្សដែលមកពីភូមិភាគបូព៌ាទាំងអស់ ។ លោកមេធាវី គូប៊ើ បន្តថា ភស្តុតាងពិតប្រាកដ ដែលទាក់ទងទៅនឹងការបោសសម្អាតគួរតែបញ្ចូលដោយមានហេតុផលច្បាស់លាស់ ដើម្បីពង្រីកដែនវិសាលភាពនៃអង្គហេតុនេះ ។ វាគឺជា «ទង្វើយករណ៍ដែលមិនអាចយកមកការពារបាន» ក្នុងការនិយាយថា វាជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម ហើយស្ថានភាពគឺ «ច្បាស់ណាស់» ។ សហព្រះរាជអាជ្ញា គាំចាន់ បានឆ្លើយតបថា ច្បាស់ណាស់វាមានទាក់ទងនឹងរឿងក្តីនេះ ។ អង្គចៅក្រមធ្វើការពិភាក្សាទៅលើបញ្ហានេះពីរបីនាទី ។ បន្ទាប់មកអង្គជំនុំជម្រះបានផ្តល់ជូនទៅឲ្យលោកចៅក្រម ឡាវ៉ែញ ក្នុងការធ្វើការសម្រេចចិត្ត ។

លោកចៅក្រម ឡាវ៉ែញ មានប្រសាសន៍ថា ទីកន្លែងឧក្រិដ្ឋកម្មនេះមិនឋិតនៅក្នុងវិសាលភាពនៃអង្គហេតុនោះទេ ដូច្នេះ «មិនចាំបាច់» សួរលម្អិតទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អង្គតុលាការអនុញ្ញាតឲ្យសួរសំណួរទាក់ទងនឹងគោលនយោបាយជាតិដែរ ។ សហព្រះរាជអាជ្ញា ត្រូវបានអនុញ្ញាតឲ្យសួរពីរទៅបីសំណួរ ប៉ុន្តែមិនចាំបាច់សួរលម្អិតពេកនោះទេ ។

សហព្រះរាជអាជ្ញាអន្តរជាតិ គាំចាន់ បានបន្តសួរថា តើអ្នកណាជាអ្នកឲ្យក្រមារពណ៌ខៀវដល់អ្នកទាំងនោះ? សាក្សីបានឆ្លើយថា ហឿន ជាអ្នកឲ្យក្រមាពណ៌ខៀវនោះដល់ពួកគាត់ ដែលក្រោយមកទាហានបានប្រើក្រមានោះ ចងពួកយើងទាំងអស់គ្នា ។ សហព្រះរាជអាជ្ញា គាំចាន់ បានឲ្យសាក្សីពណ៌នាដោយសង្ខេបអំពីហេតុការណ៍ដែលបានកើតឡើងក្រោយពីពួកគាត់ត្រូវបានគេចាប់ចង ។ សាក្សីបានឆ្លើយថា បន្ទាប់ពីត្រូវបានចាប់ខ្លួន ទាហានបានឲ្យ «ជំឡូងមួយ ឬពីរបន្ទះ» ប៉ុណ្ណោះដល់ពួកគាត់សម្រាប់អាហារមួយពេល ។ ការចាប់ខ្លួននេះមានរយៈពេល១៨ថ្ងៃ ។ «ពួកគេបានធ្វើទារុណកម្មពួកយើង ។ ពួកគេវាយពួកយើង» ។ នៅយប់ថ្ងៃទី៧ មករា ពួកគេនិយាយថា បញ្ហាមិនអាចដោះស្រាយបាននោះទេ ។ ហើយបក្សនៅភ្នំពេញនឹងដោះស្រាយបញ្ហានេះ ។ ពួកយើងត្រូវបានគេចងមួយបន្ថែមទៀត ហើយត្រូវបានគេយកចេញម្តង១០នាក់ៗ ។ ពួកយើងរកឃើញថា មនុស្សទាំងនោះត្រូវបានគេយកទៅសម្លាប់នៅភ្នំ ។ ខ្ញុំត្រូវបានគេវាយពីរបីដំបងត្រង់ក្បាល ប៉ុន្តែខ្ញុំនៅរស់ ។ នៅក្នុងចំណោមអ្នកស្លាប់ទាំងនោះ ខន ក៏នៅមានជីវិតដូចខ្ញុំដែរ ។ ពួកយើងប្រឹងងើបឡើង ទាំងខ្លួនមានជាប់ចំណង ។ បន្ទាប់មក ខន បានស្រាយចំណងឲ្យខ្ញុំ ហើយខ្ញុំបានស្រាយចំណងឲ្យគាត់ ។

ក្រោយមកទៀត ពួកយើងបានយកភក់មកលាបរបួស និងផឹកទឹកនោមខ្លួនឯងដើម្បីបានរស់ ។ បន្ទាប់មក យើងបានទៅការដ្ឋានធ្វើការ ដើម្បីរកខោអាវរបស់យើង ប៉ុន្តែមនុស្សបានរត់ភៀសខ្លួនអស់ទៅហើយ ។ «ដូច្នេះ ខ្ញុំបានដាំបាយនៅទីនោះ» ។ សាក្សីបាននៅក្នុងវង់មួយនៅទីនោះរយៈពេល១ខែ ។ សហព្រះរាជអាជ្ញា គាំចាន់ បានជូនវេទិកាទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

### ការបន្តសួរសំណួរពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហុង គីមសួន បានសាកសួរទៅកាន់សាក្សីអំពីសេចក្តីថ្លែងការណ៍របស់គាត់ដែលថា គាត់មិនបានដឹងពីបទសម្ភាសន៍ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំ២០០៥នោះទេ ។ សាក្សីចងចាំថា មានមនុស្សមួយក្រុមបានចុះទៅសម្ភាសន៍គាត់ដល់ទីកន្លែងដែលគាត់រស់នៅ ។ «ពួកគេបានថតរូបខ្ញុំផងដែរ» ។ មនុស្ស២នាក់បានសម្ភាសន៍សាក្សី ។ សាក្សីបានអានបទសម្ភាសន៍នោះមុនពេលមកសវនាការនាថ្ងៃនេះ ។ លោកមេធាវី គីមសួន បានសួរបន្តថា នៅក្នុងបទសម្ភាសន៍នោះ តើសាក្សីបានរៀបរាប់ពីបទពិសោធន៍ដែលខ្លួនបានជួបជាមួយ ខៀវ សំផន និង នួន ជា ដែរឬយ៉ាងណា? សាក្សីបានឆ្លើយថា ក្នុងអំឡុងពេលសម្ភាសន៍គេមិនបានសួរគាត់អំពីរឿងនេះនោះទេ ។ លោកមេធាវី គីមសួន បានបន្តថា តើសាក្សីនៅចងចាំពីអត្ថន័យនៃបទសម្ភាសន៍នោះដែរឬទេ? សាក្សីបានឆ្លើយថា ការចងចាំរបស់គាត់មិនល្អនោះទេ «ដោយសារតែគាត់ត្រូវរបួសក្បាល» ។

ដើម្បីឲ្យសាក្សីមានការចងចាំឡើងវិញ លោកមេធាវី គីមសួន បានបង្ហាញពីបទសម្ភាសន៍របស់សាក្សី ។ សាក្សីឆ្លើយថា ខៀវ សំផន បានមកបង្រៀនមួយថ្ងៃក្នុងមួយសប្តាហ៍ ប៉ុន្តែនៅពេលដែលគេសួរគាត់ម្តងទៀត គាត់ឆ្លើយថា ប៉ុល ពត ជាអ្នកមកបង្រៀនទៅវិញ ។ ទោះបីជាយ៉ាងណាក៏ដោយ សាក្សីមិនធ្លាប់បានឃើញនរណាម្នាក់ក្នុងចំណោមពួកគាត់ទាំងពីរនោះទេ ។ នួន ជា

មិនត្រូវបានគេលើកឡើងមកនិយាយទេ ប៉ុន្តែ «ជារឿយៗ អ្នកទាំងនោះតែងតែនិយាយពី ខៀវ សំផនៗ ប៉ុល ពត កម្រមកកន្លែងបណ្តុះបណ្តាលនេះណាស់» ។ ខៀវ សំផន តែងតែទៅទីនោះគ្រប់ម៉ោងបង្រៀនទាំងអស់ ។ ទោះជាយ៉ាងណាក៏ដោយ គាត់ត្រូវបានគេប្រាប់ចម្លើយទាំងនោះ ។ នៅពេលដែលគាត់ត្រូវបានគេសួរនាំ ។ សាក្សីមិនធ្លាប់បានឃើញនរណាម្នាក់នោះទេ ទោះបីឃើញពីចម្ងាយក៏ដោយ ។ លោកមេធាវី គីមសួន បានបន្តថា សាក្សីបានពណ៌នាអំពីរូបរាងរបស់ ខៀវ សំផន និង នួន ជា ។ តើនេះគឺជាចម្លើយរបស់គាត់មែនទេ? សាក្សីបានឆ្លើយថា «ទាំងនេះគឺជាអ្វីដែលខ្ញុំត្រូវបានគេប្រាប់ ហើយសាក្សីបាន «បញ្ជាក់ម្តងទៀតថា នេះគឺជាអ្វីដែលខ្ញុំត្រូវបានគេប្រាប់» ។ សាក្សីបានបន្តថា ខៀវ សំផន បានទៅបង្រៀនក្នុងវគ្គបណ្តុះបណ្តាលនោះ ។ ជាមួយគ្នានេះដែរ លោកមេធាវី គីមសួន បានបញ្ចប់ការសាកសួររបស់គាត់ ។

លោកប្រធានបានផ្តល់ដំណឹងដល់អង្គជំនុំជម្រះថា ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-235 នឹងត្រូវឡើងមកផ្តល់សក្ខីកម្មបន្ទាប់ពីសាក្សីរូបនេះបញ្ចប់ការផ្តល់សាក្សីកម្មរបស់គាត់ ។ លេខទូរសព្ទរបស់ ស សារិន មិនអាចទាក់ទងបាននោះទេ ហើយគាត់បានចាកចេញពីសណ្ឋាគារបាត់ទៅហើយ ។ គាត់ប្រហែលជាមិនអាចផ្តល់សក្ខីកម្មនៅថ្ងៃស្អែកបាននោះទេ ។

## ការចោទសួររបស់អង្គចៅក្រម

លោកចៅក្រម ហ្សង់ម៉ាក ឡាវែញ បានសួរទៅកាន់សាក្សីថា តើបងប្រុសរបស់គាត់ធ្វើការនៅក-៥ដែរឬយ៉ាងណា? សាក្សីបានឆ្លើយបដិសេធចំពោះសំណួរនេះ ។ លោកចៅក្រម ហ្សង់ម៉ាក ឡាវែញ បន្តថា នៅក្នុងប្រវត្តិរូបរបស់សាក្សីបានបង្ហាញថា នង និង ណេត ធ្វើការនៅក-៥ ។ សាក្សីបានឆ្លើយថា គាត់មិនបានធ្វើការនៅទីនោះទេ ហើយគាត់គឺជាកូនច្បងនៅក្នុងគ្រួសារ ។ លោកចៅក្រម ឡាវែញ បានសួរអំពីមូលហេតុដែលគាត់ត្រូវបានផ្សឹក និងស្ថានភាពជាក់លាក់នាពេលនោះ ។ សាក្សីបានឆ្លើយថា ពួកគេបានចាប់បង្ខំគាត់ឲ្យសឹក ។ ពួកគេនិយាយថា នៅក្នុងរបបនេះមិនតម្រូវឲ្យមានព្រះសង្ឃនោះទេ ហើយនៅពេលដែលពួកគេសឹក មិនមានពិធីបុណ្យតាមបែបប្រពៃណីទេ ។ តើខ្ញុំអាចនៅជាព្រះសង្ឃយ៉ាងម៉េចទៅ បើព្រះសង្ឃទាំងអស់ត្រូវបានផ្សឹក? ពួកគេចង់បំផ្លាញភ័ស្តុតាងចោលទាំងអស់ រួមទាំងលុបបំបាត់ចោលសាសនាថែមទៀតផង ។ ពួកគេទាំងអស់ត្រូវសឹកនៅក្នុងថ្ងៃតែមួយ ។

តាយ៉ា ដែលជាគណៈកម្មការនៅត្រស់ និងមនុស្សម្នាក់ទៀត ដែលជាគណៈកម្មការនៅ សង់ ជាអ្នកទទួលខុសត្រូវលើការសឹករបស់ពួកយើង ។ ពួកគេមានកាំភ្លើងដើម្បីចាប់ផ្សឹកព្រះសង្ឃមួយអង្គៗ ។ ពួកគេទាំងពីរនាក់ធ្លាប់ជា «ចៅអធិការ» ប៉ុន្តែពួកគេបានធ្វើ «ទារុណកម្មមកលើព្រះសង្ឃ» ។ បន្ទាប់ពីពួកគេត្រូវបានផ្សឹក ពួកគេបានទៅកន្លែងផ្សេងៗគ្នា ដោយអ្នកខ្លះបានទៅស្រុកកំណើតរបស់គេវិញ ។

ជាមួយគ្នានេះ លោកចៅក្រម ហ្សង់ម៉ាក ឡាវែញ បញ្ចប់ការសាកសួររបស់គាត់ ។ អង្គជំនុំជម្រះត្រូវបានផ្តល់ឲ្យក្រុមមេធាវីការពារក្តី នួន ជា ប៉ុន្តែ លោកមេធាវី កូប៉េ បាននិយាយថា ពួកគាត់គ្មានសំណួរនោះទេ ដោយសារតែគាត់មិនដឹងពីមូលហេតុដែលសាក្សីរូបនេះត្រូវឡើងមកផ្តល់សាក្ខីកម្ម ។

## ធ្វើជាចុងភៅ

មេធាវីការពារក្តី ខៀវ សំផន លោកមេធាវី គង់ សំអុន បានសួរទៅកាន់សាក្សីអំពីប្រវត្តិរូបរបស់សាក្សី ។ តើសាក្សីមាននិយាយកុហកក្នុងប្រវត្តិរូបនោះដែរឬយ៉ាងណា? សាក្សីបានឆ្លើយថា «ប្រសិនបើខ្ញុំមិនកុហកពួកគេទេ ខ្ញុំប្រហែលជាស្លាប់បាត់ទៅហើយ» ។ សាក្សីត្រូវធ្វើម្ហូបសម្រាប់ភ្ញៀវជាច្រើនដែលបានចូលរួមក្នុងការបណ្តុះបណ្តាលនាពេលនោះ ។ ដំបូង សាក្សីចិញ្ចឹមមាន់ទានៅបុរីកីឡា ហើយវាក៏ជាកន្លែងដែលគាត់ធ្វើជាចុងភៅផងដែរ ។ ខ្ញុំត្រូវបែងចែកពេលវេលារបស់ខ្ញុំ «ក្រៅពីការធ្វើរដាំស្ល ខ្ញុំត្រូវចិញ្ចឹមសត្វផងដែរ» ។

ក្នុងចំណោមកងរបស់សាក្សីទាំងអស់ សាក្សីនៅចាំតែ ម៉ន ម្នាក់គត់ ។ ម៉ន ជាអ្នកដឹងជញ្ជូនសម្ភារ ។ សាក្សីពុំបានដឹងពីឈ្មោះផ្សេងរបស់ តាចំរើន នោះទេ ។ សាក្សីបានបន្តថា «តាចំរើន ជាអ្នកគ្រប់គ្រងបុរីកីឡាទាំងមូល» ។ សាក្សីបានបញ្ជាក់ម្តងហើយម្តងទៀតថា គាត់ត្រូវធ្វើការភ្លក់ម្ហូបអាហារមុនពេលដែលត្រូវលើកឲ្យភ្ញៀវ ។

*លោកស្រីចៅក្រម ក្លូរ៉ូឌៀ ហ្វិន បានបន្តថា គាត់មិនយល់ថា សំណួរនេះទាក់ទងពីអ្វីនោះទេ ។ លោកមេធាវី សំអុន មានប្រសាសន៍ថា សំណួរនេះ គ្មានព័ត៌មានទាក់ទងនឹងការពុលអាហារនោះទេ ប៉ុន្តែវាទាក់ទងនឹងការភ្លក់ម្ហូប ។ លោកមេធាវី សំអុន សួរបន្តថា តើវាមានរយៈពេលយូរប៉ុនណាទើបគេលើកម្ហូបនោះទៅឲ្យភ្ញៀវ បន្ទាប់ពីសាក្សីបានភ្លក់រួច? សាក្សីបានឆ្លើយថា ពួកគេលើកម្ហូបភ្លាម បន្ទាប់ពីគាត់បានធ្វើការភ្លក់រួចរាល់ ។ ម្ហូបរបស់ពួកគេមាន ដូចជា សម្លស្ងោរក្តាម និងសម្លគ្រឿងរួមជាមួយសាច់ជ្រូក ឬសាច់ត្រីជាដើម ។ សាក្សីមិនបានដឹងថា សាច់ទាំងនោះយកមកពីទីណានោះទេ ។ លោកមេធាវី សំអុន បានបន្តសួរថា តើសាក្សីមានការភ័យខ្លាចទេ នៅពេលភ្លក់ម្ហូបទាំងនោះ? «ជារៀងរាល់ពេលដែលខ្ញុំភ្លក់ម្ហូប ខ្លួនរបស់ខ្ញុំតែងតែញ័រជានិច្ច ។ ខ្ញុំគិតថា ពួកគេប្រហែលជាចង់សម្លាប់ខ្ញុំហើយ» ។ សាក្សីមានការភ័យខ្លាច ពីព្រោះ «បើសិនជាអ្នកណាម្នាក់ចង់ធ្វើធ្វើបាបខ្ញុំ ចង់សម្លាប់ខ្ញុំ ចង់កម្ទេចខ្ញុំ ។ «សាក្សី» នៅតែមានការភ័យខ្លាចថាពួកគេចង់សម្លាប់គាត់ ។*

*លោកមេធាវី សំអុន បានសួរបន្តថា តើមានអាហារសល់ពីភ្ញៀវ ឬអាហារណាមួយដែលគេទុកសម្រាប់សាក្សីដែរឬយ៉ាងណា? សាក្សីបានឆ្លើយថា គាត់ហូបបាយក្នុងឆ្នាំងដែលសល់ពីភ្ញៀវ ។ អាហារដែលសល់ទាំងនោះក៏ត្រូវយកទៅដាក់ឲ្យជ្រូកស៊ីផងដែរ ។ លោកមេធាវី សំអុន បានបន្តថា តើសាក្សីរក្សាលើគោលជំហរថ្លែងការណ៍ដែលថា ស្ថានភាពការងារ និងអាហារនៅបុរីកីឡាធម្មតាដែរឬយ៉ាងណា? សាក្សីបានឆ្លើយថា គាត់ «មិនគាំទ្រនោះទេ» ។ សាក្សីនៅតែរក្សាការថ្លែងការណ៍របស់គាត់ពីខាងដើមដដែល ។ ជាមួយគ្នានេះដែរ លោកមេធាវី សំអុន បានបញ្ចប់កាសាកសួររបស់គាត់ ហើយការផ្តល់សក្ខីកម្មរបស់សាក្សីក៏ត្រូវបានបញ្ចប់ដែរ ។ លោកប្រធានអង្គជំនុំជម្រះបានអរគុណសាក្សី និងអនុញ្ញាតឲ្យគាត់ត្រឡប់ទៅវិញ ។*

### *ដើមបណ្តឹងរដ្ឋប្បវេណីថ្មី 2-TCCP-235*

*លោកប្រធានបានប្រកាសថា ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-235 នឹងត្រូវឡើងមកផ្តល់សក្ខីកម្មបន្ទាប់ ហើយលោកប្រធានក៏បានជូនដំណឹងដល់សាធារណជនផងដែរថា ដំណើរការនៃសវនាការថ្ងៃនេះគឺ ដើម្បីស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីរៀបរាប់អំពីតួនាទីរបស់ជនជាប់ចោទ ។ ដោយសារតែដំណើរការនៃការស៊ើបអង្កេត ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានហៅដោយឈ្មោះសម្ងាត់ ។*

*មេធាវីដើមបណ្តឹងរដ្ឋប្បវេណី វ៉ែន ពៅ បានសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីអំពីទីកន្លែង និងការងាររបស់គាត់ក្នុងឆ្នាំ ១៩៧៥ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា គាត់បានបួសជាព្រះសង្ឃនៅវត្តប្រាក ឃុំអូររំចេក ខេត្តកំពត ។ នៅក្នុងឆ្នាំ១៩៧១ ក្រុមយោធារបស់ «អង្គការបដិវត្តន៍» បានបង្ខំពួកគាត់ឲ្យសឹក និងបង្ខំពួកគាត់ឲ្យធ្វើការថែមទៀតផង ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានចាប់ផ្សឹកនៅពេលដែលគាត់មានអាយុ១៥ឆ្នាំ ហើយគាត់ត្រូវបានគេបញ្ជូនទៅកងពលធំលេខ១ នៃកងវរសេនាធំ១៦ កងវរសេនាតូច១៨០ ។ នៅពេលនោះ កងពលធំលេខ១ ទើបតែបង្កើតឡើង ។*

*អង្គការបានផ្តល់វគ្គបណ្តុះបណ្តាលសម្រាប់ពួកគេដើម្បីវាយប្រហារទីក្រុងភ្នំពេញ ។ ដើមបណ្តឹងរដ្ឋប្បវេណីជាប្រធានក្រុមពិសេស ដែលប្រមូលផ្តុំដោយបញ្ញវន្តនៅក្នុងកងវរសេនាតូចលេខ១៨០ ។ នៅក្នុងថ្ងៃដែលឡោមព័ទ្ធទីក្រុងភ្នំពេញ ដើមបណ្តឹងរដ្ឋប្បវេណីបានមកដល់ពោធិចិនតុងនៅម៉ោង៦ព្រឹក ។ កងកម្លាំង លន់ នល់ ក៏ដូចជាយុទ្ធនារីផ្សេងទៀតបានរៀបចំផ្កាដើម្បីទទួលពួកយើង ។ តាម៉ុក និង ស៊ូ ម៉េត បានមកដល់ទីក្រុងភ្នំពេញក្នុងចន្លោះម៉ោង៩ និង ម៉ោង១០ព្រឹក ហើយពួកគាត់ទាំងពីរនាក់បានចេញ «បញ្ជាជាច្រើន» ។ នៅពេលនោះ ដើមបណ្តឹងរដ្ឋប្បវេណីបានព្យាយាមរកសាច់ញាតិរបស់គាត់ដើម្បីឲ្យពួកគេចាកចេញពីទីនោះ ។ នៅពេលដែលមកដល់ពោចិនតុង ក្រុមយោធារបស់ដើមបណ្តឹងរដ្ឋប្បវេណីបានឃើញនារីមានកាន់ផ្កាដើម្បីទទួលស្វាគមន៍ និងអបអរដល់ជ័យជម្នះរបស់ពួកគេ ។ ទាហានខ្លះ «អាក្រក់» ខ្លាំងណាស់ ។ ពួកគេបានវាយស្ត្រីទាំងនោះ ហើយឆក់យកផ្កាពីដៃរបស់គេ ហើយបោះវាចោល ។ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលនោះ គាត់ពិបាកនឹងនិយាយណាស់ ព្រោះតែទាហាន លន់ នល់ មានស្រា និងម្ហូបសម្រាប់ពួកគាត់ ។ ម្យ៉ាងទៀត អ្នកបើកយន្តហោះយោធា លន់ នល់ បានប្រមូលផ្តុំគ្នានៅកន្លែងមួយដើម្បីទទួលអង្គការ ។ នេះបើតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។*

នៅពេលដែល តាម៉ុក តាម៉េត និង តាម៉ុត មកដល់ពួកគេបានរៀបចំយានយន្ត GMC ដើម្បីឲ្យអ្នកទាំងនោះទៅជួបអង្គការ ។ ដើមបណ្ដឹងរដ្ឋប្បវេណី បានប្រាប់មនុស្សប្រុសស្រីទាំងនោះកុំឲ្យទៅ និងកុំជឿអង្គការ ពីព្រោះពួកគេអាចនឹងត្រូវសម្លាប់ ។ អ្នកខ្លះបានជឿដើមបណ្ដឹងរដ្ឋប្បវេណី ហើយមិនបានទៅតាមអង្គការ ។ អ្នកខ្លះទៀតបានបើកយានយន្តរបស់គេទៅទិសខាងលិច ។ ដើមបណ្ដឹងរដ្ឋប្បវេណីមានបងប្រុសម្នាក់ជាអ្នកបើកខទូម្ភាគចក្រ ហើយគាត់ព្យាយាមរកបងប្រុសរបស់គាត់ ។ ដើមបណ្ដឹងរដ្ឋប្បវេណី បានរកឃើញមិត្តភក្តិរបស់បងប្រុសគាត់ ។ ខ្ញុំបានប្រាប់ពួកគេឲ្យដោះឯកសណ្ឋានរបស់គេចោល ហើយប្រសិនបើមានគេសួរនាំ ពួកគេគួរតែឆ្លើយថា ពួកគេគឺជាអ្នកធ្វើការធម្មតាប៉ុណ្ណោះ ។ ដើមបណ្ដឹងរដ្ឋប្បវេណី បានប្រាប់ទៅអ្នកទាំងនោះថា គាត់អាចនាំអ្នកទាំងនោះចេញពីព្រលានយន្តហោះនេះ ដើម្បីត្រឡប់ទៅស្រុកកំណើតរបស់ពួកគេវិញ ។

## កំពង់សោម

បន្ទាប់មក ដើមបណ្ដឹងរដ្ឋប្បវេណីបានបន្តថា នៅអំឡុងថ្ងៃទី៣០ ខែមេសា គាត់ត្រូវបានគេបញ្ជូនទៅកំពង់សោមតាមឡាន GMC ។ កងវរសេនាតូចមួយដែលមានទាហានពី៤០០ ទៅ៥០០ នាក់ក៏ត្រូវបានគេបញ្ជូនទៅទីនោះដូចគ្នាដែរ ។ នៅពេលដែលកងវរសេនាតូចលេខ១១៨០ របស់ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានគេបញ្ជូនចេញទៅ យោធាខ្លះរួមទាំងគាត់ផងដែរ ត្រូវបានគេបញ្ជូនឲ្យទៅធ្វើជាកងទ័ពជើងទឹក ឯទាហានខ្លះទៀតត្រូវបានគេបញ្ជូនទៅកន្លែងផ្សេង ។ ដើមបណ្ដឹងរដ្ឋប្បវេណី និងកងរបស់គាត់ ជាទាហានជើងទឹកនៅក្នុង «នាវាធំមួយ» ដែលនៅទីនោះពួកគេព្យាយាមចាប់អ្នកនេសាទ រួមមាន ទាហានថៃ និង អ្នកនេសាទថៃ ដែលបានមកនេសាទក្នុងដែនទឹករបស់យើងផងដែរ ។ ដើមបណ្ដឹងរដ្ឋប្បវេណីនៅទីនោះបានបួនប្រាំខែ ក៏ត្រូវបានស្នើសុំឲ្យទៅកោះស្ដេច ហើយគាត់បានទៅដល់ទីនោះជាមួយនឹងនីរសារម្នាក់ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបន្តទៀតថា បន្ទាប់មកពួកគេបានយកកាំភ្លើងភ្ជង់យើង ។ ខ្ញុំបានព្យាយាមតតាំងជាមួយពួកគេ ដោយដណ្ដើមយកកាំភ្លើង ប៉ុន្តែត្រូវបរាជ័យដោយសារតែពួកគេមានគ្នាច្រើនពេក ។ បន្ទាប់មកពួកគេបានចាប់ខ្ញុំ និង ដាក់ខ្នោះដៃខ្ញុំ ហើយបណ្ដេញនីរសារនោះចេញ ។ មនុស្ស៩នាក់ផ្សេងទៀតក៏ត្រូវបានចាប់ខ្លួនផងដែរ ។ ពួកយើងត្រូវបានគេយកទៅដាក់ក្នុងនាវាធំមួយដែលពោរពេញទៅដោយគ្រឿងអេឡិចត្រូនិចសម្រាប់ឆក់ពួកយើង ។ ពួកយើងត្រូវបានចោទប្រកាន់ពីបទលបលួចចូលដែនដីសត្រូវ ។ ខ្ញុំគឺជាមនុស្សតែម្នាក់គត់ដែលត្រូវបានគេឆក់ ប៉ុន្តែខ្ញុំបានប្រកែកទៅនឹងការចោទប្រកាន់នេះ ។ មនុស្សបីនាក់ត្រូវបានដោះលែង ហើយអ្នកខ្លះទៀតត្រូវជាប់ឃុំនៅបាតទូក ។ អ្នកដទៃទៀត ត្រូវបញ្ជូនទៅកោះកុងដើម្បីធ្វើពលកម្មធ្ងន់ធ្ងរ ឯអ្នកខ្លះទៀតត្រូវបានបញ្ជូនឲ្យទៅធ្វើស្ពានថ្មល់ ។

ពួកគេមិនត្រូវបានផ្តល់អាហារឲ្យហូបចុកគ្រប់គ្រាន់នោះទេ ហើយគេបាននាំមនុស្សចេញម្តងមួយៗ ។ «មុនដំបូង យើងមានគ្នាប្រហែល៤០នាក់ ក្រោយមកនៅសល់តែជាង១០នាក់ប៉ុណ្ណោះ» ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានស្នាក់នៅកោះកុង ប្រហែល១២ ទៅ១៣ខែ ។ មានមនុស្សម្នាក់ឈ្មោះ ចាន់ថា បានស្លាប់បាត់ ។ មិត្តភក្តិខ្លះរបស់គាត់មានការភ័យខ្លាចនៅពេលដែលត្រូវគេបញ្ជូនទៅឆ្ងាយ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ នីរសារបានហៅឈ្មោះរបស់គាត់ ប៉ុន្តែនៅពេលនោះគាត់មិនបានប្រើឈ្មោះពិតប្រាកដនោះទេ ។

ដើមបណ្ដឹងរដ្ឋប្បត្រូវបានបញ្ជូនចេញតាមម៉ូតូទឹកទៅត្រពាំងរូង ដោយមានឆ្មាំការពារជាអ្នកនាំគាត់ទៅ ។ ខ្ញុំគិតថា ខ្ញុំប្រហែលជាត្រូវស្លាប់ហើយ ។ ការពិតមានតែខ្ញុំ និងឆ្មាំការពារពីរនាក់ប៉ុណ្ណោះ ។ ពួកយើងទាំងពីរនាក់បានដើរទៅអណ្តូងទឹក ។ ពួកគាត់ទាំងពីរនាក់បានសម្រាកនៅទីនោះ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានសម្រាកនៅជិតប្រាសាទមួយ ដែលមានមនុស្សជាប់ច្រវ៉ាក់នៅទីនោះ ។ នីរសារបានមករកមើលគាត់ និងយកអាហារខ្លះមកឲ្យគាត់ ។ នៅម៉ោង៧ ឬ ៨ព្រឹក មានការគេប្រកាសថា «អង្គការហៅពួកយើងទាំងអស់គ្នាទៅនាវាធំមួយ» ។ នៅពេលនោះមាននាវាធំពីរ ដែលនាវានីមួយៗអាចផ្ទុកមនុស្សបានពី ១០០ ទៅ២០០ នាក់ ។ នាវានោះធ្វើដំណើរទៅស្រែអំបិល ដែលនៅទីនោះឃើញមានឡាន GMC ។ នៅម៉ោង ៨ ឬ ៩ ព្រឹកមានការប្រកាសតាមអូប៉ាល័រឲ្យពួកយើងធ្វើដំណើរតាមរថភ្លើង ។

មកដល់ត្រង់ចំណុចនេះ មេធាវីការពារក្តី នួន ជា លោក

វិកទ័រ កូប៉េ មានប្រសាសន៍ថា គាត់ត្រូវការការពន្យល់ពីអង្គជំនុំជម្រះ ។ "គ្មានសំណួរណាមួយទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទទាល់តែសោះ" ។ លោកមេធាវី កូប៉េ បានបន្តទៀតថា "តើផ្នែកនៃអង្គជំនុំជម្រះនេះសល់ពីផ្នែកមុនឬក៏យ៉ាងណា? ហើយតើការហៅសាក្សីនេះមកក្នុងបំណងអ្វីដែរ? លោកមេធាវី សំអុន គាំទ្រនឹងការជំទាស់នេះ ដោយមានប្រសាសន៍ថា "សំណួរនេះគ្មានទាក់ទងទាល់តែសោះ" ។ លោកមេធាវី វ៉ែន ពៅ បានឆ្លើយថា ពួកគេកំពុងខិតជិត "សំណួរដែលទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទហើយ ដូច្នេះ សូមមានភាពអំណត់បន្តិច" ។ លោកចៅក្រម និល ណុន មានប្រសាសន៍ថា សំណួរទាំងនោះគឺ "ខុសឆ្ងាយពីការពិត" សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវផ្តល់សក្ខីកម្មពីតួនាទីរបស់ជនជាប់ចោទ ចំណែកឯការពិតដទៃទៀតជាការបន្ទាប់បន្សំប៉ុណ្ណោះ ។ ជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញា វីនសិន ដឺវ៉ាល់ បានឆ្លើយថា ការផ្តល់សាក្សីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺផ្តល់ឲ្យនូវស្ថានការណ៍ជុំវិញប្រធានបទ និងទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទរួមជាមួយនឹងគុកក្រាំងតាចាន់ផងដែរ ។

លោកមេធាវី វ៉ែន ពៅ បានបន្តសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី អំពី "ហេតុការណ៍" នៅពេលដែលគាត់ត្រូវបានគេបញ្ជូនចេញទៅ ។ ដើមបណ្តឹងរដ្ឋប្បវេណី បានរៀបរាប់ថា គាត់បានមកដល់ទីក្រុងភ្នំពេញនៅម៉ោង១០ ជាមួយនឹងមនុស្ស ១.០០០នាក់ផ្សេងទៀត ។ ពួកគេទាំងនោះត្រូវបានបញ្ជូនទៅបុរីកីឡា ហើយពួកគេបានសម្រាកនៅទីនោះកន្លះយប់ មុនពេលដែលរៀនភាគអំពីចម្បាំងរវាងចិន និងជប៉ុនត្រូវបានចាក់បញ្ចាំង ។ នៅថ្ងៃទី៣ មុនពេលដែលត្រូវតម្រង់ជួរ ពួកគេត្រូវបានប្រាប់ឲ្យទៅ "ហូបបាយ" ។

នៅពេលដែលពួកគេតម្រង់ជួរ គេក៏ឃើញមានវត្តមាន តាម៉ុក សុន សេន និង នួន ជា ផងដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណី បានបន្តថា នួន ជា នៅជាមួយ តាម៉ុក តាំងពីដំបូងមកម្ល៉េះ ។ គាត់ស្គាល់ នួន ជា ដោយសារតែកាលពីឆ្នាំ១៩៧៣ គាត់មានរបួស និងត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យនៅក្រាំងល្វា ដែលស្ថិតនៅចន្លោះ ភ្នំឱរ៉ាល់ និង អមលាំង ។ នៅទីនោះ តាម៉ុក និង នួន ជា បានមកសួរសុខទុក្ខអ្នកដែលត្រូវរបួស ។ នីរសារបានប្រាប់គាត់ថា នួន ជា គឺជាបងធំទី២ ។

## កម្មាភិបាលជាន់ខ្ពស់

មេដឹកនាំទាំងបីរួមមាន សុន សេន តាម៉ុក និង នួន ជា ។ នួន ជា មាននាទីគ្រប់គ្រងយោធា ហើយគាត់បាននិយាយលើកទឹកចិត្តដល់ទាហានជិត១.០០០នាក់ រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណី នៅចាំសម្តីខ្លះរបស់ នួន ជា ដែលបានបញ្ចុះបញ្ចូលពួកគាត់ថា អ្នកទាំងអស់គ្នា បានចូលរួមក្នុងសង្គ្រាមប្រឆាំងនឹងពួកចក្រពត្តិនិយមអាមេរិក រួមនឹងអាយ៉ងរបស់ពួកវាផងដែរ ។ អ្នកបានតស៊ូសម្រាប់ជ័យជម្នះ ថ្ងៃ១៧ មេសា ១៩៧៥ របស់បក្សបដិវត្តន៍យើង ដែលជ័យជម្នះនេះ ត្រូវបានដឹងឮទូទាំងសកលលោក ។ ប៉ុន្តែសត្រូវយួនដ៏គួរឲ្យខ្ពើម នៅតែមិនបោះបង់មហិចតាបញ្ចូលកម្ពុជាទៅក្នុងឥណ្ឌូចិន ។ ពួកគេបាននាំកងពលធំជាច្រើន និងបញ្ជូនចារកម្មរបស់គេចូលក្នុងកម្ពុជាប្រជាធិបតេយ្យ រួមទាំងក្នុងជួរកងទ័ពយើងទៀតផង ។ ទាហានដ៏អង់អាចរបស់យើងបានប្រយុទ្ធជាមួយចារកម្មទាំងនោះ ។ បក្សរបស់យើងជឿទៅលើសមមិត្តទាំងអស់គ្នា ។ ពួកយើងនឹងការពារមិនឲ្យសត្រូវយួនចូលក្នុងប្រទេសយើងបានទេ ។

បន្ទាប់ពី នួន ជា និយាយលើកទឹកចិត្តរួចរាល់ តាម៉ុក និង អ្នកឯទៀតបានរៀបចំពួកយើងជា២ក្រុម ។ ក្រុមមួយត្រូវបានបញ្ជូនទៅអ្នកលឿង ។ ក្រុមរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវជិះស្រឡាងដើម្បីឆ្លងទន្លេបិទ ។ នៅលើស្រឡាងមានយានជំនិះចិនរួមទាំងធុងផងដែរ ។ ជាមួយគ្នានេះ លោកមេធាវី វ៉ែន ពៅ បានបញ្ចប់ការសាកសួររបស់គាត់ ។

## ការផ្ទេរ

ព្រះរាជអាជ្ញា ដឺ វ៉ាល់ បានសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីអំពីខណៈពេលដែលគាត់ត្រូវបានផ្ទេរ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា ពួកគាត់នឹងមិនមានអាហារនោះទេ បើសិនជាពួកគាត់មិនព្រមសឹក ។ ស៊ូ ម៉េត គឺជាមេបញ្ជាការទី១នៃកងពលធំលេខ១ ហើយ តាសៀង និង តាសារីជាមេបញ្ជាការទី២ ដែលទទួលបន្ទុកកិច្ចការសាធារណៈ ។ ប៊ុនថេង ដែលធ្លាប់ទទួលបានការបណ្តុះ បណ្តាលនៅហាណូយ គឺជាមេបញ្ជាកានៃកងពលធំលេខ១៨០ ។ នៅពេលដែលមនុស្សទាំងនេះទៅដល់ ដើមបណ្តឹង

រដ្ឋប្បវេណីក៏ត្រូវបានចាប់ខ្លួន ។ កងពលធំទាំងបី គឺនៅក្រោមការគ្រប់គ្រងរបស់តាម៉ុក និងដៃគូរបស់គាត់ នួន ជា ។ ពួកគាត់ទាំងពីរនាក់ជិតស្និទ្ធគ្នាខ្លាំងណាស់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានទទូចថា "ខ្ញុំប្រាកដណាស់ពីតាម៉ុក ។ ឈ្មោះតាម៉ុក គឺជាឈ្មោះហៅក្រៅរបស់ ជឿន" ។ បងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ដែន ជាអ្នកបើកខទ្ទម្ភាគចក្រយោធា ។ នៅក្នុងអំឡុងពេលប្រយុទ្ធ ពួកគេត្រូវធ្វើសកម្មភាព ។ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីទៅដល់ពោធិចិនតុង គាត់ដឹង "យ៉ាងប្រាកដ" តាមរយៈវិទ្យុទាក់ទងថា បងប្រុសរបស់គាត់នៅទីនោះ ។ ដូច្នេះ គាត់បានព្យាយាមរកបងប្រុសគាត់ ។ ក្រោយមក ដើមបណ្តឹងរដ្ឋប្បវេណីបាននាំមនុស្សទៅជាមួយគាត់ និងការពារអ្នកទាំងនោះចេញពីពោធិចិនតុង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានដឹងតាមរយៈការណែនាំរបស់អង្គការថា អ្នកបើកយន្តហោះទាំងអស់នឹងត្រូវប្រហារជីវិត ។

អ្នកមកពីស្រុកភូមិជាមួយគាត់ មិនជឿគាត់នោះទេ ហើយថែមទាំងចង់ជួបអង្គការទៀតផង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានសួរកូនរបស់អ្នកមកពីស្រុកជាមួយគាត់នោះ អំពីជោគវាសនារបស់ឪពុកពួកគេ ហើយកូននោះបានឆ្លើយថា "ឪពុកគេស្លាប់បាត់ហើយ" ។ បងប្រុសពីរនាក់របស់ដើមបណ្តឹងរដ្ឋប្បវេណីក៏ជាអ្នកធ្វើការក្នុងសម័យ លន់ នល់ ផងដែរ ។

សហព្រះរាជអាជ្ញា ដីវ៉ាល់ បានបន្តសួរថា តើដើមបណ្តឹងរដ្ឋប្បវេណីត្រូវលាក់ការអំពីរឿងដែលខ្លួនមានសមាជិកគ្រួសារជាទាហាន លន់ នល់ មែនឬយ៉ាងណា? ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា គាត់មិនបានប្រើឈ្មោះពិត ឬបង្ហាញពីឈ្មោះភូមិកំណើតរបស់គាត់នោះទេ ។ ពួកគេត្រូវបានបណ្តុះបណ្តាលអំពីរបៀប "បែងចែកឋានៈ" ។ សហព្រះរាជអាជ្ញា ដី វ៉ាល់ បានសួរបន្តថា តើតាម៉ុក មានបាននិយាយអំពីជោគវាសនារបស់ទាហានដែលត្រូវបានបញ្ជូនចេញដោយឡាន GMC ដែរឬយ៉ាងណា? "តាម៉ុកមិនបាននិយាយអ្វីនោះទេ" នេះបើតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

ដើមបណ្តឹងរដ្ឋប្បវេណីបានទៅដល់បុរីកីឡា នៅខែមិថុនា កក្កដា ឬ សីហា ។ សហព្រះរាជអាជ្ញា ដីវ៉ាល់ បានសួរបន្តថា បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណីចេញពីកោះកុង តើគេមានបានប្រាប់គាត់អំពីកន្លែងដែលគាត់នឹងទៅដែរឬទេ? ដើមបណ្តឹងរដ្ឋប្បវេណីបានបដិសេធ ។ ពួកគេត្រូវបានអញ្ជើញទៅការិយាល័យមួយដែលគ្រប់គ្រងដោយ តាពីន ។

ដើមបណ្តឹងរដ្ឋប្បវេណីខ្លាចថា គាត់នឹងត្រូវជាប់គុកនៅកន្លែងថ្មីនោះ ។ នៅពេលដែលទៅដល់វាលវិញ គឺបានបង្ហាញថា គាត់នឹងមិនត្រូវជាប់ឃុំនោះទេ ។ មនុស្សទាំងអស់ត្រូវបាននាំទៅបុរីកីឡា ដែលពួកគេត្រូវស្នាក់នៅក្នុងអាគារកម្ពស់បីជាន់ ។ អ្នកខ្លះជាអ្នកធ្វើការក្នុងកងដឹកជញ្ជូន ខ្លះទៀតមកពីថ្នាក់ស្រុក និងអ្នកខ្លះទៀតមកពីផ្នែកផ្សេង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា មិនមានស្ត្រី ឬកុមារនៅទីនោះទេ ហើយមានភាពយន្តឯកសារមួយដែលបានបង្ហាញអំពីការប្រយុទ្ធគ្នារវាងចិន និងជប៉ុន ។

សហព្រះរាជអាជ្ញា ដីវ៉ាល់ បានបន្តថា ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងពី ខៀវ សំផន ។ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា គាត់មិនធ្លាប់បានជួប ខៀវ សំផន នោះទេ ។ គាត់ធ្លាប់តែឮសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ផ្សាយតាមវិទ្យុ នៅឆ្នាំ១៩៧៥ ឬឆ្នាំ១៩៧៦ ប៉ុណ្ណោះ ។ ខៀវ សំផនបានលើកឡើងអំពីទិន្នផលស្រូវ ហើយនិយាយថា មនុស្សម្នាក់នឹងទទួលបានស្រូវពី ១-២តំប៉ឹង ។

នៅពេលនោះ ដើមបណ្តឹងរដ្ឋប្បវេណី បានក្លាយជាសមាជិកនៃសមាគមយុវជនរួចហើយ "ដោយសារតែគាត់ជាមនុស្សដែលមានភាពរីកចម្រើន" ។ សហព្រះរាជអាជ្ញា ដីវ៉ាល់ បានបន្តថា នួន ជា ជាអ្នកទទួលបន្ទុកយោធា ។ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា នួន ជា ជាអនុលេខាបក្ស និងទទួលបន្ទុកយោធា និងសេដ្ឋកិច្ច ។

លោកមេធាវី កូប៉េ បានបដិសេធ ហើយបន្តថា វាហាក់បីដូចជាលឿនពេក ។ ប្រសិនបើគេពិចារណាទៅលើក្រុមមេធាវីការពារក្តី ដែលបានទទួលស្គាល់ នួន ជា ជាអនុលេខាបក្សដែលមានតួនាទីសំខាន់ក្នុងការរៀបចំគោលនយោបាយ និងបានធ្វើការថ្លែងការណ៍នៅបុរីកីឡា ។ សហព្រះរាជអាជ្ញា ដីវ៉ាល់ មានប្រសាសន៍ថា សំណួរនេះទាក់ទងនឹងតួនាទីយោធារបស់ នួន ជា ។ សាក្សីបានឆ្លើយថា គេបានប្រាប់គាត់នៅពេលដែលគាត់នៅមន្ទីរពេទ្យ ។

**លីអូនី គីជេស្តី**

# ការធ្វើទស្សនកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង : កិច្ចផ្តួចផ្តើមជាមួយអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

កាលពីថ្ងៃពុធ ទី១៩ ខែមេសា ឆ្នាំ២០១៧ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៥រូបមកពីខេត្តឧត្តរមានជ័យ មានដូចជា លោក ហូវ តេង, លោក ស្រាង សារឿម, លោក ឃៀន រ៉ាម, លោក ជា ឈឿត និង លោក មន ម៉ៅ បានធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដើម្បីសិក្សាពីមជ្ឈមណ្ឌល និងការងាររបស់មជ្ឈមណ្ឌលផ្ទាល់ ។ គម្រោងនេះត្រូវបានគេផ្តល់អនុសាសន៍ថានឹងត្រូវដាក់បញ្ចូលក្នុងកម្មវិធីផ្តល់សំណងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក ឬ សាលាក្តីខ្មែរក្រហម) ។ ដើម្បីធានាឲ្យបានថាគម្រោងនេះ គឺជាយន្តការផ្តល់សំណងដ៏សមរម្យមួយ អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តល់អនុសាសន៍ឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដើម្បីបញ្ចេញគំនិតផ្ទាល់ខ្លួនទៅលើអត្ថប្រយោជន៍និងគុណសម្បត្តិរបស់គម្រោងមួយនេះ ។

លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី ទៅកាន់មជ្ឈមណ្ឌលកាលពីព្រឹកមិញនេះ ។ មជ្ឈមណ្ឌលនេះស្ថិតលើភ្នំដងរែក ដែលបង្ហាញពីទេសភាពដ៏ល្អស្រស់ត្រកាលនៃប្រទេសកម្ពុជា ។ នៅពេលទៅដល់ទីនោះភ្លាម ដើមបណ្តឹងរដ្ឋប្បវេណីទាំងប្រាំរូបបានដើរទៅកាន់មាត់ប្រាំងថ្ម ដែលបង្ហាញពីទេសភាពនៃទីជនបទជុំវិញ ។ គ្មាននរណាម្នាក់ដែលមិនលង់ចិត្តនឹងសម្រស់ធម្មជាតិដ៏



ទិដ្ឋភាពស្រុកអន្លង់វែង មើលពីលើភ្នំដងរែក

ស្រស់ត្រកាលដែលស្ថិតនៅជុំវិញតំបន់នោះ ក៏ដូចជានៅជុំវិញមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងឡើយ ។ លោកបណ្ឌិត លី សុខឃាង ដែលបាននាំសិស្សានុសិស្សមកពីភ្នំពេញក្នុងដំណើរទស្សនកិច្ចមុនៗដាំដើមឈើជុំវិញមជ្ឈមណ្ឌលនេះ បានថ្លែងថា លោកមានអារម្មណ៍ថាដើមឈើត្រូវបានគេកាប់ជាញឹកញយ ប៉ុន្តែពុំមានការដាំជាថ្មីឡើងវិញឡើយ ។ ដើមឈើទាំងនោះកំពុងតែចាប់ផ្ដើមរីកលូតលាស់ ហើយប្រហែលជាការរីកលូតលាស់នេះឆ្លុះបញ្ចាំងពីសក្ដានុពល ដែលមជ្ឈមណ្ឌលមានក្នុងនាមជាកម្មវិធីផ្ដល់សំណងផងដែរ ។ មជ្ឈមណ្ឌលសម្រាប់ការអប់រំ និងសន្ទនានេះ មានសក្ដានុពលក្នុងការចាក់ឫសគល់ថ្មីក្នុងស្រុកអន្លង់វែង ។

លោកបណ្ឌិត លី សុខឃាង បានចាប់ផ្ដើមធ្វើបទបង្ហាញទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ។ ដំបូង លោកបានធ្វើការពន្យល់ពីកម្មវត្ថុនៃមជ្ឈមណ្ឌល ដើម្បីបង្កើនការយល់ដឹងនិងការស្រាវជ្រាវស្វែងយល់ការពិតរបស់ប្រវត្តិសាស្ត្រកម្ពុជា ដែលយើងចាំបាច់ត្រូវតែធ្វើតាមរយៈការយល់ដឹងពី «ជ្រុងម្ខាងទៀតនៃប្រវត្តិសាស្ត្រ» ។ ដូច្នេះ មជ្ឈមណ្ឌលផ្ដោតសំខាន់លើការផ្សះផ្សា ទាំងក្នុងសហគមន៍ និងប្រទេសជាតិទាំងមូល ។ លោកបណ្ឌិត លី សុខឃាង បានបកស្រាយថា មជ្ឈមណ្ឌលនេះគឺជាបណ្ណាល័យ និងការិយាល័យព័ត៌មានសម្រាប់យុវជន ក្នុងស្រុកអន្លង់វែង មកពីក្រុងភ្នំពេញ និងទីកន្លែងផ្សេងៗ ក្នុងប្រទេសកម្ពុជា និងទូទាំងសាកលលោក ។ បន្ទាប់មក លោកបណ្ឌិត លី សុខឃាង បានលើកឡើងពីទីតាំងភូមិសាស្ត្ររបស់មជ្ឈមណ្ឌល ដោយកត់សម្គាល់ពីសម្រស់ដ៏ស្រស់ត្រកាលនៅលើភ្នំដងរែក និងតួនាទីរបស់ទេសភាពនេះក្នុងការធ្វើឲ្យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក្លាយជាកន្លែងសម្រាប់ធ្វើការពិចារណា ។ សកម្មភាពរបស់មជ្ឈមណ្ឌលក្នុងចំណោមសកម្មភាពផ្សេងៗដែលត្រូវបានរៀបរាប់មានដូចជា ទស្សនកិច្ចសិក្សាពីសន្តិភាព និងសិទ្ធិមនុស្សរបស់សិស្ស ការស្នើឲ្យមានកម្មវិធីបណ្ដុះបណ្ដាលមគ្គុទេសក៍ទេសចរណ៍ ការស្រាវជ្រាវ និងការចងក្រងឯកសារ និងការសរសេរពីសៀវភៅប្រវត្តិសាស្ត្រអន្លង់វែង ។ លោកបណ្ឌិត លី សុខឃាង បានបកស្រាយប្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីថា ដោយសារតែអន្លង់វែងជាតំបន់តស៊ូ ចុងក្រោយរបស់ខ្មែរក្រហម ដូច្នេះហើយតំបន់នេះនៅមានរឿងរ៉ាវជាច្រើនដែលត្រូវការការសិក្សាទៅលើបន្ថែម ។ លោកបានបន្តថា ដើម្បីយល់ដឹងពីរបបខ្មែរក្រហម ពួកយើងត្រូវតែសិក្សាទាំងពីជនរងគ្រោះ និងចារី ប៉ុន្តែទង្វើនេះគឺមិនមែន ដើម្បីលើកតម្កើងរបបខ្មែរក្រហម ឬអតីតកម្មាភិបាលខ្មែរក្រហមនោះទេ ។ ប៉ុន្តែផ្ទុយទៅវិញ ទង្វើនេះមានសារសំខាន់ក្នុងការជួយឲ្យប្រជាជនយល់ដឹងពីមនោគមវិជ្ជារបស់ខ្មែរក្រហម ដែលអាចឈានទៅរកការឆ្លើយសំណួរពាក់ព័ន្ធនឹងការបន្តគាំទ្ររបបខ្មែរក្រហមក្នុងតំបន់នេះ ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៥ ។ សំណួរអំពីប្រវត្តិសាស្ត្រនៅតែពុំទាន់មានចម្លើយ ហើយស្រុកអន្លង់វែងនេះគឺជាដែនប្រវត្តិសាស្ត្រសម្រាប់ប្រទេសកម្ពុជាទាំងមូល ។ លោកបណ្ឌិត លី សុខឃាង បានបកស្រាយថាទស្សនវិជ្ជារបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងពឹងផ្អែកលើគំនិតមួយដែលគិតថា យើងមិនអាចប្រានចោលក្រុមជាក់លាក់ណាមួយក្នុងសង្គមឡើយ ហើយដើម្បីយល់ដឹងពីខ្មែរក្រហម និងអតីតកាល យើងគួរតែចាប់ផ្ដើមពីអន្លង់វែង ព្រោះតំបន់នេះជានិមិត្តរូបនៃផ្នែកមួយដ៏ខ្មៅងងឹតនៃអតីតកាលរបស់កម្ពុជា ដែលអាចដើរតួជាផ្នែកមួយនៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ផ្ទុយទៅនឹងតំបន់ដែលអរិយធម៌អស្ចារ្យផ្សេងៗដូចជា ប្រាសាទអង្គរវត្ត និងបាស្រាទព្រះវិហារ ។

បន្ទាប់ពីបទបង្ហាញ លោកបណ្ឌិត លី សុខឃាង បានសួរដើមបណ្ដឹងរដ្ឋប្បវេណីពីចំណាប់អារម្មណ៍របស់ខ្លួនទៅលើមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងសក្ដានុពលរបស់មជ្ឈមណ្ឌលនេះក្នុងនាមជាផ្នែកមួយនៃកម្មវិធីផ្ដល់សំណងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើមបណ្ដឹងទាំងប្រាំបានយល់ស្របជាឯកច្ឆ័ន្ទថា មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងគួរ តែត្រូវបានបញ្ចូលជាផ្នែកមួយនៃកម្មវិធីសំណងដោយតុលាការខ្មែរក្រហម ។ លោក ម៉ៅ ម៉ន បានផ្ដល់ចម្លើយមុនគេ ដោយលោកបានយល់ស្របជាមួយនឹងមជ្ឈមណ្ឌល និងគម្រោងរបស់មជ្ឈមណ្ឌល ហើយបានលើកសសើរពីតួនាទីរបស់មជ្ឈមណ្ឌល ដែលជាកន្លែងសម្រាប់ធ្វើការសិក្សារៀនសូត្រ និងចងក្រងឯកសារ ។ លោកបានបញ្ជាក់ថា បើតាមគំនិតរបស់លោកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងអាចជាកម្មវិធីផ្ដល់សំណងដ៏ស្រស់ស្អាតមួយ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រេចឧបត្ថម្ភដល់មជ្ឈមណ្ឌល

នេះ ។ ដោយសារតែមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងធ្លាប់ជាអតីតបន្ទប់ប្រជុំរបស់មេដឹកនាំខ្មែរក្រហមមួយចំនួន ហើយស្ថិតក្នុងតំបន់ដែលមេដឹកនាំទាំងនេះភាគច្រើនបានរស់នៅ និងស្លាប់ លោក ម៉ៅ បានលើកឡើងថា មជ្ឈមណ្ឌលនឹងបណ្តាលឲ្យអ្នកដែលមកទស្សនាធ្វើការឆ្លុះបញ្ចាំង ពីអតីតកាលជាក់ជាមិនខាន ។ លោកបានបង្ហាញពីក្តីសង្ឃឹមរបស់លោកថា មជ្ឈមណ្ឌលនឹងអភិវឌ្ឍទៅជាកន្លែងមួយសម្រាប់ការអាន និងការស្រាវជ្រាវពីអតីតកាល ហើយផ្តល់ការស្វាគមន៍ចំពោះទាំងភ្ញៀវជាតិ និងអន្តរជាតិ ។ លោក ហួរ គេង បានឆ្លើយសំណួរចុងក្រោយគេ ដោយនិយាយថា ការមានទីតាំងសម្រាប់ធ្វើការរំឭកឡើងវិញពីអតីតកាលមានសារសំខាន់ណាស់ ។ ទោះជាយ៉ាងនេះក្តី លោកបានស្នើឲ្យមជ្ឈមណ្ឌលធ្វើការសាងសង់ស្តូប ដែលអាចដើរតួជានិមិត្តរូបនៃការរំឭកបន្ថែមពីលើនេះទៅទៀត ។

យើងមានបំណងចង់ស្វែងយល់បន្ថែមពីគំនិតរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងអំពីគម្រោងរបស់មជ្ឈមណ្ឌល ក៏ដូចជាមតិរបស់អ្នកទាំងនោះលើការផ្សះផ្សា និងសំណង ។ ដូច្នេះ ខ្ញុំបានសំណេះសំណាលជាមួយដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ម្តងៗ ដើម្បីពិភាក្សាពីមតិរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ និងដើម្បីយល់ដឹងឲ្យកាន់តែស៊ីជម្រៅទៅលើការគាំទ្រចំពោះមជ្ឈមណ្ឌលដែលអ្នកទាំងនោះបានលើកឡើង ។

ដើមបណ្តឹងរដ្ឋប្បវេណីគ្រប់រូប បានលើកឡើងពីការរួមបញ្ចូលរវាងទេសភាពដ៏ស្រស់ត្រកាលនៅជុំវិញ និងទីតាំងសម្រាប់ការសិក្សាក៏ដូចជាការរំឭកពីអតីតកាល ។ លោក ម៉ៅ បានបកស្រាយថាមុនមកទស្សនា មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង លោកមានអារម្មណ៍ភ័យព្រួយបន្តិចបន្តួច ដោយសារតែកត្តាបរិបទប្រវត្តិសាស្ត្ររបស់តំបន់អន្លង់វែងនេះ ។

ប៉ុន្តែនៅពេលដែលលោកបានធ្វើដំណើរមកដល់ទីតាំងរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនេះ សម្រស់ធម្មជាតិនៃទីតាំងនេះបានឆាបយកអារម្មណ៍របស់លោក ហើយលោកបានប្រាប់ខ្ញុំថា លោកគិតថា ទីតាំងនេះមានសារសំខាន់ណាស់សម្រាប់អ្នកទស្សនាមកគយគន់ទេសភាព និងបន្ធូរអារម្មណ៍ ក៏ដូចជាឆ្លុះបញ្ចាំងអំពីអតីតកាលផងដែរ ។ លោក ហួរ គេង និង លោក ស្រង់ សារីម បានបង្ហាញពីចំណាប់អារម្មណ៍ដូចគ្នាដែរ ។ លោក សារីម បានបកស្រាយថា នេះជាលើកទីមួយដែលលោកបានមកដល់តំបន់អន្លង់



ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំរូប មកពីខេត្តឧត្តរមានជ័យ រួមជាមួយសិស្សមកពីវិទ្យាល័យអន្លង់វែង និងនិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានមកជួបប្រជុំ និងពិភាក្សាគ្នានៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដើម្បីស្នើសុំអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដាក់បញ្ចូលមជ្ឈមណ្ឌលសន្តិភាពនេះក្នុងកម្មវិធីផ្តល់សំណងសម្រាប់ជនរងគ្រោះពីរបបខ្មែរក្រហម ។

វែង ហើយមុនពេលមកទស្សនាលោកពុំបាននឹកស្មានដល់ថាទីតាំងរបស់មជ្ឈមណ្ឌលមានភាពស្រស់ស្អាតបែបនេះឡើយ ។ បន្ថែមពីនេះទៀត លោក សារឹម បានបកស្រាយថានៅពេលដែលលោកស្ថិតក្នុងសាលសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជារឿយៗលោកតែងតែមានអារម្មណ៍ខឹងគុំគួន និងមានបំណងចង់សងសឹក ហើយចង់ឲ្យជនជាប់ចោទស្លាប់ ។ នៅពេលដែលបានមកដល់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងទស្សនាទីតាំងរបស់មជ្ឈមណ្ឌល លោកបានថ្លែងថាលោកចាប់ផ្តើមមានអារម្មណ៍ខុសប្លែកមួយរំពេច ។ លោកមានអារម្មណ៍សប្បាយរីករាយ និងធូរស្បើយ ក្រោយពីបានស្តាប់លោក បណ្ឌិត លី សុខឃាង បកស្រាយពីការផ្សះផ្សា ។ លោក សារឹម បានមានប្រសាសន៍ថាលោកបានយល់ដឹងថា ការសងសឹកមិនសំខាន់នោះឡើយ ប៉ុន្តែអ្វីដែលសំខាន់ជាងគេនោះគឺ ការផ្សះផ្សាជនរងគ្រោះ និងអ្នករស់រានមានជីវិត ។ វាពិតជាមានសារសំខាន់ក្នុងការដែលដើមបណ្តឹងរដ្ឋប្បវេណីយល់ដឹងថា មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានបំណងចង់លើកតម្កើងពីរបបខ្មែរក្រហម ឬតួនាទីរបស់អន្លង់វែងក្នុងអតីតកាលឡើយ ប៉ុន្តែដោយឡែក មជ្ឈមណ្ឌលមានបំណងផ្តល់ជាទីតាំងដើម្បីធ្វើការសិក្សាពីអតីតកាល ។ យោងតាមចំណាប់អារម្មណ៍ទាំងនេះ យើងអាចមើលឃើញយ៉ាងជាក់ស្តែងថា ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រឹមតែពេញចិត្ត និងការរួមបញ្ចូលគ្នារវាងសម្រស់ធម្មជាតិ និងការអប់រំតែប៉ុណ្ណោះទេ ប៉ុន្តែអ្នកទាំងនោះក៏បានគិតថាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងទីតាំងនេះ គឺជាទីតាំងដែលប្រកបដោយភាពវិជ្ជមាន និងសុទិដ្ឋិនិយមមួយសម្រាប់ការលើកតម្កើងការសិក្សារៀនសូត្រ និងការផ្សះផ្សា ។

លោក ម៉ៅ បានមានលើកឡើងថា បន្ទាប់ពីសេចក្តីសម្រេចពីភាពពាក់ព័ន្ធរបស់លោកនៅក្នុងសំណុំរឿង០០២ វគ្គ០១ លោកមិនបានត្រូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាក់ទងឬក៏តាមដានជាមួយនឹងដំណើរវិវត្តន៍នៃតុលាការ ឬសេចក្តីសម្រេចនោះទេ ។ ដូច្នេះ លោកមានការភ្ញាក់ផ្អើល នៅពេលដែលមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានធ្វើការទាក់ទងទៅលោក ។

នេះបានឆ្លុះបញ្ចាំងពីភាពចាំបាច់នៃកម្មវិធីផ្តល់សំណងក្នុងការផ្តល់ទីយាយភាព និងជាវិធីសាស្ត្រក្នុងការបន្តដំណើររបស់ជនរងគ្រោះ ដើម្បីទទួលបានភាពជោគជ័យក្នុងការសម្រេចបាននូវការផ្សះផ្សា និងយុត្តិធម៌របស់អ្នកទាំងនោះរៀងៗខ្លួន ។ លោក សារឹម បានកត់សម្គាល់ឃើញថា តុលាការមិនអាចផ្តល់មកវិញនូវអ្វីដែលជនរងគ្រោះបានបាត់បង់នោះទេ ហើយអ្វីដែលតុលាការធ្វើបាននោះគឺត្រឹមតែជាការកាត់ទោសមេដឹកនាំកំពូលឲ្យជាប់ពន្ធនាគារតែប៉ុណ្ណោះ ខណៈនោះដែរ លោក ខៀន វ៉ាម បានកត់សម្គាល់ថាតុលាការអនុញ្ញាតឲ្យជនរងគ្រោះបញ្ចេញនូវកំហឹងរបស់ពួកគេពីអតីតកាល ដែលទង្វើនេះអាចជួយឲ្យមានការសះស្បើយសម្រាប់មនុស្សមួយចំនួន ។ ប៉ុន្តែ តាមរយៈការពន្យល់របស់លោកបណ្ឌិត លី សុខឃាង មជ្ឈមណ្ឌលនេះអាចបំពេញបន្ថែមឲ្យតុលាការខ្មែរក្រហម ។ បច្ចុប្បន្ននេះ តុលាការអាចកាត់ទោសមេដឹកនាំជាន់ខ្ពស់ស្របទៅតាមអាណត្តិរបស់ខ្លួន ។ ទោះបីជាយ៉ាងនេះក្តី មជ្ឈមណ្ឌលមានទីយាយភាព ហើយអាចអនុញ្ញាតឲ្យប្រជាជនប្រើប្រាស់ការស្រាវជ្រាវ និងការអប់រំ ជាវិធីសាស្ត្រក្នុងការថ្កោលទោសរបបខ្មែរក្រហម តាមរយៈសង្គម ការសិក្សាស្រាវជ្រាវបែបជាន់ខ្ពស់ ដោយគ្មានដែនកំណត់ ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងជាតំណាងនៃវិធីសាស្ត្រក្នុងការរិះគន់ និងការបញ្ចេញមតិ ក៏ដូចជាការចងក្រងឯកសារ និងការអប់រំ ដែលមិនមានថ្ងៃផុតកំណត់ ។ ដូចអ្វីដែលលោក ឈឿត បានកត់សម្គាល់ តុលាការត្រូវតែមានភាពរហ័សក្នុងការកាត់ក្តី ដោយសារតែវ័យចំណាស់របស់ជនជាប់ចោទ ។ តាមរយៈការរួមបញ្ចូលមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងទៅក្នុងការផ្តល់សំណងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងជួយតបត នឹងពេលកំណត់ដែលអង្គជំនុំជម្រះមានតាមរយៈការវិនិយោគលើគម្រោង ដោយមិនរឹតត្បិតដោយពេលវេលា ។

ជាចុងបញ្ចប់ យើងក៏ត្រូវតែពិចារណាលើប្រភេទសំណងដែលដើមបណ្តឹងរដ្ឋប្បវេណីគិតថាមានសារសំខាន់បំផុតសម្រាប់ខ្លួន ។ លោក ខៀន វ៉ាម បានបញ្ជាក់ថា លោកមានអារម្មណ៍ត្រេកអរ ដែលមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនេះត្រូវបានបង្កើតឡើង ដោយសារតែគាត់មានអារម្មណ៍ថាការផ្តល់សំណងនេះគួរតែរួមមានការថែរក្សាឯកសារ ខណៈពេលដែលលោក ឈឿត ក៏កត់បានសម្គាល់ពីសារសំខាន់នៃការអប់រំ និងការលើកទឹកចិត្ត



ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំរូប មកពីខេត្តឧត្តរមានជ័យ រួមជាមួយសិស្សមកពីវិទ្យាល័យអន្លង់វែង និងនិស្សិតមកពីសាកលវិទ្យាល័យភ្នំពេញ ថតរូបជុំគ្នានៅខាងមុខការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។

យុវជនជំនាន់ក្រោយឲ្យរៀនសូត្រពីប្រវត្តិសាស្ត្រ ។ លោកគេង បានថ្លែងថា កម្មវិធីផ្តល់សំណងនេះ គួរតែផ្តោតលើគម្រោង ដែលផ្តល់ភ័ស្តុតាងពីអតីតកាលដើម្បីធ្វើឲ្យប្រាកដថាអំពើឃោរឃៅបែបនោះមិនអាចកើត ឡើងសារជាថ្មីម្តងទៀត ខណៈពេល លោក ម៉ៅ បានផ្តោតលើយ៉ាងខ្លាំងទៅលើសារសំខាន់នៃការអប់រំរបស់កម្មវិធីផ្តល់សំណង ។ លោក ម៉ៅ បានបង្ហាញពីចំណាប់អារម្មណ៍លើការចែករំលែករឿងរ៉ាវរបស់លោកទៅកាន់ក្មេងៗជំនាន់ក្រោយ ហើយលោកក៏មានអារម្មណ៍វិជ្ជមានចំពោះតួនាទីរបស់មជ្ឈមណ្ឌល ជាសារមន្ទីរមួយដែល មានការចូលរួមពីយុវជន ។

ជាការពិតណាស់ យោងតាមការឆ្លើយតបទាំងនេះ យើងអាចឃើញបានយ៉ាងជាក់ស្តែងថា មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានទទួលការឯកភាពជាឯកច្ឆ័ន្ទពីដើមបណ្តឹងរដ្ឋប្បវេណីទាំងប្រាំ ហើយគោលដៅ និងមូលដ្ឋានរបស់មជ្ឈមណ្ឌលសមស្របជាមួយ និងតម្រូវការផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការផ្តល់សំណងការផ្សះផ្សា និងការរំឭកពីអតីតកាល ។ បន្ថែមពីនេះទៀត មានការកត់សម្គាល់ថា មានតែដើមបណ្តឹងរដ្ឋប្បវេណីប្រាំរូប ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំង១៧រូប នៅឧត្តរមានជ័យ តែប៉ុណ្ណោះ ដែលបានចូលរួមទស្សនាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដើម្បីធ្វើការចែករំលែកមតិរបស់ខ្លួនទៅលើការងាររបស់មជ្ឈមណ្ឌល ដោយសារមានតែដើមបណ្តឹងទាំងប្រាំរូបនេះទេដែលអាចធ្វើដំណើរបាន ព្រោះដើមបណ្តឹងដទៃទៀតមានជំងឺឈឺថ្កាត់ មិនអាចធ្វើដំណើរបាន ហើយមានដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានទទួលមរណភាពផងដែរ (យោងតាមការបកស្រាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានវត្តមាន) ។ បើទោះបីជាចំនួនដើមបណ្តឹងដែលអាចចូលរួមបានមានកំណត់ក៏ដោយ ប៉ុន្តែការឆ្លើយតបដែលប្រកបដោយភាពវិជ្ជមាន និងសុទិដ្ឋិនិយមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងប្រាំរូបដែលមានវត្តមាន បានធ្វើឲ្យមានការជំរុញលើកទឹកចិត្តយ៉ាងខ្លាំងដល់ក្រុមការងារយើងដែលមកពីមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ ក្នុងនាមជាផ្នែកមួយនៃកម្មវិធីផ្តល់សំណងដើមបណ្តឹងរដ្ឋប្បវេណី មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងហាក់មានសមត្ថភាពក្នុងការពង្រីកដំណើរក្រោយជម្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្រុកអន្លង់វែង និងប្រជាជនក្នុងប្រទេសកម្ពុជាទាំងមូល លើសពីកម្មវិធីផ្តល់សំណងដើមបណ្តឹងរដ្ឋប្បវេណីរបស់អង្គជំនុំ ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយហេតុផលនេះ យើងសង្ឃឹមថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងយករបាយការណ៍នេះដើម្បីពិចារណាដាក់បញ្ចូលមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក្នុងកម្មវិធីផ្តល់សំណងដូចដែលបានផ្តល់អនុសាសន៍ ។

**ភាហ្ស៊ី ហេជីវិចគុន**

# ការបង្កើតជារូបរាង និងការរចនាឡើងនូវវិទ្យាស្ថានស្ទីករីត មជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍

នៅក្នុងថ្ងៃនេះ អ្នកកាន់ទុក្ខនៅទូទាំងពិភពលោក រំពុកអំពីការទទួលមរណភាពដែលមិនគួរកើតមានរបស់លោកស្រី ហ្សាហា ម៉ូហាម៉ាដ ហាឌីដ ស្ថាបត្យករមានសញ្ជាតិដើមអ៊ីរ៉ាក់មួយរូប ដែលមានស្នាដៃ និងកេរ្តិ៍ឈ្មោះលំដាប់ពិភពលោក ក្នុងចំណោមស្ថាបត្យករមានទេពកោសល្យបំផុតនានា ។ ចំពោះវិទ្យាស្ថានស្ទីករីត យើងពិតជាមានកិត្តិយសណាស់ដែលអាចរួមបញ្ចូលនូវស្នាដៃរបស់លោកស្រីនៅក្នុងការរចនាពោរពេញដោយភាពបង្កើតថ្មីរបស់វិទ្យស្ថាននេះ ។ វិទ្យាស្ថាននេះផ្ទាល់ក៏ទទួលបានកិត្តិសព្ទល្បីរន្ទឺជាពិសេសដោយសារតែគោលគំនិតប្លែកពីគេរបស់វិទ្យាស្ថានក្នុងការប្រើប្រាស់ស្ថាបត្យកម្មរបស់ខ្លួន ដើម្បីផ្តល់តម្លៃដល់ការចងចាំអំពីជនរងគ្រោះស្លូតត្រង់ ។ យើងសូមឆ្លៀតឱកាសនេះដើម្បីរំឭកថាយើងអាចអញ្ជើញលោកស្រីឲ្យចូលរួមជាមួយនឹងវិទ្យាស្ថានស្ទីករីតបានដោយរបៀបណា ហើយយើងបានបង្ហាញដល់ក្រុមស្ថាបត្យកររបស់លោកស្រីអំពីសិល្បៈ និងស្ថាបត្យកម្មបែបបុរាណដ៏ល្អប្រណិតរបស់ប្រទេសកម្ពុជាដោយរបៀបណា ដើម្បីអាចឲ្យក្រុមស្ថាបត្យករនេះអាចរួមបញ្ចូលសមាសធាតុទាំងនេះទៅក្នុងគម្រោងការរចនា ។ យើងមានសេចក្តីសោកសង្រេកយ៉ាងខ្លាំង ដោយសារតែការទទួលមរណភាពដែលមិនគួរកើតមានរបស់លោកស្រី យើងមិនអាចទទួលស្វាគមន៍ ក៏ដូចជាធ្វើឲ្យលោកស្រីចូលរួមពេញលេញនៅក្នុងកេរដំណែលបែបបុរាណដ៏ល្អប្លែករបស់ប្រទេសកម្ពុជានេះ ។ តទៅនេះគឺជាព័ត៌មានពិស្តារ ៖

មួយរយៈពេលខ្លីបន្ទាប់ពីលោកឆាំង យុ ស្ថាបនិកវិទ្យាស្ថាន



រូបទីមួយរាប់ពីឆ្វេង ៖ អ្នកស្រី ហ្សាហា ម៉ូហាម៉ាដ ហាឌីដ ជាស្ថាបត្យករ និង ជាប្រធានក្រុមហ៊ុន ហ្សាហា ហាឌីដ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្ទីករីត នៅការិយាល័យកណ្តាលរបស់ក្រុមហ៊ុនអ្នកស្រី ក្នុងទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស ។

ស្ទីករីត និងជានាយកប្រតិបត្តិនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានស្នើឲ្យខ្ញុំធ្វើជាសមាជិកមួយរូបនៃក្រុមប្រឹក្សាជាន់ខ្ពស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា យើងបានពិភាក្សាគ្នាអំពីចក្ខុវិស័យនៃវិទ្យាស្ថានស្ទីករីតរបស់លោក ។ លោកបានស្នើទៅកាន់ស្ថាបត្យករខ្មែរក្នុងស្រុកនានា ក៏ប៉ុន្តែលោកគិតថាសំណើគម្រោងដែលផ្តល់ឲ្យពុំបានឆ្លើយតបគ្រប់គ្រាន់ចំពោះចក្ខុវិស័យរបស់លោកទេ ។ ខ្ញុំផ្តល់យោបល់ដល់ក្រុមប្រឹក្សាឲ្យស្វែងរកសេវាកម្មផ្នែកស្ថាបត្យកម្មកម្រិតពិភពលោក ហើយលោកក៏ស្នើឲ្យខ្ញុំធ្វើការសាកសួរ ។

ខ្ញុំបានសរសេរលិខិតសាកសួរទៅកាន់ស្ថាបត្យករល្បីល្បាញពិភពលោកដែលប្រចាំនៅសហរដ្ឋអាមេរិកចំនួនពីររូប មួយរូបជាបុរស និងមួយរូបជាស្ត្រី អ្នកទាំងពីរបានបដិសេធដោយសារតែសម្ពាធការងារ ឬចំណាប់អារម្មណ៍របស់គាត់ដែលប្តូរទៅលើអ្វីផ្សេងក្រៅពីអគារ ។ បន្ទាប់មកខ្ញុំក៏បានសរសេរទៅកាន់ក្រុមហ៊ុនស្ថាបត្យកម្ម ហ្សាហា ហាឌីដ ដោយពន្យល់បកស្រាយអំពីគម្រោងនិងបង្ហាញអំពីគោលបំណងរបស់យើងក្នុងការបង្ហាញនូវគំរូអគារថ្មីមួយដែលខុសប្លែកពីគោលគំនិតបែបប្រពៃណីដែលមានទម្រង់ជាក់លាក់ និងទទួលឥទ្ធិពលពីស្ថាបត្យកម្មនៃបូជនីយដ្ឋានបែបលោកខាងលិច ។ លោក ឆាំង យុ គាំទ្រចំពោះស្ថាបត្យករជាស្ត្រីដោយសារតែជនរងគ្រោះ ស្ទួតត្រង់នៃអំពើប្រល័យពូជសាសន៍មួយភាគធំគឺជាស្ត្រី និងកុមារ ។

យើងមានសេចក្តីសោមនស្ស នៅពេលដែលក្រុមហ៊ុនរបស់លោកស្រី ហាឌីត បានបង្ហាញពីការចាប់អារម្មណ៍ ក្រោយមក យើងក៏បានទៅជួបជាមួយនឹងក្រុមរចនាដែលរៀបចំឡើងផ្ទាល់ដោយលោកស្រី នៅទីក្រុងឡុងដ៍ ដើម្បីចាប់ផ្តើមដំណើរការរចនា ។ នៅក្នុងអង្គប្រជុំ លោក ឆាំង យុ បានបកស្រាយអំពីសារសំខាន់នៃការដាក់បញ្ចូលទៅក្នុងការរចនានូវសមាសធាតុជានិមិត្តរូបនៃសម្បត្តិវប្បធម៌បែបបុរាណ និងស្ថាបត្យកម្មបែបសាសនារបស់កម្ពុជា ជាពិសេសគឺបណ្តុំប្រាសាទប្លែកពីគេ ដែលប្រមូលផ្តុំនៅបរិវេណអង្គរវត្ត ។ យើងក៏បានបញ្ជាក់អំពីតម្លៃជាវិជ្ជមានដែលយើងចង់ឲ្យការរចនារំឭកដល់ ការសះស្បើយ យុត្តិធម៌ ការផ្សះផ្សា និងសេចក្តី សង្ឃឹមចំពោះអនាគត ។ សមាជិកនៃក្រុមរចនាបានយល់ស្រប ហើយនៅរយៈពេលប៉ុន្មានខែក្រោយមកក្រុមរចនានេះបានធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ ។ ស្របតាមការប្រឹក្សា យើងបានរួមដំណើរជាមួយនឹងក្រុមរចនាទៅកាន់ខេត្តសៀមរាប ។ ដំបូង យើងបានធ្វើទស្សនកិច្ចជុំវិញបរិវេណអង្គរវត្ត និងប្រាសាទនានាក្បែរនោះ ។ បន្ទាប់មក យើងបានបន្តទៅកាន់ទីតាំងដែលឆ្ងាយពីនោះ ដែលតម្រូវឲ្យយើងធ្វើដំណើរវែងឆ្ងាយលើផ្លូវក្រាលកៅស៊ូ និងផ្លូវលំនានា ទន្ទឹមនឹងនោះ ដំណើរស្រាវជ្រាវនេះក៏តម្រូវឲ្យយើងធ្វើដំណើរដោយថ្មើរជើងកាត់ព្រៃ ដើម្បីទៅទស្សនាប្រាសាទចាស់បាក់បែកនានា ក្នុងនោះ ប្រាសាទមួយចំនួនស្ថិតនៅក្បែរព្រំដែនកម្ពុជា-ថៃដូចជាប្រាសាទព្រះវិហារ ។

ចំណុចពិសេសមួយក្នុងចំណោមចំណុចពិសេសផ្សេងៗនៃដំណើរស្រាវជ្រាវជាច្រើនថ្ងៃនេះ គឺការធ្វើទស្សនកិច្ចរបស់យើងទៅកាន់ប្រាសាទបន្ទាយស្រី ដែលមានលិង្គរបស់ត្រីភុវតមហេស្វរមានន័យថា ម្ចាស់ដ៏មានតេជ នៃឋានក្រោមទាំងបីផ្នែក ។ ខុសប្លែកពីប្រាសាទដ៏ធំ និងមហស្ចារ្យ គឺប្រាសាទអង្គរវត្ត ប្រាសាទបន្ទាយស្រី គឺជាប្រាសាទតូចល្អប្រណិតមួយ ក៏ប៉ុន្តែក្បូរក្បាច់រចនាយ៉ាងល្អិតល្អន់លើផ្នែកខាងមុខរបស់ប្រាសាទនេះ នៅតែរក្សាបានទ្រង់ទ្រាយភាគច្រើន ជាជាងប្រាសាទធំៗដទៃ ។ ចំពោះសមាជិកនៃក្រុមរចនា បទពិសោធន៍ទៅកាន់ប្រាសាទបន្ទាយស្រីនេះ បានផ្តល់នូវទិដ្ឋភាពថ្មីមួយចំពោះការយល់ដឹងរបស់គេ នោះគឺការផ្តោតលើសោភណភាព សិល្បៈខ្នាតតូច ដោយប្រើប្រាស់ជំនាញបច្ចេកទេសដ៏វិសេសវិសាល ក្នុងការរំលេចនូវទិដ្ឋភាពជាក់ស្តែងនៃនិមិត្តរូបបែបសាសនា និងវប្បធម៌ ដែលមិនអាចប្រៀបផ្ទឹមបាននៅទីតាំងនានាក្នុងប្រទេសកម្ពុជា ក៏ដូចជាតំបន់អាស៊ីអាគ្នេយ៍ ។ សមាជិកក្រុមរចនាបានប្រែក្លាយបទពិសោធន៍ជាក់ស្តែងរបស់ខ្លួនទៅជាការគូរគំនូរ និងថតរូប ព្រមទាំងវិលត្រឡប់ទៅកាន់ទីក្រុងឡុងដ៍ ជាមួយបទពិសោធន៍ផ្ទាល់ទៅកាន់ពិភពប្លែកទាំងស្រុងមួយនិងរបៀប ដែលមនុស្សពោរពេញដោយទេពកោសល្យ និងការប្តេជ្ញា បានបង្កើតពិភពនេះឡើង ។ ក្រុមរចនាបានគ្រោង ធ្វើការប្រែក្លាយនូវបទពិសោធន៍ដែលទទួលបាន និងបង្កើតជាការរចនាវិទ្យាស្ថានស្ទីករីតនេះឡើង ក្រោមការដឹកនាំរបស់លោកស្រីហ្សាហា ហាឌីដ ។

**ម៉ាកឃីស ហ្សីមមឺរ**

# ចំណាប់អារម្មណ៍របស់និស្សិតស្ថាបត្យកម្មចំពោះស្នាដៃរចនា របស់វិចិត្រករ ស៊ីវា អ៊ីង

***យ៉េង សិរីរ័ត្នៈ មនោសញ្ចេតនានៃរូបចម្លាក់***

កាលពីប៉ុន្មានឆ្នាំមុន ខ្ញុំធ្លាប់បានឃើញស្នាដៃសិល្បៈរបស់ ស៊ីវា មួយចំនួន ជាពិសេសផ្ទាំងគំនូររបស់គាត់ ។ ជាទូទៅ គំនូរទាំងនេះត្រូវបានគូសឡើងនៅលើផ្ទាំងក្តារបន្ទះធំៗ ដែលពោរពេញទៅដោយគំនិតបង្កប់ ការរួមបញ្ចូលនូវសម្ភារបែបទំនើប និងអារម្មណ៍នៃការរងចាំអំពីរបបខ្មែរក្រហម ។



រូបចម្លាក់របស់ ស៊ីវា អ៊ីង ធ្វើពីស្ពាន់

ក្រោយមកទៀត នៅពេលដែលខ្ញុំបានឃើញស្នាដៃចម្លាក់របស់គាត់ជាលើកដំបូង ខ្ញុំមានការភ្ញាក់ផ្អើលណាស់ ដោយសារតែស្រទាប់ផ្ទៃខាងក្រោម ស្រទាប់ខាងលើនៃរូបចម្លាក់ ទ្រង់ទ្រាយនៃរូបចម្លាក់ លំនឹង និងចលនានៃរូបចម្លាក់ ចំណុចទាំងនេះបានធ្វើឲ្យខ្ញុំរំភើបពេលភាពអច្ឆរិយនៃបច្ចេកទេសផ្នែកលំនឹង និងការដំឡើង ។

ស្រទាប់នៃរូបចម្លាក់មានលក្ខណៈគ្រើម និងរឹង ដែលធ្វើឲ្យខ្ញុំគិតត្រឡប់ទៅដល់ទុក្ខលំបាកនៃការរស់នៅក្នុងអំឡុងពេលធ្លាក់ចុះរបស់កម្ពុជា នោះគឺរបបខ្មែរក្រហម ។ ភាពប៉ិនប្រសប់នៃការរំលេចនូវផ្ទៃនៃស្រទាប់របស់សមាសធាតុ រំឭកខ្ញុំអំពីភាពឥតខ្ចោះនៃសិល្បៈរបស់ស្នាដៃនេះ ព្រោះរូបចម្លាក់នេះស័ក្តិសមជាស្នាដៃបង្កើតថ្មី តាមរយៈគុណភាពនៃរូបរាងផ្ទាល់ ដែលបានបញ្ជាក់អំពីការវិវត្តនៃការប្រើប្រាស់សម្ភារ ។ ផ្នែកទាំងនេះត្រូវបានពិពណ៌នាយ៉ាងល្អិតល្អន់តាមរយៈរូបរាង ដែលមាននាទីជាព័ត៌មាននៃវត្ថុបំណងរបស់សិល្បៈករ ។ វត្ថុបំណងគឺជាគោលដៅនៃការដកពិសោធរបស់ស្នាដៃសិល្បៈ ។ បែបផែនសិល្បៈនៃរូបចម្លាក់នេះ មានលក្ខណៈអស្ចារ្យដោយសារតែគុណភាពនៃជំនាញដែលប្រើប្រាស់ដើម្បីសូន ចម្លាក់នេះឡើងអមជាមួយនឹងភាពប៉ិនប្រសប់ កម្រិតខ្ពស់ដែលចាំបាច់សម្រាប់ដំណាក់កាលដកពិសោធន៍នីមួយៗ នៅក្នុងអំឡុងពេលនៃការដំឡើង ។ រូបចម្លាក់នេះប្រៀបបានទៅនឹងស្ថាបត្យកម្មបែបសហសម័យដែរ ។ តម្លៃនៃកម្រិតរបស់ជំនាញផ្នែកគំនិតអរូបិយ ជំរុញឲ្យមានការដកពិសោធការរចនានៅក្នុងទំហំធំជាងមុន សមិទ្ធផលនឹងលេចឡើង ហើយរចនាបថផ្សេងៗត្រូវបានរួមផ្សំ ។ ត្រឡប់មករូបចម្លាក់នេះវិញ វាគឺជាកិច្ចខិតខំប្រឹងប្រែងដ៏ស៊ុតស្មុគស្មាញមួយ ព្រមទាំងជាការវិវត្តដ៏ប្រសើរ និងភាពកើនឡើងទ្វេនៃបច្ចេកទេសក្នុងការដំឡើង និងបង្កើតរូបចម្លាក់នេះឡើង ។ កិច្ចការទាំងនេះគឺជាបណ្តុំដ៏ស្មុគស្មាញ និងកម្រមួយដែលរួមបញ្ចូលនូវការផ្សារប្រកបដោយជំនាញខ្ពស់ ។

គុណភាពនៃជំហររបស់ចម្លាក់ គឺជាវិធីសាស្ត្រមួយក្នុងការរាយរាប់អំពីរឿងរ៉ាវរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម ។ យើងរាល់គ្នាបានដឹងហើយថា ការឆ្លងកាត់ពោរពេញដោយការលំបាកជីវិតមានភាពផុយស្រួយ ក៏ប៉ុន្តែអ្នកទាំងនោះនៅតែអាចបន្តរស់រាន

មកទល់ពេលបច្ចុប្បន្ន ។ អ្វីៗ នៅតែជាការចងចាំអំពីជីវិតដ៏ប្រថុយប្រថាន ។ ការរស់នៅពុំមានភាពស្ងប់សុខ ហើយខ្ញុំយល់ថា ភាពប្រថុយប្រថានគឺជាអត្ថន័យនៃជីវិត ។ ជីវិតដែលគ្មានភាពប្រថុយប្រថាន គឺមិនមានតម្លៃសម្រាប់ការរស់នៅទេ ។ ដូចគ្នាទៅនឹងរូបចម្លាក់នេះដែរ ចម្លាក់នេះស្ថិតនៅជិតរដ៏វៃឆ្លាតមួយដែលជាជិតរដែលគួរឲ្យព្រឺព្រួចបំផុត ឆ្ពោះទៅរកការធ្លាក់មកក្រោម ។

ចលនានៃចម្លាក់ គឺជាចំណុចគន្លឹះសម្រាប់មនុស្សក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងប្រវត្តិសាស្ត្រ ការចងចាំដែលអរូបិយ ក៏ប៉ុន្តែមនោសញ្ចេតនានៃរូបចម្លាក់ផ្ទាល់បង្កើតជាការសន្ទនាជាមួយនឹងអារម្មណ៍ និងព្រលឹងរបស់យើង ។ ជីវិតដែលពុំមានមនោសញ្ចេតនា គឺពុំមែនជាជីវិតទេ សូម្បីតែចិត្តរបស់យើងក៏មានមនោសញ្ចេតនា ។ ហេតុនេះ មនោសញ្ចេតនាមិនអាចទស្សន៍ទាយបាន វាគឺជាផ្នែកដ៏ចាំបាច់មួយក្នុងការណែនាំរូបចម្លាក់នេះទៅក្នុងទីសាធារណៈនៃទីក្រុងដែលប្រមូលផ្តុំដោយជីវិតនេះ ។ ចម្លាក់នេះមិនត្រឹមតែសម្រាប់អ្នកដែលបានឆ្លងកាត់ប្រវត្តិសាស្ត្រខ្មោងងឹងនេះប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏សម្រាប់អ្នកដែលរស់នៅទីតាំងនោះដែរ ។ បន្ថែមពីនេះទៅទៀត ការបង្ហាញពីគំនិតបង្កប់នេះ ផ្តល់ឲ្យយើងនូវការស្រមើស្រមៃ ដែលធ្វើឲ្យរូបចម្លាក់នេះមានភាពរស់រវើក មិនមែននឹងថ្កល់ ។ ចម្លាក់នេះអាចផ្តល់នូវភាពសុទិដ្ឋិនិយមដល់យើង ។ ដូចគ្នាទៅនឹងជីវិតដែរ ជីវិតមិនមែនត្រឹមតែសិល្បៈដែលតែងតែធ្វើឲ្យយើងញញឹមទេ ក៏ប៉ុន្តែធ្វើឲ្យយើងឈានទៅដល់ទីខ្មោងងឹតនៃប្រវត្តិសាស្ត្រដែលយើងបានឆ្លងកាត់ ។

ដូច្នេះ ខ្ញុំមានការពេញចិត្តយ៉ាងខ្លាំងចំពោះប្រភេទនៃស្រទាប់សម្ភារដែលប្រើប្រាស់ជំនាញប៉ិនប្រសប់នៃស្នាដៃសិល្បៈ គុណភាពចលនា និងមនោសញ្ចេតនា ដែលបានបង្ហាញនៅលើតួខ្លួនទាំងមូលរបស់រូបចម្លាក់ដែលបង្កើតជាការចាប់អារម្មណ៍សម្រាប់ខ្ញុំ និងធ្វើឲ្យខ្ញុំជឿជាក់ចំពោះស្នាដៃសិល្បៈបែបសហសម័យ ដែលអាចក្តោបយកបេះដូងរបស់មនុស្ស ។ រូបចម្លាក់នេះគឺជាសិល្បៈនៃការទាក់ទងដែលរៀបរាប់អំពីរឿងរ៉ាវ និងរឿងរ៉ាវដែលឆ្ពោះទៅកាន់ការចងចាំ ហើយការចងចាំគឺជាសមាសធាតុផ្សំមួយរបស់ជីវិត ។ រូបចម្លាក់នេះមិនត្រឹមតែសម្រាប់ការចងចាំទេ ក៏ប៉ុន្តែគឺសម្រាប់អ្នកទាំងឡាយណាដែលចងចាំអំពីយើង ។

## សូ វិទូៈ រចនាបថថ្មីប្លែកពីគេ

ខ្ញុំធ្លាប់បានឃើញស្នាដៃរបស់ ស៊ីវា មួង ក្នុងអំឡុងពេលតាំងពិព័រណ៍ ។ ផ្ទាំងគំនូរ និងចម្លាក់របស់គាត់ពិតជាស្នាដៃវិចិត្រកម្មមួយដែលបង្កប់ន័យទាក់ទងនឹងការចងចាំអំពីរបបខ្មែរក្រហម ។

សម្រាប់ខ្ញុំ ស្នាដៃចម្លាក់របស់ ស៊ីវា មានរចនាបថថ្មីប្លែកពីគេ និងជាមធ្យោបាយថ្មីមួយក្នុងការតំណាងឲ្យគំនិតនៃសិល្បៈ ។ ស្នាដៃនេះនឹងលេចរូបរាងនៅក្នុងទីក្រុងភ្នំពេញនាពេលឆាប់ៗនេះ ។ ចម្លាក់នេះមានលក្ខណៈសហសម័យ និងទំនើប ហើយមានភាពល្បីរន្ទឺនៅក្នុងពិភពលោកដោយសារតែចម្លាក់នេះជំរុញឲ្យការស្រមើស្រមៃរបស់មនុស្សឈានទៅរកភាពអរូបិយ និងគំនិតគ្មានដែនកំណត់ ។

ចម្លាក់នេះធ្វើអំពីស្ពាន់ ជារូបចម្លាក់នៃមនុស្សម្នាក់ដែលទម្រេតខ្លួនលើជើងទម្រស្ពាន់ ដោយរក្សានូវលំនឹងបានយ៉ាងល្អ ។ ចលនានៃចម្លាក់នេះហាក់ដូចជាបង្ហាញអំពីការឈឺចាប់ និងកំពុងស្នើនូវក្តីមេត្តាពីនរណាម្នាក់ ។ តាមរយៈការគ្របដណ្តប់ទៅដោយស្រទាប់រឹង និងពណ៌ស្រអាប់នៃសមាសធាតុផ្សំរបស់ចម្លាក់ ខ្ញុំគិតថា ចម្លាក់នេះតម្រូវឲ្យមានការចំណាយពេល និងបទពិសោធន៍អមជាមួយនឹងភាពអត់ធ្មត់ដើម្បីសម្រេចបាន ។

ការងាររបស់ ស៊ីវា បាននាំអ្នកទស្សនាទៅក្នុងស្ថានភាពនៃការឈឺចាប់ និងការចងចាំមួយរបស់ជាតិអំពីអំឡុងរបបខ្មែរក្រហម ជាពិសេសការក្តោបក្តាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ នៅពេលនោះ ខ្មែរក្រហមដែលទទួលបានជ័យជម្នះបានគ្រប់គ្រងលើទីក្រុងភ្នំពេញ ព្រមទាំងធ្វើការរៀបចំសង្គមកម្ពុជាសាជាថ្មី ។ ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនចាកចេញពីទីក្រុង ដោយហិង្សា ។ រូបចម្លាក់នេះធ្វើការបកស្រាយយ៉ាងច្បាស់អំពីផ្នត់គំនិតអំពើហិង្សា និងទុក្ខសោក នាខណៈពេលនោះ ។

ចំណុចដំបូងបង្អស់ដែលទាក់ទាញការចាប់អារម្មណ៍របស់ខ្ញុំ គឺ ចលនា និងលំនឹងនៃរូបចម្លាក់នេះ ។ ខ្ញុំយល់ថា សិល្បៈករប៉ុនប៉ងបង្ហាញអំពីរូបភាពជាក់ស្តែងនៃចលនាដងខ្លួន ដែលបង្ហាញដល់អ្នកទស្សនាអំពីអារម្មណ៍ឈឺចាប់ និងការសំពះអង្វរសុំក្តីមេត្តា ។ ខ្ញុំចាប់អារម្មណ៍ចំពោះភាពលម្អិតនៃស្រទាប់ស្ពាន់ តាមការយល់ឃើញផ្ទាល់ខ្លួន ស្រទាប់នេះត្រូវបានគួបផ្សំទៅដោយខ្សែបន្ទាត់ ចំណុច

តូចៗ និងខ្សែពត់ពេន ធាតុទាំងនេះបានបង្កើតជាស្រទាប់បង្កប់ និងយ៉ាងល្អិតៗ ដែលហាក់ដូចជាក្តោបនូវការចងចាំនៃរូបចម្លាក់ផ្ទាល់ ។

ខ្ញុំយល់ថា ស៊ីរា បាននាំយកនូវអ្វីដែលតំណាងឲ្យការចងចាំរបស់ទីក្រុងភ្នំពេញ ខណៈដែលបុគ្គលនីមួយៗស្ទើរតែភ្លេចអស់បាត់ទៅហើយ ។ ខ្ញុំមានការជឿជាក់ប្រកបដោយសុទិដ្ឋិនិយមថា ខណៈដែលរូបចម្លាក់នេះត្រូវបានដំឡើងនៅទីតាំងរបស់ខ្លួន មនុស្សជាច្រើនប្រាកដជាមានការចាប់អារម្មណ៍ ហើយរូបចម្លាក់នេះនឹងក្លាយជាស្នាដៃនៃការចងចាំមួយ ដែលរំឭកយើងទាំងអស់គ្នាអំពីសម័យកាលដ៏ខ្មៅងងឹតរបស់ប្រទេសកម្ពុជា ។ ខ្ញុំក៏សង្ឃឹមថានឹងមានស្នាដៃ ឬរូបចម្លាក់ប្រភេទនេះជាច្រើនទៀត លេចរូបរាងនៅក្នុងទីក្រុងរបស់ខ្ញុំ គឺទីក្រុងភ្នំពេញ ។

***សៀង សត្យាៈ បណ្តែតខ្លួនក្នុងលំហ***

កាលពីប៉ុន្មានខែមុន រូបចម្លាក់មួយនេះរបស់ ស៊ីរា ត្រូវបានស្នូនជារូបរាងក្នុងទំហំជាក់ស្តែង ដើម្បីដាក់តម្កល់នៅទីសាធារណៈ សម្រាប់ជាការរំឭក ។ ខ្ញុំបានទៅទស្សនាការតាំងពិព័រណ៍អំពីស្នាដៃសិល្បៈរបស់គាត់ នៅឯមជ្ឈមណ្ឌលបារាំងប្រចាំនៅកម្ពុជា ។ ស្នាដៃភាគច្រើនរបស់គាត់រំឭកដល់ការចងចាំនៃអំឡុងពេលខ្មៅងងឹតរបស់ប្រវត្តិសាស្ត្រកម្ពុជា នោះគឺរបបខ្មែរក្រហម និងការចងចាំកាលពីកុមារភាពរបស់គាត់អំពីសម្បត្តិវប្បធម៌ខ្មែរ ។

នៅពេលដែលខ្ញុំបានឃើញទំហំជាក់ស្តែងនៃចម្លាក់ ដែលត្រូវបានដុសខាត់ដើម្បីទទួលបានលទ្ធផលសម្រេច នៅក្នុងរោងជាងក្នុងស្រុកមួយក្នុងខេត្តសៀមរាប ជាលើកដំបូង ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយសារតែលំនឹងនៃទ្រង់ទ្រាយរបស់រូបចម្លាក់ ក៏ដូចជាស្រទាប់ស្ពាន់គ្រើមនៃរូបចម្លាក់ ។

ដូចទៅនឹងស្ថាបត្យកម្មដែរ តុល្យភាពមានតួនាទីសំខាន់ណាស់ក្នុងការបង្ហាញនូវគោលបំណងនៃវត្ថុក្នុងលំហមួយ ។ ខ្ញុំយល់ថា រូបចម្លាក់របស់ ស៊ីរា ពិតជាស្ថិតនៅត្រង់ចំណុចដ៏សមស្របមួយ ។ ផ្នែកទម្រេតចុះនៃចលនារបស់រូបចម្លាក់នេះ បង្ហាញអំពីភាពចលាចល និងច្របូកច្របល់ ចម្លាក់នេះបង្កើតឲ្យមានអារម្មណ៍ឈឺចាប់ ការព្រួយបារម្ភ ភាពភ័យខ្លាច ដែលធ្វើឲ្យខ្ញុំយល់ថាស្មុគស្មាញ ។ អារម្មណ៍ច្របូកច្របល់ជាច្រើនស្ថិតនៅក្នុងការគិតរបស់ខ្ញុំ ហើយខ្ញុំពុំអាចផ្ចង់ស្មារតីបាន ។ ខ្ញុំព្យាយាមតាំងខ្លួនខ្ញុំនៅក្នុងស្ថានភាពនៃរូបចម្លាក់នេះ នៅក្នុងស្ថានភាពដែលតម្រូវឲ្យខ្ញុំបណ្តែតខ្លួនក្នុងលំហ តាមរយៈកាយវិការនៃរូបចម្លាក់ ខ្ញុំស្រមៃដល់ខណៈពេលមួយដែលខ្ញុំពុំមានកម្លាំង ពុំមានអាវុធដើម្បីប្រយុទ្ធតបត ពុំមានសមត្ថភាពដើម្បីរត់គេចពីការបំពានលើសិទ្ធិរស់រានរបស់ខ្ញុំ អ្វីដែលខ្ញុំមានគឺត្រឹមតែដៃទទេមួយគូ ដែលប្រណមឡើងអង្វរសុំក្តីមេត្តា ។

ទន្ទឹមនឹងនេះ ស្រទាប់គ្រើមនៃស្ពាន់បង្កើតបានជាស្រទាប់ដែលនឹងស្មានមិនដល់មួយ ។ រំពេចនោះ ខ្ញុំយល់ថា ស្រទាប់ក្រៅនេះតែងប្រែប្រួលជានិច្ច ចំណុចនេះហើយដែលធ្វើឲ្យស្នាដៃសិល្បៈនេះប្លែកពីគេ និងលេចធ្លោ ។ ដូចទៅនឹងផ្ទាំងគំនូររបស់គាត់ដែរ ភាពទាក់ទាញនៃស្រទាប់ បង្កើតជាអារម្មណ៍អន្ទាញអន្ទងចុះឡើង ពោលគឺពុំមានចំណុចបញ្ចប់ និងចំណុចចាប់ផ្តើម ។

រូបចម្លាក់នេះពិតជាបានរំលេចឲ្យមនុស្សឃើញអំពីរូបភាពនៃព្រឹត្តិការណ៍សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា ដែលបង្កឲ្យជនរងគ្រោះប្រមាណ២លាននាក់បាត់បង់ជីវិត នោះគឺរបប ប៉ុល ពត ។ រូបចម្លាក់នេះបង្ហាញអំពីភាពអាណិតអាសូរ និងការផ្សះផ្សាអំពីប្រវត្តិសាស្ត្រនៃសោកនាដកម្មរបស់ប្រទេសកម្ពុជា ។ ខ្ញុំជឿជាក់ថា ការស្រមើស្រមៃគឺជាអាហារនៃគំនិត យើងតែងមានការស្រេកឃ្លាន ដូច្នេះ ខ្ញុំរំពឹងថា រូបចម្លាក់នេះនឹងនាំមកនូវអ្វីដែលសង្គមនេះខ្វះខាតដោយពុំដឹងខ្លួន ក៏ដូចជាសម្រាប់មនុស្សជំនាន់ក្រោយដែលមានចំណង់ផ្នែកគំនិតច្នៃប្រឌិត ការស្រមើស្រមៃ និងសិល្បៈ ។

សរុបសេចក្តីមក ខ្ញុំមានការជឿជាក់យ៉ាងមុតមាំថា រូបចម្លាក់នៃការចងចាំនេះ នឹងរំឭកអំពីការចងចាំនៃអ្នកទាំងឡាយដែលបានបាត់បង់មនុស្សជាទីស្រឡាញ់របស់ខ្លួននៅក្នុងរបបខ្មែរក្រហម ក៏ដូចជាឧទ្ទិសដល់អ្នកទាំងឡាយដែលលែងមានវត្តមាននៅទីនេះទៀតហើយ ។ ជាជាងការរំឭកអំពីភាពព្រឺព្រួចនៃពេលវេលាដ៏ខ្មៅងងឹតទាំងនោះ រូបចម្លាក់នៃការចងចាំនេះ ធ្វើឲ្យអ្នកដើរឆ្លងកាត់មានអារម្មណ៍អាណិតអាសូរ និងក្តីសង្ឃឹមសម្រាប់អនាគតដ៏សុខដុមមួយ ដោយមិនបំភ្លេចអំពីអតីតកាល ។

**យ៉េង សិរីរ័ត្ន, សូ ទិទ្ធ និង សៀង សត្យា**

# «សល់មួយគ្រាប់»

## រឿងរ៉ាវ គ្រួសារខ្ញុំ ក្នុងរបបដឹកនាំខ្មៅងងឹត

***(តពីលេខមុន)***

### ការត្រឡប់ទៅផ្ទះកំណើតម្ដងទៀត

មកដល់ភ្នំពេញ ខ្ញុំមិនបាន ប្រញាប់ រកអ៊ុំស្រី ខាងម្ដាយ ពីរគ្រួសារទៀត ដូចបានប៉ងពីមុនទេ ។ ពូ ដែលរួមដំណើរជាមួយបាននាំខ្ញុំទៅរស់នៅស្រុកកំណើតរបស់គាត់ ។ ក្រោយមក ខ្ញុំសុំគាត់មកភ្នំពេញដើម្បីបន្តការរៀនសូត្រ ។

ខ្ញុំចាប់ផ្ដើមស្វែងរកអំឡុង ដើមឆ្នាំ១៩៩០ ពេលដែលនយោបាយនៅកម្ពុជាមានការធូរស្រាលខ្លះ ។ មានការចាប់ផ្ដើមចរចារកដំណោះស្រាយ សន្តិភាពរវាងនាយករដ្ឋមន្ត្រី ហ៊ុន សែន តំណាងឲ្យរដ្ឋកម្ពុជា និងសម្ដេច នរោត្ដម សីហនុ តំណាងឲ្យក្រុមតស៊ូត្រីភាគី ។ ខ្ញុំសប្បាយចិត្តណាស់ កោតសរសើរ ដោយគោរពដល់ថ្នាក់ដឹកនាំខ្មែរ ដែលធ្វើការដោះស្រាយដើម្បីជាតិ ។ ខ្ញុំបានចាប់ផ្ដើមតាមដានសភាពការណ៍ស្រុកទេសតាមរយៈទូរទស្សន៍ហើយពេញចិត្តនឹងសកម្មភាពនាយករដ្ឋមន្ត្រី ហ៊ុន សែន យ៉ាងខ្លាំង ។

ខ្ញុំបានរកឃើញសាច់ញាតិខាងម្ដាយខ្ញុំ ចុងឆ្នាំ១៩៩០ ។ ដឹងថាគាត់បានទៅរស់នៅស្រុកបារាំងហើយ គឺតាមរយៈគ្រួសារសាច់ថ្លៃរបស់ពួកគាត់រស់ដែលរស់នៅស្រុកខ្មែរ ផ្ដល់អាសយដ្ឋានរបស់អ៊ុំខ្ញុំទាំងពីរគ្រួសារនៅបារាំង ។

ខ្ញុំមិនបានត្រលប់ទៅខេត្តពោធិ៍សាត់វិញភ្លាមៗទេ រហូតដល់ខ្ញុំបានរៀនចប់ មានការងារធ្វើត្រឹមត្រូវ ។ លើកទីពីរដែលខ្ញុំត្រលប់ទៅឃើញផ្ទះម្ដងទៀត ក្នុងឆ្នាំ១៩៩២ ។ ខ្ញុំគ្រាន់តែមើលពីចម្ងាយ ។ ខ្ញុំនូវមានការភ័យខ្លាចក្នុងការនិយាយប្រាប់គេថាជាផ្ទះរបស់ខ្ញុំ ។ ទើបតែក្រោយបោះឆ្នោតឆ្នាំ១៩៩៣ទេ ដែលខ្ញុំហ៊ាននិយាយជាថ្មីម្ដងទៀតថាផ្ទះនោះធ្លាប់ជាផ្ទះរបស់ខ្ញុំ ។ ពាក្យពេចន៍របស់ខ្មែរក្រហមដែលនិយាយថា «ដកស្មៅត្រូវដកទាំងឬស» នៅដក់ជាប់នៅក្នុងខួរក្បាលរបស់ខ្ញុំនៅឡើយនៅពេលនោះ ។

ឆ្នាំ១៩៩២ ផ្ទះខ្ញុំ បានប្រើធ្វើជាសាលាឃុំផ្ទះព្រៃ ។ សព្វថ្ងៃនេះ ផ្ទះរបស់ខ្ញុំត្រូវបានគេយកធ្វើជាទីស្នាក់ការកងរាជអាវុធហត្ថ ខេត្តពោធិ៍សាត់ ។ ផ្ទះនេះស្ថិតនៅក្នុងសភាពមិនស្អាតដូចមុនទេ ស្រះទាំងពីរនៅមុខផ្ទះ ត្រូវគេលប់ដីពេញ ។ មិនមានដាំដើមឈើច្រើន និងសួនផ្កា ដូចពីមុនទៀតទេ ។ ផ្ទះថ្មចាស់ វាយកម្ទេចចោល បាត់ឃ្លាំងស្ដុកស្រូវ បាត់ផ្ទះឈើបុរាណ ។ បច្ចុប្បន្នមានការសាងសង់អគារថ្មីៗជំនួស មានសង់ក្លោងទ្វារថ្មី ចាក់លុបដីបន្ថែមក្នុងបរិវេណផ្ទះ ។ កាលពីមុនមានផ្ទះតែបួន ខ្នងប៉ុណ្ណោះនៅចន្លោះស្ពានដែកទាំងពីរ ។ ប៉ុន្តែ សព្វថ្ងៃនេះ មានផ្ទះ និងមនុស្សជាច្រើនមករស់នៅនៅចន្លោះស្ពានទាំងថ្មទាំងពីរវិញ ។

សកម្មភាពឡូតដ្ឋក៏បានចាប់ដំណើរការឡើងវិញ ប៉ុន្តែវាច្បាស់ណាស់ថាវាលែងជាកម្មសិទ្ធិគ្រួសារខ្ញុំទៀតហើយ ។ ខ្ញុំជាមនុស្សតែម្នាក់គត់ដែលបានរស់រានមានជីវិតនៅក្នុងគ្រួសាររបស់ខ្ញុំ ។ ហេតុអ្វីខ្ញុំគ្មានសិទ្ធិយកទ្រព្យសម្បត្តិដែលជារបស់ខ្ញុំមកវិញបាន? វាគួរណាស់តែខ្ញុំអាចយកមកវិញបាន ។ ខ្ញុំចង់យកផ្ទះដែលជាទ្រព្យរបស់ក្រុមគ្រួសារខ្ញុំមកវិញ ។ វាប្រហែលជាអាចជួយឲ្យខ្ញុំបានធូរស្បើយខ្លះ ។

### ការឈឺចាប់

ខ្ញុំមានការសោកស្ដាយណាស់ ដែលខ្ញុំមិនអាចជួយបងប្អូនខ្ញុំណាម្នាក់បានសោះ ។ ខ្ញុំមានអារម្មណ៍ថាខ្លួនឯងអសមត្ថភាពមិនអាចជួយសូម្បីតែប្អូនស្រី ដ៏តូចរបស់ខ្លួន ។ រឿងរ៉ាវទាំងអស់នេះខ្ញុំមិនអាចបំភ្លេចបានទេ ហើយវាឋិតនៅក្នុងខួរក្បាលខ្ញុំរហូត ។ ខ្ញុំតែងតែលាក់វា ដោយការឈឺចាប់ក្រៃលែង ទុកក្នុងខ្លួនរហូតមិនដែលរៀបរាប់ប្រាប់នរណាគេទេ ។

ដើម្បីកុំឲ្យគេសម្លាប់ ខ្ញុំខិតខំលាក់ប្រវត្តិរូបរបស់ខ្ញុំផងដែរ ពីព្រោះខ្ញុំមានការភ័យខ្លាចថាមានការគុំគួនសម្លាប់ ធ្វើបាបពីរបបកុម្មុយនីស្ត ។ ដូចដែលយើងធ្លាប់បានឮសូរនៅក្នុងជំនាន់ ប៉ុល ពត រួចហើយ ។ ពេលគេដកស្មៅ គេត្រូវដកទាំងឬស ដើម្បីកុំឲ្យស្មៅវា

ដុះបានទៀត ។

ខ្ញុំបានសាងសង់ចេតិយមួយនៅក្នុងវត្តព្រះពុទ្ធសម្រាប់ឧទ្ទិសដល់ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំ ។ វាគ្រាន់តែធ្វើឡើងជាតំណាងតែប៉ុណ្ណោះ ។ ដោយសារតែមិនមានតម្កល់ធាតុអ្វីទេ ។ ប៉ុន្តែខ្ញុំបានសរសេរឈ្មោះឪពុកម្តាយខ្ញុំនៅទីនោះ ។ ខ្ញុំតែងទៅទីនោះដើម្បីស្មឹងស្មាធនៅពេលមានបុណ្យសាសនាផ្សេងៗដូចជាបុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌ ។ ខ្ញុំទៅអុជធូប សំអាតចេតិយ និងនិមន្តព្រះសង្ឃសូត្រធម៌ដើម្បីឲ្យបានជាកុសលទៅដល់ព្រលឹងបងប្អូនខ្ញុំដែលបានបាត់បង់ជីវិតទៅ ។

ខ្ញុំមិនបានជួយនរណាម្នាក់ទាល់តែសោះនៅក្នុងគ្រួសារខ្ញុំ ។ ខ្ញុំមិនដែលមានឱកាសផ្តល់អ្វីទាល់តែសោះឲ្យឪពុកម្តាយខ្ញុំ សូម្បីតែនំចំណីអាហារមួយម៉ាត់ ។ ខ្ញុំមានវិប្បដិសារីដែលមិនអាចធ្វើអ្វីតបស្នងដល់ឪពុកម្តាយ និងបងប្អូន ។ ឧទាហរណ៍ពេលដែល គាត់ឈឺជាដើម ខ្ញុំគួរណាស់តែអាចនៅជិតខិតខំមើលថែទាំគាត់ ។

ដូច្នេះ ខ្ញុំមានតែការខិតខំប្រឹងធ្វើការទាំងលំបាកនឿយហត់គ្រប់បែបយ៉ាង ។ ដោយខ្ញុំសង្ឃឹមទុកថា ប្រសិនបើជាតិក្រោយមានមែនពិត ។ ខ្ញុំនឹងអាចជួបក្រុមគ្រួសារខ្ញុំជាថ្មីម្តងទៀត ។ ខ្ញុំសូមឧទ្ទិសបុណ្យកុសលនៃអំពើល្អរបស់ខ្ញុំទាំងប៉ុន្មានដែលបានសាងឲ្យបានដល់ឪពុកម្តាយ និងគ្រួសាររបស់ខ្ញុំ ។

ខ្ញុំមិនដែលមានចិត្តគំនិតគុំគួននឹងអ្នកដែលបានសម្លាប់ឪពុកម្តាយខ្ញុំទេ ។ ខ្ញុំនឹងមិនចងពៀរពួកគេវិញទេ ។ ខ្ញុំបានដឹកនាំគម្រោងធំៗ និងសកម្មភាពជាច្រើន ទៅជួយដល់តំបន់ក្រីក្រ និងតំបន់ដែលខ្ញុំធ្លាប់ឆ្លងកាត់ក្នុងរបប ប៉ុល ពត ។ ដើម្បីឲ្យគេទាំងនោះរៀនធ្វើអំពើល្អ និងឲ្យគេយល់ដឹងការអភិវឌ្ឍសង្គមពិតប្រាកដ ។

ខ្ញុំមានអារម្មណ៍ថាត្រូវបានគេបន្តធ្វើការវិនិច្ឆ័យដាក់ទោសដល់មនុស្សទាំងឡាយណា ដែលបានធ្វើការបម្រើឲ្យរបប លន់ នល់ ដោយមិនទាន់បានរកយុត្តិធម៌ ។ គ្រួសាររបស់ខ្ញុំត្រូវបានបាត់បង់ជីវិតទាំងអយុត្តិធម៌ ។ សម្រាប់ខ្ញុំ វាជារឿងអយុត្តិធម៌ទ្វេដង ។ អ្នកធ្វើការឲ្យ របប លន់ នល់ បានប្រឆាំងពួកខ្មែរក្រហម ។ ពួកទាហាន លន់ នល់ ត្រូវបានសម្លាប់ដោយពួកខ្មែរក្រហម ។ ពួកទាហាន លន់ នល់ គេបានបន្ទោសថាជាអ្នកបានផ្តួលរំលំរបបសីហនុ ។ ខ្ញុំសួរខ្លួនឯងថា តើគ្រួសារខ្ញុំមានបានធ្វើអ្វីខុស ?

សព្វថ្ងៃនេះ ខ្ញុំព្យាយាមមិនលាតត្រដាងក្តីកង្វល់របស់ខ្ញុំទេ ប៉ុន្តែ ក្នុងជម្រៅចិត្តខ្ញុំផ្ទាល់ ខ្ញុំមិនអាចបំភ្លេចបានទេ នូវអ្វីដែលបានកើតមានឡើងក្នុងរបបខ្មែរក្រហម ។ ខ្ញុំក៏មិនដឹងថាធ្វើយ៉ាងណាដែរដើម្បីបំភ្លេចរឿងរ៉ាវទាំងនោះ ។

អនុស្សាវរីយ៍ជូរចត់ទាំងអស់នោះហាក់ដូចជានៅដក់ជាប់ក្នុងការចងចាំរបស់ខ្ញុំជារៀងរហូត ។ខ្ញុំបានព្យាយាមធ្វើយ៉ាងណាឲ្យរឿងរ៉ាវទាំងនោះជ្រុះចេញពីខ្លួនខ្ញុំ ។ ប៉ុន្តែវាមិនព្រមចេញទៅណាសោះពីអារម្មណ៍ខ្ញុំ ។

ខ្ញុំមិនអាចបំភ្លេចការឈឺចាប់ដែលខ្ញុំបានឆ្លងកាត់នេះបានទេ ។ ពេលខ្លះខ្ញុំនឹកឃើញវានៅពេលយប់ ខ្ញុំយំដោយមិនដឹងខ្លួននៅនឹកឃើញវានូវឡើយ ។ ខ្ញុំជាអ្នករួចរស់ជីវិតតែម្នាក់គត់ក្នុងគ្រួសាររបស់ខ្ញុំ ហើយខ្ញុំអសមត្ថភាពជួយក្រុមគ្រួសារខ្ញុំ គឺដោយសារតែមូលហេតុនេះហើយដែលធ្វើឲ្យខ្ញុំឈឺចាប់កាន់តែខ្លាំង ។ ខ្ញុំមិនអាចរស់នៅឲ្យសប្បាយអស់ពីពោះនោះទេ ។ នៅពេលដែលខ្ញុំសើច វាមិនដែលឲ្យបានទាំងស្រុងអស់ពីពោះពីពុងទេ ។ មែនទែនទៅវាហាក់ដូចជាខ្ញុំមានអ្វីទប់មិនឲ្យសប្បាយអស់ ។

ខ្ញុំមិនមានភាពរីករាយដូចអ្វីដែលអ្នកដទៃគេមានទេ ។ ខ្ញុំនូវបន្តឃើញរូបភាពនៅក្នុងរបបខ្មែរក្រហមនៅពេលដែលខ្ញុំធ្មេចភ្នែក ។ អាការៈបែបនេះកើតឡើងយ៉ាងទៀងទាត់ ។ រឿងគ្រប់បែបយ៉ាងដក់នៅក្នុងខួរក្បាលខ្ញុំទាំងអស់ ហើយអាការៈនេះទៀតសោតវាកើតឡើងដោយឯកឯងតែម្តង ។ ឧទាហរណ៍ដូចជាពេលដែលខ្ញុំឃើញអ្នកដទៃរស់នៅជួបជុំគ្រួសារជាដើម នៅពេលដែលឃើញបែបនេះ វាធ្វើឲ្យខ្ញុំនឹកគិតទៅដល់គ្រួសារខ្ញុំផ្ទាល់ ។

តាមរយៈការធ្វើការនេះ ធ្វើការនោះ និងធ្វើឲ្យខ្លួនឯងរវល់រហូត គឺជាមធ្យោបាយ ដែលខ្ញុំខំព្យាយាមបំភ្លេច ។ ខ្ញុំក៏ខិតខំរៀនផងដែរនូវការអប់រំចិត្តតាមបែបព្រះពុទ្ធសាសនាដើម្បីអាចឲ្យខ្ញុំបំភ្លេចរឿងរ៉ាវដែលកើតឡើងបាន ។

ពេលខ្លះ ខ្ញុំលើកយកផ្នែកខ្លះៗនៃរឿងរ៉ាវរបស់ខ្ញុំមកនិយាយជាមួយមិត្តភក្តិខ្ញុំ ។ ប៉ុន្តែ ខ្ញុំមិនដែលបាននិយាយឲ្យបានលម្អិតដូចពេលនេះទេ ។

ខ្ញុំបានចាប់ផ្តើមលាតត្រដាងអត្តសញ្ញាណរបស់ខ្ញុំនៅក្រោយការមកដល់របស់អង្គការសហប្រជាជាតិ នៅ១៩៩៣ ដែលពីមុន

មក ខ្ញុំមិនដែលបានលាតត្រដាងឡើយ ។

ពេលខ្លះទៀត ខ្ញុំក៏បាននិយាយរឿងខ្ញុំឲ្យកូនៗរបស់ខ្ញុំស្ដាប់ដែរ ប៉ុន្តែពួកគេហាក់ដូចជាមិនជឿថាវាជាការពិតទេ ។ ឧទាហរណ៍ដូចជាពេលដែលខ្ញុំនិយាយថាខ្ញុំធ្លាប់អត់មានអីហូប ពួកគេគិតថាវាមិនមែនជាការពិតទេ ។ ពេលដែលខ្ញុំប្រាប់ថាមានការកាប់សម្លាប់មនុស្ស កូនប្រុសខ្ញុំឆ្លើយថា "ចុះហេតុអ្វីក៏មិនតបតវិញ?" រឿងខ្លះទៀត គេសើចពេលដែលខ្ញុំនិយាយប្រាប់គេ ។

ខ្ញុំបាននិយាយរឿងរ៉ាវរបស់ខ្ញុំខ្លះៗដែរជាមួយប្រពន្ធរបស់ខ្ញុំ ប៉ុន្តែមិនដែលបាននិយាយសាច់រឿងឲ្យអស់ន័យសេចក្ដីទេ ។ ខ្ញុំធ្លាប់ប្រាប់គាត់ថាផ្ទះរបស់ខ្ញុំនៅទីកន្លែងណាថា ខ្ញុំធ្លាប់រស់នៅកន្លែងណាកាលពីមុនរបបខ្មែរក្រហម ។ ប្រពន្ធខ្ញុំក៏បានរស់នៅឆ្លងកាត់របបខ្មែរក្រហមដែរ ។ កាលនោះ គាត់រស់នៅក្នុងខេត្តកំពង់ចាម ។ ប៉ុន្តែ គ្រួសារខាងប្រពន្ធខ្ញុំមិនបានបែកខ្ញែកគ្នាខ្លាំងឲ្យដូចជាគ្រួសារខាងខ្ញុំ ។

ចំពោះខ្ញុំផ្ទាល់ ខ្ញុំមិនមានគំនិតសងសឹកជាមួយនឹងអ្នកណាទេ ។ ខ្ញុំគ្រាន់តែចង់ឲ្យប្រជាពលរដ្ឋអត់ឱនឲ្យគ្នារួបរួមគ្នា ។ ឲ្យមេដឹកនាំគិតគូរដល់ផលប្រយោជន៍ជាតិ ស្រឡាញ់ជាតិខ្លួនឯងជាធំ ។

ខ្ញុំចង់ឲ្យអ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋនេះប្រាប់ទៅដល់ក្មេងជំនាន់ក្រោយថាតើដោយសារហេតុអ្វី? បានជាពួកគេបានប្រព្រឹត្តនូវអំពើសាហាវយង់ឃ្នងដែលគេបានធ្វើកន្លងមកនេះ? ។ បើតាមចាស់ៗនិយាយ គេថាគោលបំណងរបស់ខ្មែរក្រហមគឺដើម្បីដេញកងទ័ពវៀតណាមដែលបានឈ្លានពានចូលមកក្នុងទឹកដីខ្មែរនៅក្នុងជំនាន់សីហនុ ហើយពុំព្រមចាកចេញទៅវិញ ។ ប៉ុន្តែតាមការពិត អ្នកដែលស្លាប់គឺសុទ្ធសឹងតែប្រជាជនខ្មែរ ។

ខ្ញុំចង់ឲ្យសហគមន៍អន្តរជាតិផ្ដល់យុត្តិធម៌ជូនពលរដ្ឋកម្ពុជា ។ ពីព្រោះបើគ្មានយុត្តិធម៌ទេ គឺអ្នកទន់ខ្សោយជាអ្នកទទួលរងគ្រោះ ហើយសង្គមនៅតែបន្តបែកបាក់ ។ គេនៅតែបន្តយកគំរូអាក្រក់ពីសម័យខ្មែរក្រហម មកអនុវត្តពីកន្លែងមួយទៅកន្លែងមួយទៀតតាមនយោបាយដ៏ទុច្ចរិត ។

នៅក្នុងប្រទេសកម្ពុជា ព័ត៌មានត្រូវបានគេកែប្រែ មេដឹកនាំខ្លះ បំបែកប្រជាជនជាបក្ស ជាពួក លាបពណ៌ ធ្វើឲ្យជាតិខ្សោះកម្លាំង ។ បុគ្គលម្នាក់ៗរៀនចេះនូវគំនិតសួនតួ ហើយគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គេ ។ អាក្រក់ទៅជាល្អ សទៅជាខ្មៅ ។

ខ្ញុំចង់មានមេដឹកនាំណា ដែលស្រឡាញ់ប្រជាពលរដ្ឋខ្លួន ដែលជួយឲ្យយើងយល់បានពីប្រវត្តិសាស្ត្រពិតប្រាកដ ។ ថាហេតុអ្វីបានជាប្រជាជនខ្មែរត្រូវបានគេសម្លាប់ ។ ដោយវិធីណា ដែលគំនិតឆ្កួតលីលានោះបានកើតឡើង? ។

ប្រវត្តិសាស្ត្រត្រូវតែពិត ។ ដើម្បីឲ្យក្មេងៗអាចរៀនចេះដឹងបាន ឲ្យគេស្គាល់ប្រវត្តិសាស្ត្រច្បាស់ និងដើម្បីកុំឲ្យសុបិនអាក្រក់នោះកើតឡើងជាថ្មីម្ដងទៀតឲ្យសោះ ។

ខ្ញុំក៏មានបំណងចង់ឲ្យមានការសាងសង់ស្តូបមួយដ៏ធំ ដើម្បីជាការរចង់ចាំ និងឧទ្ទិសដល់អ្នកដែលបានស្លាប់ទាំងអស់ ក្នុងខេត្តណាមួយ ហើយខ្ញុំក៏ចង់ឲ្យមានមូលនិធិចងចាំអ្នកដែលស្លាប់ សម្រាប់បង្កើតជាមជ្ឈមណ្ឌលប្រើប្រាស់លើការងារផ្សព្វផ្សាយសន្តិភាព និងអភិវឌ្ឍន៍ចំណេះដឹង ជំនាញដល់ក្មេងជំនាន់ក្រោយ ។ **(នៅមានត)**

**ហែម សុវណ្ណារិទ្ធិ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.d.dccam.org*

# «សារភាពណ៍»

## មុនឆ្នាំ១៩៧៥

ខ្ញុំកើតនៅឆ្នាំ១៩៧០ អំឡុងខែខសភា ។ ឪពុកខ្ញុំជាកម្មកររោងចក្រក្រចៅតម្បាញដូនទាវ ។ គាត់ស្លាប់មុនរបបខ្មែរក្រហមចូលភូមិមួយអាទិត្យ ។ ខ្ញុំមិនដឹងគាត់កើតជំងឺអ្វីទេ គ្រាន់តែឮអ៊ំស្រីខ្ញុំតំណាលថា ពេលគាត់ជួសជុលដំបូលផ្ទះ ដើម្បីឲ្យបងប្អូនភៀសខ្លួនពី ត្រើយម្ខាង (ផ្សារខ្ពប) ស្នាក់នៅពេលគេចពីគ្រាប់កាំភ្លើង ។ ឪពុកខ្ញុំចាប់ផ្តើមចុកទ្រូងយ៉ាងខ្លាំង ។ ក្រោយពេលបញ្ជូនទៅដល់មន្ទីរពេទ្យបានមួយយប់ គាត់ក៏ផុតដង្ហើម ។

អ៊ំស្រីខ្ញុំប្រាប់ថា គាត់មិនចូលចិត្តខ្មែរក្រហមទេ គាត់ដឹងថាពួកនេះ បើបានជ័យជម្នះហើយ នឹងបំបែកកូនចៅ ឪពុកម្តាយមិនឲ្យនៅជុំគ្នាទេ ប៉ុន្តែពេលនោះគ្មាននរណាម្នាក់ជឿគាត់ទេ ម្នាក់ៗយល់ថា ខ្មែរក្រហមស្អាតស្អំ មិនពុករលួយ សូម្បីតែគេចង់បានម្ជុល គេមិនបេះយកទទេៗទេ គឺគេតែងចងលុយទុកនឹងដើម ប្រសិនបើម្ចាស់មិននៅ ។

ផ្ទះរបស់ខ្ញុំកាលណោះ នៅខាងក្រោយវត្តស្វាយជ្រុំ តែឥឡូវដីមួយជួរនោះ ក្លាយជាបញ្ជាការអាវុធហត្ថ និងសាលាស្រុកហើយ ។ ខ្ញុំនៅចាំបានថា មានយប់មួយអ្នកភូមិផ្អើល រត់ចូលវត្តគេចពីការបាញ់គ្នា ។ ឪពុកខ្ញុំបានពរខ្ញុំចូលក្នុងបរិវេណវត្តដែរ ។ ខ្ញុំឆ្ងល់ថា ហេតុអ្វីបានជានាំគ្នារត់ចូលវត្ត បើវត្តនិងផ្ទះខ្ញុំនៅម្ខាងផ្លូវម្នាក់នោះ ។ បងស្រីខ្ញុំប្រាប់ថា ពេលនោះ តាមវាលស្រែជាប់ព្រៃរនាម ក៏មានយន្តហោះមកទម្លាក់គ្រាប់បែកដែរ ។

ពេលខ្មែរក្រហមវាយសម្រុកខ្លាំង គ្រួសារខ្ញុំ និងអ្នកភូមិមួយចំនួននាំគ្នាភៀសខ្លួន ទៅពួនតាមដងអូរ ។ ម្តាយខ្ញុំប្រាប់ថា កាលណោះ ខ្មែរក្រហមចាប់ផ្តើមវាយសម្រុកខ្លាំង មកត្រើយខាងកើតស្ទឹង ។ ខ្ញុំមិនដឹងថា រយៈពេលប៉ុន្មានថ្ងៃទេ ដែលគ្រួសារខ្ញុំរស់នៅក្នុងលេណដ្ឋាន ។ ម្តាយខ្ញុំប្រាប់ទៀតថា ខ្មែរក្រហមនៅក្នុងព្រៃហើយតែងតែតម្រូវឲ្យអ្នកទៅរកត្រី រកខស ឬប្រូតស្រូវលួចលាក់យកស្បៀង ឬសម្ភារផ្សេងៗមកឲ្យ ។ គាត់ថា ខ្មែរក្រហមធ្លាប់បានកាត់ក្បាលអ្នកស្រុកម្នាក់ដោយចោទថា ជារនុកក្នុងរបស់ទាហានលន់ នល់ ។ ភូមិ ឃុំដែលខ្ញុំរស់នៅ ជាតំបន់ប្រទាញប្រទង់រវាងទាហានលន់នល់ និងខ្មែរក្រហម ។ ចាស់ៗបានតំណាលថា ក្រោយខ្មែរក្រហមបានទទួលជោគជ័យ ខ្មែរក្រហមបានចាប់មេឃុំឈ្មោះផាង និងសហការីគាត់ប៉ុន្មាននាក់បាញ់សម្លាប់ចោល ។

## ការចាប់ផ្តើមរបបថ្មី

ក្រោយពេលដែលខ្មែរក្រហមរំដោះហើយ ភូមិឃុំមានជីវភាពដូចម្តេច ខ្ញុំអត់ដឹងទេ តែដល់ពេលដែលឃើញអ្នកជម្លៀសមករស់នៅរាយប៉ាយតាមផ្ទះ តាមវត្ត ទើបដឹងថា ជាការផ្លាស់ប្តូរមួយ ។ អ្នកទាំងនោះខ្លះមកពីទីក្រុងភ្នំពេញ ខ្លះមកពីត្រើយស្លា និងក្រុងបាត់ដំបង ។

គេបានសង់ខ្ទមជាជួរនៅចន្លោះភូមិ និងវត្តប៉ាឆា ។ កាលណោះ ទីនោះជាស្រែដីទំនាប ។ គេសង់ជាប់ៗគ្នាច្រើនជួរ ហើយផ្ទះនោះប្រកស្បូវ និងក្រាលរនាបឫស្សី ។ បើទោះ ជាមានខ្ទមច្រើនក៏អ្នកជម្លៀសនៅពុំគ្រប់ដែរ ។ ដូច្នេះ អង្គការក៏ឲ្យនៅតាមផ្ទះ ឬក្រោមផ្ទះ និងតាមវត្ត ។ ក្នុងចំណោមផ្ទះទាំងអស់ អត់តែផ្ទះខ្ញុំទេ ដែលមិនមានអ្នកជម្លៀសរស់នៅជាមួយ ។ ម្តាយខ្ញុំ និងបងៗបីនាក់ត្រូវអង្គការចាត់ទៅធ្វើការនៅតាមកង ហើយនៅផ្ទះ សល់តែបងស្រី ប្អូនស្រី និងខ្ញុំ ប៉ុន្តែពេលយប់ យើងនៅគេងផ្ទះជុំគ្នា ។ ម្តាយខ្ញុំប្រាប់ថា ថ្ងៃមួយ អង្គការបានប្រមូលប្រជាជនទាំងចាស់ទាំងថ្មី មកប្រជុំ និងបានចុចឈ្មោះបុរសម្នាក់ដែលជាអ្នកជម្លៀស (ត្រូវជាប្តីរបស់ ប៉ែ ឆៃប៉ូវ ដែលស្នាក់នៅក្នុងវត្ត) ឲ្យក្រោកឈរហើយចាប់ចងស្លាបសេក ។ ប្រជុំចប់ ក៏បណ្តើរគាត់យកទៅព្រៃអាស្រមមួយខាងលិចភូមិ របស់ខ្ញុំប្រហែល១គីឡូម៉ែត្រ (បច្ចុប្បន្នស្ថិតក្នុងឃុំពាមឯក និងជាវត្តស្វាយដង្គំ) ហើយយើង មិនដឹងថា បុរសនោះមានទោសអ្វីនោះទេ ។ ទីនោះមានការសម្លាប់មនុស្សច្រើនគួរសមដែរ នេះបើតាមសម្តីចាស់ៗ ។

ក្នុងចំណោមអ្នកជម្លៀសទាំងនោះ មានអ៊ំស្រីម្នាក់ដែលជិត

ស្និទ្ធជាមួយម្តាយខ្ញុំ ឈ្មោះ ហយ មកពីត្រើយស្លា ។ អ្នកជម្លៀសតែងតែយកចិត្តម្ចាស់ផ្ទះដោយឲ្យជាខោអាវ ។ ចាប់តាំងពីពេលនោះមក ខ្ញុំឃើញគេប្រមូលផ្តុំកុមារដែលមានវ័យប្រហាក់ប្រហែលនឹងបង ស្រីបន្ទាប់របស់ខ្ញុំយកទៅដាក់នៅវត្តប៉ាឆា (ឥឡូវសល់តែដើមអំពិលជាចំណាំ) ។ បងស្រីខ្ញុំ ប្រាប់ថា គាត់ខ្លាចខ្មោចណាស់ ហើយក្មេងៗឯទៀតក៏ដូចគ្នាដែរ និងនាំគ្នាយំឡើងទ្រហឹង ព្រោះដឹងថា ទីនោះពីសង្គមចាស់ជាកន្លែងកប់ខ្មោច ឬបូជាសព ។ ខ្ញុំនៅចាំបានថា ក្មេងៗទាំងនោះ អង្គការក៏មានបង្រៀនដោយឲ្យអានអក្សរលើក្តារខៀន ។ ខ្ញុំក៏បានចូលរួមដែរ ហើយអត្ថបទនោះវែងគួរសម ។ គ្រូអានចុះឡើងបីបួនសា ។ ខ្ញុំអត់ចេះអក្សរទេ តែចាំបាន ។ ខ្ញុំពុំចាំអត្ថបទទាំងមូលទេ គ្រាន់តែចាំខ្លះៗដូចជា គេនិយាយពីការកែច្នៃត្រីរបស់អង្គការ ដូចជា ធ្វើផ្អក មាំ ប្រហុក ត្រីឆ្អើរ ។ តាំងពីពេលនោះមក ខ្ញុំ និងក្មេងៗឯទៀតត្រូវដើរ ៥០០ម៉ែត្រទៅហូបបាយនៅរោងបាយរួម ដែលកាលណោះ នៅហូបបាយនៅឡើយទេ ។ បងស្រីខ្ញុំ ត្រូវហូបតាមកងចល័តរបស់ខ្លួន ។

អង្គការចាប់ផ្តើមឲ្យឈ្លបឆែកឆេរតាមផ្ទះ ប្រមូលយកទ្រព្យសម្បត្តិមកដាក់រួម ។ តែដំបូង អង្គការប្រកាសឲ្យប្រជាជនយកទៅប្រគល់ដោយស្ម័គ្រចិត្ត ។ ក្រោយមកទើបមាន ការឆែកឆេរ ហើយខ្ញុំឃើញឈ្លបខ្មែរក្រហមទាំងនោះ បាចសាចរបស់មិនសំខាន់ដូចជា សៀវភៅ ឬសម្ភារផ្សេងៗតាមស្ទឹង ។ អង្គការបានចាត់ឲ្យប្រុសៗវាយព្រះក្នុងវិហារវត្តស្វាយជ្រុំទម្លាក់ចោលក្នុងទឹក ។ ខ្ញុំ និងក្មេងៗដទៃទៀត បានចូលក្នុងវិហារគាស់ការ៉ូ ជញ្ជូនមកធ្វើមេមីក ។ ខ្ញុំឃើញគេដាក់ជណ្តើរឡើងកកាយយកសៀវភៅសាស្ត្រាស្លឹករឹត លើពិដានព្រះវិហារទម្លាក់ចោល ។ ក្រោយមកអ្នកដែលចូលរួមវាយព្រះពុទ្ធរូប បានស្លាប់ជាបន្តបន្ទាប់ ។ ចាស់ៗនិយាយថា មកពីអ្នកទាំងនោះរំលាយព្រះ ដូចពាក្យទំនៀមនិយាយថា សម្លាប់ម្តាយ រំលាយព្រះ មានទោសធ្ងន់ណាស់ និងឃើញបាបទាន់ហន់ ។ រំលាយព្រះ រួចហើយអង្គការក៏យកព្រះវិហារ ធ្វើជាមន្ទីរពេទ្យ ។ ខ្ញុំធ្លាប់ចាក់ថ្នាំដែរនៅក្នុងសម័យនោះ ។ ដបថ្នាំ គឺដបទឹកក្រូចសីរ៉ាំង និងម្ជុលធំៗចាក់បន្តគ្នា ប្រើម្ជុលតែមួយ ។ សំណាងដែរ ខ្ញុំពុំដែលអាប់សែរ ។ ខ្ញុំមិនដឹងថា ពេទ្យអង្គការព្យាបាលបែបណានោះទេ ។ ប្អូនថ្លៃប្រុសខ្ញុំបានរឭកប្រាប់ខ្ញុំថា បងស្រីរបស់គាត់ឈ្មោះ យូ ពេលត្រឡប់មកពីធ្វើការនៅការដ្ឋានវិញ មានអាការៈចង់ខ្យល់ ហើយបន្ទាប់ពីកោសខ្យល់រួច ក៏បញ្ជូនទៅមន្ទីរពេទ្យអង្គការ ។ ក្រោយពីពេទ្យខ្មែរក្រហមចាក់ថ្នាំរួច ក៏បែកពពុះមាត់ស្លាប់តែម្តង ។ គ្រួសាររបស់ប្អូនថ្លៃខ្ញុំ មានឪពុកម្តាយ បងស្រីបីនាក់ និងប្អូនប្រុសម្នាក់ទៀត បានស្លាប់ដោយការអត់ឃ្លាន និងជំងឺ ។

ជារៀងរាល់ថ្ងៃ ខ្ញុំឃើញខ្មែរក្រហមសែងសពយកទៅកប់នៅវត្តប៉ាឆា ខាងក្រោយ ផ្ទះរបស់ខ្ញុំប្រហែល២០០ម៉ែត្រ ។ ប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៦ ផ្ទះដែលអង្គការសង់ឲ្យអ្នកជម្លៀសមានសភាពស្ងាត់ជ្រងំ ដោយអ្នកខ្លះត្រូវប្តូរទីកន្លែង ខ្លះត្រូវស្លាប់ ។ ភាពអត់ឃ្លាន ក៏មានសភាពខ្លាំងឡើង ។ ទាំងអ្នកចាស់អ្នកថ្មី កើតជំងឺហើម រាក ហើយស្លាប់ ជាបន្តបន្ទាប់ ។ មានពេលខ្លះអង្គការបែកកន្ទក់ឲ្យហូប ។ ដោយអំណាចនៃសេចក្តីស្រេក ឃ្លាន ម្នាក់ៗស្វែងរកអាហារបន្ថែម ។ កូនអ្នកជម្លៀសពីរនាក់បងប្អូន ដែលនៅខាងកើតផ្ទះខ្ញុំ និងធ្លាប់លេងជាមួយគ្នារាល់ថ្ងៃ បានពុលសំបកដំឡូងស្លាប់ ។

អំឡុងពេលដែលខ្ញុំនៅផ្ទះ ក្រោយវត្តនោះ ខ្ញុំធ្លាប់ឃើញខ្មែរក្រហមបណ្តើរមនុស្ស ដោយចងស្លាបសេកផង ខ្ញុំមិនដឹងថា ខ្មែរក្រហមបណ្តើរអ្នកទាំងនោះទៅទីណាទេ ។ មានម្តងនោះ ពេលខ្ញុំភ្ញាក់ពីដេក ចុះមកដី ខ្ញុំឃើញអ្នកទោសម្នាក់ត្រូវខ្មែរក្រហមដាក់ច្រវាក់នៅ ក្រោមផ្ទះ គាត់ឈ្មោះ ហេង (សព្វថ្ងៃនៅរស់) ។ គ្មាននរណាម្នាក់ហ៊ានទៅសួរសុខទុកគាត់ទេ ។ រឿងដែលធ្វើឲ្យខ្ញុំភ័យកាន់តែខ្លាំងនោះ គឺ ខ្ញុំបានឃើញខ្មែរក្រហមវាយបណ្តើរកុមារម្នាក់ និងស្ត្រីចំណាស់ម្នាក់ ។ កុមារនោះ អាយុច្រើនជាងខ្ញុំ ព្រោះគាត់នៅកងកុមារ ។ គាត់ត្រូវឈ្លបចងវាយ ព្រោះតែគាត់លួចបេះសណ្តែកហូប ។ ខ្ញុំមិនដែលមើលទិដ្ឋភាពនោះទេ ច្រើនតែរត់ចេញ ។ នៅពេលដែលឈ្លបវាយស្ត្រីចំណាស់នោះ ខ្ញុំរត់ទៅណាមិនរួចទេ ។ កាលណោះ ខ្ញុំកំពុងបណ្តើរក្លួយដីដូនមួយពីរបីនាក់ទៅហូបបបរនៅរោងបាយ តាមផ្លូវ រអិលស្ទើរទប់ខ្លួនមិននឹង ។ ឈ្លបក្មេងៗ វាយទាត់ធាក់ស្ត្រីចំណាស់នោះពីក្រោយខ្ញុំ គាត់ដួលច្រមុលភក់ ស្រែកអង្វរឈ្លបកុំឲ្យធ្វើបាបគាត់ ។ ខ្ញុំខ្លាចណាស់ ខ្លាចឈ្លបវាយដោយទាំងខ្ញុំ ក៏ខំប្រឹងដើរឲ្យលឿន តែក្លួយៗខ្ញុំ វាប្រទាញរអិលមុខ

ក្រោយ ។ សេចក្តីភ័យខ្លាចរបស់ខ្ញុំនៅពេលនោះ មិនដឹងថាពិពណ៌នាបែបណាឲ្យអស់នោះទេ ។ តាំងពីពេលនោះមក គ្រាន់តែឮនរណាម្នាក់ស្រែកខ្លាំងៗ បេះដូងរបស់ខ្ញុំលោតញាប់រន្ថើន ។ ពេលខ្ញុំពរពោះកូនទី១ ភាពភ័យខ្លាចនេះកើតមានឡើងម្តងទៀត ពេលនោះខ្ញុំដើរពីមុខអ្នកអូសរទេះ ។ អ្នកអូសរទេះនោះ បានស្រែកគំហកសូមផ្លូវ ធ្វើឲ្យខ្ញុំស្ទុះដើរទៅមុខមិនរួច ហើយធ្វើឲ្យនឹកឃើញដល់ទិដ្ឋភាពដែលឈ្លបក្មេងៗវាយធ្វើបាបស្ត្រីចំណាស់ម្នាក់នោះក្នុងរបបខ្មែរក្រហម ។ រូបភាពដ៏ខ្លោចផ្សា នោះបានលេចឡើងក្នុងខួរក្បាលខ្ញុំជាថ្មីម្តងទៀត ។

## ការផ្លាស់ប្តូរទីលំនៅ

ក្រោយមក ផ្ទះរបស់ខ្ញុំត្រូវបានអង្គការស្នើរុះ ហើយឲ្យគ្រួសារខ្ញុំ ក៏ដូចជាអ្នកឯទៀត ទៅសង់ផ្ទះនៅតាមដងផ្លូវវិញ ។ អ៊ំខ្ញុំបានរៀបចំកន្លែងដេកក្រោមផ្ទះ ដែលសល់តែដំបូល ។ ផ្ទះគាត់ដែលនៅជាប់ខ្ញុំនោះ ត្រូវអង្គការរុះយកឈើអស់នៅសល់តែគ្រឹះសសរប៉ុណ្ណោះ ។ យើងទាំងអស់គ្នាត្រូវនៅកន្លែងផ្ទះចាស់សិនទម្រាំផ្ទះថ្មីធ្វើរួច ។ បន្ទាប់ពីផ្ទះថ្មីសង់រួចរាល់ យើងទាំងអស់គ្នា បានផ្លាស់ទៅនៅផ្ទះថ្មី ។ អ៊ំខ្ញុំគាត់ឡូឡាជេរអង្គការ ដែលយកឈើប្រហោង ឈើបែកមកធ្វើផ្ទះឲ្យគាត់នៅ ហើយរុះយកឈើផ្ទះគាត់ល្អៗយកទៅបាត់ ។ ផ្ទះថ្មីរបស់យើងពោរពេញដោយសត្វសង្កើចទោះបីជាអ៊ំខ្ញុំដាំទឹកក្តៅចាក់ក៏មិនពាយដែរ ។

អំឡុងពេលនោះ អង្គការចាប់ផ្តើមជ្រើសរើសកងចល័តកុមារម្តងទៀត ខ្ញុំចង់ទៅនឹងគេណាស់ ចង់ទៅចុះការដ្ឋានដូចអ្នកឯទៀតដែរ ។ ខ្ញុំរៀបចំអីវ៉ាន់ខ្លួនឯងដោយមិនប្រាប់ម៉ែ ។ ខ្ញុំបានមកដល់ការដ្ឋានអង្គុយចាំអង្គការនាំទៅ ម៉ែរបស់ខ្ញុំទៅទាន់ និងឃាត់ហើយស្នើមេកងកុំឲ្យខ្ញុំទៅ ។ ខ្ញុំខឹងនឹងគាត់ណាស់ ហើយនិយាយប្រៀបធៀបឲ្យគាត់ស្តាប់ថា ម៉ែមើល សាឡី គេកើតឆ្នាំដំណាលខ្ញុំដែរ ម៉ែគេឲ្យទៅ ហើយខ្ញុំថាឲ្យម៉ែទៀតថា ម៉ែឯងកម្មសិទ្ធិក្រាស់ណាស់ មិនឲ្យកូនទៅ ។

ខ្ញុំមើលទៅក្មេងឯទៀតដូចជាមានអំណួត ដែលបានទៅកងចល័តកុមារ ជាពិសេស សាឡី មើលទៅវាដូចជាស្វាហាប់ណាស់ ។ នឹកឃើញដល់រឿងនេះខ្ញុំចង់តែសើច ហួសចិត្តថា អង្គការនោះ អីក៏ពូកែម្ល៉េះ? សំណាងហើយដែលម៉ែខ្ញុំជាអ្នកមូលដ្ឋាន បើអ្នកថ្មីវិញប្រហែលជាយ៉ាប់ហើយចំពោះរឿងខ្ញុំ ។

អង្គការបានយកកុមារទាំងអស់ទៅស្នាក់នៅផ្ទះក្បឿងនៅក្បែរវត្តឯករង្សី ។ បងប្រុសជីដូនមួយខ្ញុំ តែងលួចមកផ្ទះញឹកញាប់ ហើយក៏ត្រូវមេកងមកចាប់យកទៅវិញ ធ្វើទារុណកម្មតិចតួច ។ គាត់ប្រាប់ថា ពេលយប់ឡើង គាត់ខ្លាចខ្មោច ហើយក្មេងៗឯទៀតយំទ្រហឹង ដេករងារគ្មានភួយដណ្តប់ ។ ពេលថ្ងៃ ធ្វើការដូចមនុស្សធំដែរ គឺរែកដី ជញ្ជូនកណ្តាប់ ទប់ទំនប់ ។ ចំណែកខ្ញុំ អង្គការហៅថាក្មេងការដ្ឋាន ។ ការងាររបស់ពួកខ្ញុំ គឺរើសអាចម៍គោ បោចស្មៅក្នុងចម្ការ ឬស្រែ និងចិញ្ច្រាំទន្ទ្រានខែត្រ ។

ម្តងនោះ ខ្ញុំរវល់លីងពោតហូប ហើយរកកន្លែងធ្វើការមិនឃើញ ។ ខ្ញុំដើរបណ្តើរហូប ពោតបណ្តើរ កម្មាភិបាលចាស់ម្នាក់ក៏សួរថា មិត្តកុមារដើរទៅណា? ខ្ញុំឆ្លើយថា ទៅរកកន្លែងធ្វើការ ។ ហេតុអីក៏យឺត? ខ្ញុំឆ្លើយថា មកពីខ្ញុំរវល់ដាំទឹកលាងដំបៅឲ្យអ៊ំខ្ញុំ ។ ខ្ញុំចេះតែភរដោយឥតព្រាងទុក ។ ខ្ញុំរកកន្លែងធ្វើការមិនឃើញទេ ។ មកដល់ការដ្ឋាន កុមារដទៃទៀតបានប្រាប់ខ្ញុំថា ឯងអត់បបរទេព្រោះអត់បានធ្វើការ ។ ខ្ញុំដូចជាឆ្ងល់ណាស់ថា ហេតុអីអង្គការឲ្យខ្ញុំធ្វើមេកងកុមារការដ្ឋាននេះ បើខ្ញុំមិនសូវនិយាយស្តី ហើយមាឌក៏តូច ។ ក្រោយរបបខ្មែរក្រហមដួលរលំ ខ្ញុំខ្មាស់គេផង និងខឹងផងពេលដែលអ្នកទាំងនោះហៅខ្ញុំថា មេកងកុមារ ។ ខ្ញុំស្អប់ពាក្យនេះណាស់ ។ ខ្ញុំគិតថា អ្នកទាំងនោះចង់ថា ខ្ញុំជាមនុស្សអាក្រក់ កាចសាហាវ ដូចកម្មាភិបាលផ្សេងៗ ហើយ តែទោះជាយ៉ាងណា ខ្ញុំបានត្រឹមតែខ្ទប់ខ្ញាញ់ក្នុងចិត្តមិនសម្តែងឲ្យគេដឹង ។

ពេលភ្លៀងធ្លាក់មក ពួកខ្ញុំរងារណាស់ ហើយក៏មិនដែលឃើញអង្គការហៅឲ្យមក ជ្រកភ្លៀងដែរ ។ ពេលរើសស្មៅក្នុងស្រែពួកខ្ញុំអង្គុយដកស់បន្ទឹមក្នុងទឹកស្រែ ដោយពុំគិត ខ្លាចឈ្លើងទាមទេ ។ កាលណោះ ខ្ញុំដូចជាអត់ខ្លាចឈ្លើងទេ ចុះហេតុអ្វីក្រោយមកខ្ញុំខ្លាចម្ល៉េះ? ។ ក្រៅពីរៀនរាប់អក្សរ ម៉ែកុមារ ឬអ្នកគ្រូ បានបង្រៀនឲ្យច្រៀងចម្រៀង ។ ខ្ញុំចាំបានតែមួយឃ្លាទេគឺយើងខ្ញុំកុមារស្រឡាញ់អង្គការ ឥតមានព្រំដែន ស្រឡាញ់មែនទែន ។ ក្រៅពីធ្វើការតាមស្រែចម្ការ ខ្ញុំធ្លាប់ទៅចូលរួមប្រជុំនៅសហករណ៍ម្តង ។ សហករណ៍នោះនៅវត្តឯករង្សី ហើយក្រោយរបបខ្មែរក្រហមដួលរលំក៏ក្លាយជាសាលាបឋមសិក្សា ។ ក្រោយមកទៀត ក៏រុះយកមកសាលា

រៀនបឋមព្រែកនរិន្ទ ។

ជាញយៗម៉ែកុមារ តែងសួរនាំពីប្រវត្តិឪពុកម្ដាយ ។ កាលណោះ ខ្ញុំដូចជាអត់សប្បាយចិត្តសោះ ព្រោះគ្មានអ្វីអួតនឹងគេ ដោយសារតែគ្រួសារខ្ញុំអ្នកក្រ ឪពុកជាកម្មករ ម្ដាយធ្វើស្រែ ឯអ្នកខ្លះវិញ ជាកូនអ្នកជំនួញ អ្នកធ្វើការ ។ ខ្ញុំចង់តែនិយាយបំភ្លើស តែខ្ញុំខ្មាស់គេ ខ្លាចគេដ្ឋាញ់ ហើយខ្ញុំគ្មានជំនាញខាងនិយាយ ។

ភូមិរបស់ខ្ញុំបានបាត់មនុស្សប្រុសជាបណ្ដើរៗចាប់ពីចុងឆ្នាំ១៩៧៦ ខ្លះត្រូវអង្គការ ហៅទៅរៀនសូត្រ ហើយខ្លះទៀតរត់គេច តែមកដល់ឥឡូវក៏ពុំឃើញត្រឡប់មកវិញទេ ។ ចាប់តាំងពីពួកនិរតីមកគ្រប់គ្រង និងផ្លាស់ទីលំនៅខ្ញុំមក ការងារ ការហូបចុករឹតតែលំបាកឡើងៗ ។ ម៉ែខ្ញុំ ត្រូវធ្វើការនៅកងមនុស្សចាស់ ឆ្ងាយពីភូមិ ហើយពុំវិលល្ងាចទេ ។ តែក្រោយពេលគាត់ធ្លាក់ឈាម ប្រធានកងនារីបានអនុញ្ញាតឲ្យគាត់មកព្យាបាលនៅភូមិវិញ ។ គាត់ពុំហ៊ានសុំអង្គការឈប់ទេ តែបានអ្នកភូមិម្នាក់ឈ្មោះ ស៊ាង បានស្នើសុំមេកងឲ្យដោយប្រាប់ថា បើមិនឲ្យម៉ែខ្ញុំសម្រាកព្យាបាលទេ នោះគាត់នឹងស្លាប់មិនខាន ។ ដោយមានការអង្វរកពីអ៊ំស៊ាង ទើបមេកងអនុញ្ញាតឲ្យម៉ែខ្ញុំឈប់សម្រាក ។ តាំងពីពេលនោះមក ម៉ែខ្ញុំក៏បានធ្វើការនៅភូមិ ហើយល្ងាចឡើងបានមកផ្ទះជួបជុំគ្រួសារវិញ ។

តាំងពីខ្ញុំដឹងក្ដី ខ្ញុំពុំដែលឃើញម៉ែខ្ញុំសប្បាយចិត្ត ញញឹមចេញមកពីបេះដូងទេ ទើបតែពេលខ្ញុំប្រឡងជាប់គ្រូនៅឆ្នាំ១៩៨៦ ខ្ញុំ ឃើញគាត់រំភើបចិត្ត ញញឹម និងបណ្ដើរខ្ញុំទៅកាត់ខោអាវ ។ ស្នាមញញឹមនោះ ស្ថិតនៅនឹងមុខខ្ញុំជានិច្ច ។

ក្នុងចំណោមបងខ្ញុំទាំង៤ បងស្រីទី១ ធ្វើការធ្ងន់ និងឆ្ងាយពីផ្ទះជាងគេ ។ ក្នុងអំឡុងពេលនោះ ខ្ញុំមិនដែលជួបមុខគាត់ទេ ។ គាត់ធ្វើនៅកងចល័តនារី ដែលត្រូវផ្លាស់ប្ដូរកន្លែង ធ្វើការច្រើនកន្លែងដូចជា ប្រាសាទឯកភ្នំ វាលទ្រា (ថ្មគោល) និងទំនប់តាអុន ។ នៅប្រាសាទឯកភ្នំ គាត់តំណាលប្រាប់ខ្ញុំថា គាត់ឃើញគេបណ្ដើរអ្នកទោសទៅសម្លាប់រាល់ល្ងាច ។ មានម្ដងនោះ គាត់ឃើញគេចងដៃចងជើងក្មេងម្នាក់ សែងដូចសែងជ្រូក ។ នៅទីនោះ គាត់ត្រូវជីថ្មប្រាសាទយកមកធ្វើទំនប់មួយខាងចុងឆ្ដោរ ដែលគេហៅថា ទំនប់យាយនូ ។ បើគិតពីប្រាសាទឯកភ្នំមកចុងឆ្ដោរ បើដើរកាត់ប្រហែល៣គីឡូម៉ែត្រ ហើយបើដើរតាមព្រែកប្រហែល៥គីឡូម៉ែត្រ ។ ពិសិដ្ឋ និងផល្លី ដែលជាគ្រូបង្រៀនដូចខ្ញុំដែរ បានរម្លឹកប្រាប់ខ្ញុំថា គាត់ត្រូវគេប្រើឲ្យជញ្ជូនថ្មយកទៅធ្វើទំនប់ដែរ កាលណោះគាត់នៅកងកុមារចល័តឃុំពាមឯក ។ ភូមិចុងឆ្ដោរ ជាកន្លែងដាំបន្លែ ។ មីងម្នាក់ឈ្មោះ មឿន កាលពីសង្គមចាស់នៅ ក្រោយផ្ទះរបស់ខ្ញុំ ប្ដីរបស់គាត់ឈ្មោះ អន បានប្រាប់ខ្ញុំថា ថ្ងៃមួយគាត់ត្រូវបានមេចុងភៅការដ្ឋានចាត់ឲ្យទៅយកត្រប់នៅខាងចុងឆ្ដោរគ្នាពីរបីនាក់ ។ ពេលត្រឡប់មកវិញដល់កន្លែងស្ងាត់មួយ ដោយធ្ងន់ពេក ក៏ដាក់ចុះបម្រុងអង្គុយ ស្រាប់តែក្រឡេកទៅម្ខាងឃើញ គេកំពុងសម្លាប់មនុស្ស ។ គាត់ភ័យណាស់ លើកត្រប់ប្រឹងដើរយ៉ាងលឿន ហាក់ដូចជា គ្មានអ្វីធ្ងន់សោះ ។ ក្នុងចិត្តគាត់គិតថា ពួកនោះនឹងតាមមកចាប់គាត់សម្លាប់ ។ តាំងពីពេលនោះមក គាត់ថា ខ្លួនគាត់បេះតែល្ហិតល្ហៃមកទល់សព្វថ្ងៃ ហើយសាច់របស់គាត់នៅតែក្រៀមស្វិត ។

បងប្រុសខ្ញុំ ត្រូវបានគេចាត់ឲ្យរកស្បៀងនៅស្រុកលើ ដូចជាខាង បដាក ស្រុករតនមណ្ឌល ។ គាត់ពុំសូវអត់ឃ្លានទេ ។ គាត់ថា នៅទីនោះ គេហូបបាយ មិនហូបបបរទេ ។ បងស្រីទី៣ គាត់នៅកងយុវជនចល័តដែរ តែធ្វើការនៅតែក្នុងសហករណ៍ ។ គាត់ធ្លាប់ត្រូវបានអង្គការចាត់ឲ្យធ្វើពេទ្យ តែអ៊ំខ្ញុំមិនឲ្យធ្វើ ព្រោះគាត់យល់ថា ធ្វើពេទ្យ គឺគ្មានអ្វីក្រៅពីសែងខ្មោច និងជីករណ្ដៅកប់ខ្មោចទេ ហើយមេកងរបស់គាត់ក៏រារាំងមិនឲ្យគាត់ធ្វើដែរ ។ កាលណោះ គាត់គ្រុនចាញ់ញឹកញាប់ ហើយនឹងកើតដំបៅនៅកែងជើងទៀត ។ ទម្រាំព្យាបាលជា ត្រូវចំណាយពេលយូរ ។ ឯបងស្រីទី៤ នៅក្នុងកងចល័តកុមារ ។ គាត់ត្រូវតែងលួចបូតស្រូវ រើសកួរស្រូវ ដើម្បីយកមកបំពេញសេចក្ដីស្រេកឃ្លានក្នុងគ្រួសារ ។ គាត់រម្លឹកប្រាប់ខ្ញុំថា ថ្ងៃមួយ ពេលដែលគាត់កំពុងរើសកួរស្រូវ ស្រាប់តែឈ្លបទៅដល់ ។ គាត់ក៏ដូចជាក្មេងៗដទៃទៀត ភ័យស្លន់ស្លោររត់រៀងៗខ្លួន ។ គាត់បានឃើញឈ្លបចាប់បានក្មេងប្រុសម្នាក់ជាកូនអ្នកជម្លៀស ។ ពួកវាវាយក្មេងនោះ ដួលត្រឡប់ត្រឡិនក្នុងស្រែ ។ គាត់អាសូរ ក្មេងនោះណាស់ តែពុំដឹងជួយយ៉ាងម៉េច ។ ឈ្លបដេញវាយក្មេងនោះដល់ភូមិ ។ ក្មេងនោះភ័យញ័រខ្លួនចំប្រប់ ។ តាំងពីពេលនោះមក ម៉ែខ្ញុំលែងឲ្យខ្ញុំដើររើសកួរ ឬបូតស្រូវទៀត ហើយ សុខចិត្តហូបបបរលាយត្រកួន ។ **(នៅមានត)**

**ផាន់ សុផល**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










*មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ truthpdara@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។*

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

*១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។*

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

*១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។*

*ដើម្បីយុត្តិធម៌និងការចងចាំ*
*ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ*

*ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក* (USAID)
*អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩*

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
*ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨*

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 208, 2017 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.